អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2018, 16:00
CMS/CFO: Sann Rada

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| **កែលើឯកសារលេខ៖** | **ERN(s):** | **កាលបរិច្ឆេទ៖** | **ប្រភេទកំណែ៖** |
|---|---|---|---|
| E3/10655 | 01506022-01506096 | 22/01/2018 | ☐ កែលើឯកសារដើម<br>☒ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| **មូលហេតុនៃការកែតម្រូវ៖** |
|---|
| ជំនួសឯកសារមិនទាន់កែតម្រូវដោយឯកសារដែលបានកែតម្រូវរួច។ |

| **សេចក្តីលម្អិតនៃការកែតម្រូវ៖** |
|---|
| |

ស្នើដោយ៖ អង្គភាពបកប្រែភាសា — ហត្ថលេខា៖

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ — ហត្ថលេខា៖

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ — ហត្ថលេខា៖

**[Chapter 1]**

## ជំពូកទី ១៖ សេចក្តីណែនាំអំពីរបបខ្មែរក្រហម

*ពេលគិតពីអតីតកាល ខ្ញុំគិតថា ខ្ញុំសំណាងណាស់ដែលបាននៅរស់ដល់ឥឡូវ។ ជីវិតខ្ញុំក្នុងរបបខ្មែរក្រហមគឺ ដូចរង់ចាំការស្លាប់រាល់ថ្ងៃអញ្ចឹង។*

*លោកស្រី ហ៊ុន សន [Hun Sorn] ខេត្តសៀមរាប*

ផ្នែកនេះផ្តល់នូវទិដ្ឋភាពមួយនៃរបបខ្មែរក្រហម ដែលរៀបរាប់ដោយរឿងរ៉ាវផ្ទាល់ខ្លួនដែលប្រមូលចងក្រងក្នុងផ្នែកសំខាន់ៗក្នុងសៀវភៅនេះ។

**របបខ្មែរក្រហម**

របបខ្មែរក្រហមបានគ្រប់គ្រងកម្ពុជាជាផ្លូវការចាប់ពីខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ខែ មករា ឆ្នាំ ១៩៧៩ និងត្រូវបានដឹកនាំដោយរដ្ឋាភិបាលកុម្មុយនីស្តហួសហេតុបំផុតមួយ។ របបខ្មែរក្រហមបានបំផ្លាញទាំងស្រុងនូវក្តីសុបិនរបស់កុមារី និងស្ត្រី ដោយបង្វែរជីវិតរបស់ពួកគេឱ្យធ្លាក់ចូលក្នុងភាពរងទុក្ខវេទនា និងរងគ្រោះយ៉ាងខ្លាំង។

ខ្មែរក្រហមបានគ្រប់គ្រងពលរដ្ឋជាមួយនឹងការបំភ័យភេរវកម្ម និងការគំរាមកំហែងគ្មានទីបញ្ចប់។ កុមារី និងស្ត្រីត្រូវបានបង្ខំឱ្យរស់នៅក្រោមការភ័យខ្លាចយ៉ាងខ្លាំង។ ពួកគេត្រូវបានដកហូតសេរីភាពផ្ទាល់ខ្លួន និងជម្រើសបុគ្គល។ កុមារី និងស្ត្រីជាច្រើនបានឆ្លងកាត់បទពិសោធន៍នៃការស្លាប់សមាជិកគ្រួសារជាច្រើន ការបាត់ខ្លួនមនុស្សជាទីស្រឡាញ់ ការឃើញផ្ទាល់ភ្នែកនូវអំពើទារុណកម្ម អំពើហិង្សា និងការសម្លាប់មនុស្ស និងជាអ្នកទទួលរងនូវការធ្វើបាបឃោរឃៅធ្ងន់ធ្ងរ។ បទពិសោធន៍ទាំងនេះនៅតែជារឿងតក់ស្លុតសម្រាប់ក្រុមស្ត្រីដែលបានរួចរស់ជីវិតពីរបបនោះ។

ដោយផ្អែកលើតំបន់ និងឆ្នាំនៃរបបខ្មែរក្រហម ភាពភ័យខ្លាច និងការរងទុក្ខលំបាកដែលស្ត្រីបានជួបប្រទះមានភាពចម្រុះ។ ទោះជាយ៉ាងណា ភាពភ័យខ្លាចដែលកើតមានជាទូទៅបំផុតក្នុងចំណោមស្ត្រីក្នុងអំឡុងពេលនេះ គឺភាពអត់ឃ្លាន និងលទ្ធភាពដែលនឹងត្រូវគេសម្លាប់បានគ្រប់ពេល។ ភាគច្រើននៃស្ត្រីនៅក្នុងការស្រាវជ្រាវនេះ បានបាត់បង់សមាជិកគ្រួសារខ្លួនជាច្រើន ហើយការឆ្លងកាត់ហេតុការណ៍ស្លាប់ជាបន្តទាំងនេះធ្វើឱ្យពួកគេមានអារម្មណ៍ថា ពួកគេអាចស្លាប់គ្រប់ពេល។

Deleted: តក់ស្លុត

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

## ការបំផ្លិចបំផ្លាញរចនាសម្ព័ន្ធសង្គម

សង្គមកម្ពុជាជាប្រពៃណី ត្រូវបានបំផ្លាញទាំងស្រុងដោយប្រព័ន្ធគ្រប់គ្រងរបស់ខ្មែរក្រហម។ គ្រួសារ ដែលជាឯកតាតូចជាងគេបំផុតនៅក្នុងសង្គម ត្រូវបានបែកបាក់ដោយសារគោលបំណងចង់ធ្វើបដិវត្តន៍ឱ្យបានជោគជ័យរបស់ខ្មែរក្រហម តាមរយៈជីវិតសហករណ៍ គឺប្រជាជនត្រូវបង្ខំឱ្យចេញឆ្ងាយពីក្រុមគ្រួសាររបស់ពួកគេដើម្បីចូលរួមធ្វើពលកម្មខ្លាំងក្លា។ ភាគច្រើន ប្ដីប្រពន្ធត្រូវគេបង្ខំឱ្យនៅបែកគ្នា ហើយកូនត្រូវបានបំបែកពីឪពុកម្ដាយ។ លោកស្រី ណាន ណូរី [Nan Nory] អាយុ ៦៧ ឆ្នាំ បាន និយាយ ថា៖ "*ពេលវេលារីករាយក្នុងរបបខ្មែរក្រហមគឺមានតែនៅពេលដែលខ្ញុំអាចជួបឪពុកម្ដាយខ្ញុំប៉ុណ្ណោះ*"។ គាត់ មានភាពភ័យខ្លាចជាប់រហូតថា ឪពុកម្ដាយគាត់អាចនឹងត្រូវពួកខ្មែរក្រហមសម្លាប់នៅពេលណា មួយ។

ព្រះពុទ្ធសាសនា ដែលជាសាសនាលេចធ្លោបំផុតនៅក្នុងប្រទេសកម្ពុជា ត្រូវបានលុបបំបាត់ចោល។ វត្តត្រូវបានប្រែក្លាយទៅជាឃ្លាំង និងត្រូវបានប្រើជាកន្លែងប្រជុំផងដែរ។ នៅតំបន់ខ្លះ វត្តត្រូវគេប្រើធ្វើជាគុកផងដែរ[១]។ ព្រះសង្ឃត្រូវបានបង្ខំឱ្យសឹក និងក្លាយជាឧបាសក។ លោក ហ៊ុច វឹក [Huch Veork] អាយុ ៦២ ឆ្នាំ បាននិយាយថា៖ "*ខ្ញុំគឺជាព្រះសង្ឃមួយអង្គមុនរបបខ្មែរក្រហម។ មិនយូរប៉ុន្មានបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅក្នុងតំបន់ខ្ញុំ នៅខេត្តតាកែវ ព្រះសង្ឃទាំងអស់ត្រូវបានបង្ខំឱ្យប្ដូរសម្លៀកបំពាក់ចេញទាំងអស់។ ខ្មែរក្រហមបានឱ្យសម្លៀកបំពាក់ពណ៌ខ្មៅមកឱ្យយើងស្លៀក។ ពួកគេបានបង្ខំខ្ញុំឱ្យផ្លាស់ទីទៅខេត្តកំពត ហើយខ្ញុំត្រូវបានបង្ខំឱ្យធ្វើការឥតឈប់ដូចអ្នកផ្សេងទៀតដែរ*"[២]។ ព្រះសង្ឃខ្លះដែលត្រូវបានបង្ខំឱ្យលាចាកពីភាពជាព្រះសង្ឃត្រូវបានបង្ខំឱ្យរៀបការ។ លោកស្រី ផុម អួន [Phom Oun] ត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យរៀបការជាមួយអតីតព្រះសង្ឃ[៣]។ ប្រពៃណី និងសហគមន៍សាសនាត្រូវបានបំផ្លាញ ហើយមេដឹកនាំខ្មែរក្រហមថ្មីបានឡើងកាន់អំណាច និងគ្រប់គ្រងលើប្រជាជន។

## គ្រប់យ៉ាងដើម្បីបដិវត្តន៍ គ្មានទេសិទ្ធិមនុស្ស

ប្រជាជនត្រូវបានគេដកហូតសិទ្ធិមនុស្សជាមូលដ្ឋានទាំងអស់ រួមទាំងសិទ្ធិរស់រានមានជីវិតផង។ ប្រជាជនជាច្រើនត្រូវបានប្រហារជីវិតដោយគ្មានហេតុផល។ ក្រោមឈ្មោះបដិវត្តន៍ ការរើសអើងគឺជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់ប្រជាជន។ ប្រជាជនមិនត្រូវបានប្រព្រឹត្តមកលើស្មើៗគ្នាទេ។ ប្រជាជនត្រូវបានបែងចែកជាពីរក្រុម៖ "ប្រជាជនមូលដ្ឋាន" និង "ប្រជាជនថ្មី"។ ជាទូទៅ "ប្រជាជនមូលដ្ឋាន" គឺអ្នកដែលរស់នៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមមុនខែ មេសា ឆ្នាំ ១៩៧៥ រីឯ "ប្រជាជនថ្មី" គឺអ្នកដែលរស់នៅក្នុងទីក្រុងមុនខែ មេសា ឆ្នាំ ១៩៧៥។ "ប្រជាជនថ្មី" ត្រូវគេបង្ខំឱ្យផ្លាស់ទីទៅតំបន់ជនបទ។ ក្នុងករណីជាច្រើន "ប្រជាជនមូលដ្ឋាន" អាចរីករាយនឹងសិទ្ធិមួយចំនួន ដែលមិនត្រូវបានផ្ដល់ទៅឱ្យ "ប្រជាជនថ្មី" ឡើយ។

Deleted: ដាក់

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

ប្រជាជនទាំងអស់ត្រូវគេបង្ខំឱ្យធ្វើការ។ ស្ត្រីមានផ្ទៃពោះត្រូវគេបង្ខំឱ្យធ្វើការ ហើយស្ត្រីដែលទើបនឹងសម្រាលកូនរួចក៏ត្រូវគេបង្ខំឱ្យត្រឡប់ទៅធ្វើការវិញដែរ។ កុមារមិនអាចចូលសាលារៀនបានទេ ប៉ុន្តែពួកគេត្រូវបានគេបង្ខំឱ្យធ្វើការ។ ជំនួសការទៅសាលា កុមារត្រូវសិក្សាពីសិទ្ធាន្តបដិវត្តន៍។ លោកស្រី ប៊ុនឈិត វាសនា [Bunchhit Veasa] បាននិយាយថា៖ "*មានវគ្គសិក្សារយៈពេលមួយម៉ោងស្តីពីមនោគមវិជ្ជានយោបាយសម្រាប់កុមារ។ ខ្ញុំត្រូវស្តាប់គ្រូបង្រៀនដែលនៅក្មេងនៅឡើយ ហើយពួកគេបាននិយាយអំពីបដិវត្តន៍*"[៤]។ ភាគច្រើនពួកគេគ្មានពេលលេង គ្មានពេលសម្រាកទេ ហើយពេលវេលាផ្ទាល់ខ្លួនគឺសម្រាប់តែគេងប៉ុណ្ណោះ។

**លក្ខណៈផ្លូវភេទ**

លក្ខណៈផ្លូវភេទក៏ត្រូវបានគ្រប់គ្រងផងដែរ ហើយ "ការប្រព្រឹត្តិខុសសីលធម៌" ត្រូវបានកំណត់ដើម្បីហាមឃាត់រាល់ទំនាក់ទំនងរវាងបុរស និងស្ត្រីក្រៅចំណងអាពាហ៍ពិពាហ៍[៥]។ ខ្មែរក្រហមក៏បានគ្រប់គ្រងផងដែរលើការទំនាក់ទំនងផ្លូវភេទចំពោះគូស្វាមីភរិយានៅទីតាំងមួយចំនួន។

ខ្មែរក្រហមបានបែងចែកប្រជាជនជាពីរក្រុម៖ បុរស/កុមារា ឬស្ត្រី/កុមារី។ ដូច្នេះ ក្រុមភេទទីបីត្រូវគេរើសអើង ឬផ្តន្ទាទោស[៦]។ សេរីភាពនៃជម្រើសផ្ទាល់ខ្លួនត្រូវបានគេដកហូត សាសនាត្រូវបានលុបបំបាត់ចោល គ្មានសិទ្ធិបង្ហាញពីអារម្មណ៍ផ្ទាល់ខ្លួន ឬការតវ៉ាចំពោះពួកខ្មែរក្រហមឡើយ។ គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឱ្យជ្រើសរើសការងារដោយខ្លួនឯងឡើយ ប៉ុន្តែជំនួសមកវិញត្រូវបានបង្ខំឱ្យធ្វើពលកម្មលំបាកៗដែលផ្តល់ដោយពួកខ្មែរក្រហម។ គ្មានសកម្មភាពសេដ្ឋកិច្ចណាត្រូវបានអនុញ្ញាតឡើយ។ សេវាថែទាំសុខភាពភាគច្រើនគឺមិនអាចរកបានទេ។ ប្រជាជនជាច្រើនស្លាប់ដោយសារជំងឺដែលអាចបង្ការបាន ឬកង្វះអាហារូបត្ថម្ភ។

**ការគ្រប់គ្រងលើអាពាហ៍ពិពាហ៍**

ក្នុងអំឡុងរបបខ្មែរក្រហម ពួកខ្មែរក្រហមបានគ្រប់គ្រងលើអាពាហ៍ពិពាហ៍ស្ទើរតែទាំងអស់។ ពេលស្ត្រីចង់រៀបការ ពួកគេបានសុំការអនុញ្ញាតពីពួកខ្មែរក្រហម។ ក្នុងករណីខ្លះ ពួកខ្មែរក្រហមបានបង្ខំឱ្យស្ត្រីរៀបការដោយផ្ទុយពីឆន្ទៈរបស់ពួកគេ។ ពួកខ្មែរក្រហមបានគ្រប់គ្រងលើពិធីអាពាហ៍ពិពាហ៍ ហើយអាពាហ៍ពិពាហ៍រួមត្រូវបានធ្វើឡើង។ ពួកខ្មែរក្រហមបានរៀបចំ និងគ្រប់គ្រងពិធីអាពាហ៍ពិពាហ៍ទាំងនោះ ហើយភាគច្រើន គ្មានសមាជិកគ្រួសារណាម្នាក់ត្រូវបានអនុញ្ញាតឱ្យចូលរួមឡើយ។ គ្មានការរៀបចំពិធីតាមប្រពៃណី គ្មានតន្ត្រី និងគ្មានអាហារពិសេសឡើយ។ ដំណើរការនោះគឺដូចនឹង "កិច្ចប្រជុំ" ដែរ។ ជាធម្មតា "កិច្ចប្រជុំ" មានរយៈពេលតែមួយម៉ោងប៉ុណ្ណោះ ហើយត្រូវបានធ្វើឡើងនៅពេលល្ងាច។ នេះគឺជាប្រព័ន្ធគាបសង្កត់យ៉ាងខ្លាំង។ រដ្ឋាភិបាលព្យាយាមគ្រប់គ្រងលើរាល់ការបង្កើតឯកតាគ្រួសារថ្មីទាំងអស់ រួមទាំងជម្រើសបន្តពូជផងដែរ។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

នៅក្នុងការស្រាវជ្រាវនេះ ស្ត្រី ៣១ នាក់ បានរៀបការក្នុងអំឡុងរបបខ្មែរក្រហម (N=១២១, ២៦%)។ ការស្រាវជ្រាវនេះបានកំណត់ឃើញថា មាន "អាពាហ៍ពិពាហ៍" ខុសគ្នាជាច្រើនប្រភេទ ក្នុងអំឡុងរបបខ្មែរក្រហម។ ស្ត្រីមួយចំនួនត្រូវបានបង្ខំឱ្យរៀបការជាមួយបុរសដែលខ្មែរក្រហមជ្រើសរើសឱ្យ។ អ្នកដែលត្រូវបានបង្ខំឱ្យរៀបការទាំងនោះបានរៀបរាប់ពីអារម្មណ៍ខឹង និងទុក្ខព្រួយ ហើយអន់ចិត្តនៅពេលពួកគេត្រូវគេបង្ខំឱ្យរៀបការ។ ការបដិសេធនឹងការណែនាំបែបនោះជាធម្មតានាំដល់ការដែលត្រូវគេសម្លាប់។ អាពាហ៍ពិពាហ៍ដោយបង្ខំនេះគឺខុសគ្នាពីអាពាហ៍ពិពាហ៍ផ្សំផ្គុំតាមប្រពៃណី ព្រោះឪពុកម្ដាយគ្មានអំណាចក្នុងដំណើរការសម្រេចចិត្តលើអាពាហ៍ពិពាហ៍របស់កូន ប៉ុន្តែជំនួសមកវិញ ពួកខ្មែរក្រហមបានក្លាយជា "ឪពុកម្ដាយ" ដល់អ្នកដែលត្រូវរៀបការ។

ផ្ទុយទៅវិញ ស្ត្រីជាច្រើនបានរៀបការជាមួយនឹងអ្នកដែលខ្លួនស្រឡាញ់ ហើយមានករណីជាច្រើនដែលឪពុកម្ដាយរបស់ស្ត្រីបានរៀបចំអាពាហ៍ពិពាហ៍របស់ពួកគេនៅក្នុងរបបខ្មែរក្រហម ដោយមានការយល់ព្រមពីពួកខ្មែរក្រហម។ រឿងរ៉ាវប្រភេទនោះជាច្រើនត្រូវបានចងក្រងជាឯកសារក្នុងការស្រាវជ្រាវនេះ។ ស្ត្រីដែលជ្រើសរើសរៀបការនៅក្នុងរបបខ្មែរក្រហមបាននិយាយថា ពួកគេចង់រៀបការ ពីព្រោះការរៀបការ និងឋានៈជាភរិយាអាចធានាលក្ខខណ្ឌជីវភាពរស់នៅល្អប្រសើរជាងមុន ពួកគេអាចនៅជាមួយឪពុកម្ដាយចាស់ៗរបស់ពួកគេបាន ឬពួកគេចៀសផុតពីការងារហត្ថកម្មលំបាកៗ ដែលស្ត្រីនៅលីវត្រូវធ្វើឆ្ងាយពីឪពុកម្ដាយពួកគេ។ ដំណើរការនេះគឺស្ត្រីត្រូវដាក់ពាក្យសុំរៀបការជាមួយអនាគតស្វាមីរបស់ខ្លួនទៅពួកខ្មែរក្រហម ហើយបន្ទាប់មកខ្មែរក្រហមរៀបចំពិធីមង្គលការរួមគ្នាច្រើន។ ជាទូទៅ សមាជិកគ្រួសារមិនបានចូលរួមពិធីមង្គលការភាគច្រើន ប៉ុន្តែខ្លះត្រូវបានអនុញ្ញាត។ ក្នុងករណីមួយចំនួន គ្រួសារបានទទួលទានអាហារពិសេសសម្រាប់មង្គលការ ដូចជាបង្អែមជាដើម។

**ការមានផ្ទៃពោះ និងការសម្រាលកូន**

នៅក្នុងការស្រាវជ្រាវនេះ ស្ត្រី ៦៦ នាក់ (N=១២១, ៥៥%) ដែលយើងជួប បានសម្រាលកូន និងបុរស ៣៨ នាក់ (N=១០៤, ៣៧%) ដែលបានក្លាយជាឪពុកក្នុងអំឡុងរបបខ្មែរក្រហម។ ស្ត្រីទាំងអស់ដែលខ្ញុំបានជួប (N=៥៤) បានរាយការណ៍ថា ពួកគេមិនសប្បាយចិត្តទេខណៈពួកគេមានផ្ទៃពោះក្នុងរបបខ្មែរក្រហម។ ពួកគេមិនចង់មានផ្ទៃពោះទេ។ ស្ត្រីជាច្រើននាក់មានផ្ទៃពោះនៅពេលខ្មែរក្រហមឡើងកាន់អំណាច និងជាច្រើនទៀតក៏មានផ្ទៃពោះក្នុងអំឡុងរបបខ្មែរក្រហមផងដែរ។ ស្ត្រីមានផ្ទៃពោះត្រូវគេបង្ខំឱ្យធ្វើការដូចជាស្ត្រីផ្សេងទៀតដែរ ហើយពួកគេទទួលបានបបរតែក្នុងចំណែកស្មើគ្នាប៉ុណ្ណោះ គឺតិចខ្លាំងណាស់។ ក្នុងករណីភាគច្រើន ស្ត្រីទាំងនោះកំពុងរស់នៅឆ្ងាយពីប្ដី ដែលជាអ្នកអាចជួយទាំងផ្លូវកាយ និងផ្លូវចិត្តក្នុងអំឡុងពេលមានផ្ទៃពោះ។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

ស្ត្រីស្ទើរតែទាំងអស់ដែលមានផ្ទៃពោះក្នុងអំឡុងពេលរបបខ្មែរក្រហម មានភាពភ័យខ្លាច ព្រោះពួកគេមិនដឹងថាត្រូវចិញ្ចឹមកូនដោយរបៀបណា នៅពេលពួកគេគ្មានអាហារបរិភោគនោះ។ គ្មានការអនុញ្ញាតឱ្យសម្រាកទេ នៅពេលពួកគេមានអាការៈចាញ់កូននោះ។ គ្មានថ្នាំផ្តល់ឱ្យឡើយ មានតែថ្នាំបុរាណមួយចំនួនដែលឪពុកម្តាយ ឬប្តីរបស់ខ្លួនព្យាយាមផ្សំជាមួយនឹងឫសឈើខ្លះៗពីព្រៃប៉ុណ្ណោះ។

ស្ត្រីជាច្រើនបានរលូតកូន ប្រហែលជាមកពី ដូចលោកស្រី ញ៉ែត ណេន [Nhaet Nen] អាយុ ៦២ ឆ្នាំ បាននិយាយថា៖ *"យើងត្រូវគេបង្ខំឱ្យធ្វើការធ្ងន់ណាស់រហូតដល់យើងរលូតកូនដោយស្វ័យប្រវត្តិតែម្តង"*[៧]។ ស្ត្រីម្នាក់បានក្លាយជាពិការជាអចិន្ត្រៃយ៍ដោយសារតែការរលូតកូនក្នុងអំឡុងរបបខ្មែរក្រហម ពោលគឺគ្មានការព្យាបាលត្រឹមត្រូវណាត្រូវបានផ្តល់ដល់នាងឡើយ។

ក្នុងអំឡុងពេលមានផ្ទៃពោះ ស្ត្រីដែលត្រៀមខ្លួនជាម្តាយជាច្រើនបានជួបប្រទះនឹងការស្លាប់សមាជិកគ្រួសាររបស់ខ្លួន មើលឃើញផ្ទាល់ភ្នែកនូវអំពើទារុណកម្ម ឬការសម្លាប់មនុស្ស ហើយពួកគេត្រូវបានបង្ខំឱ្យរស់នៅក្រោមសម្ពាធយ៉ាងខ្លាំងដើម្បីរស់រានមានជីវិត ខណៈពេលទារកកំពុងលូតលាស់ក្នុងខ្លួនរបស់ពួកគេ។

**ជីវិតពេលមានកូន**

ស្ត្រីជាច្រើនមានកូនរួចទៅហើយមុនរបបខ្មែរក្រហម ហើយជាច្រើនទៀតក៏ទើបនឹងក្លាយជាម្តាយជាលើកដំបូងផងដែរក្នុងអំឡុងរបបខ្មែរក្រហម។ បទពិសោធន៍ជាម្តាយក្នុងអំឡុងពេលសង្គ្រាមត្រូវបានលាបពណ៌ដោយភាពវេទនាគ្មានទីបញ្ចប់ និងការរងទុក្ខលំបាក។ ពេលម្តាយមានកូន ជាញឹកញាប់ ប្តីនៅធ្វើការពលកម្មឆ្ងាយៗ។ ម្តាយត្រូវគេទុកឱ្យនៅចិញ្ចឹមបីបាច់កូនតែម្នាក់ឯង។ នៅពេលពួកគេបានឃើញមុខកូនតូចៗរបស់ខ្លួននៅពេលយប់បន្ទាប់ពីធ្វើការងារពេញមួយថ្ងៃ ពួកគេមានអារម្មណ៍រីករាយ និងស្រាក_ស្រាន្តចិត្ត។ កូនៗរបស់ពួកគេអាចជាកម្លាំងចិត្តតែមួយគត់ដើម្បីឱ្យម្តាយតស៊ូរស់តទៅទៀត។

ទោះជាយ៉ាងណា ជីវិតរបស់ម្តាយមានការលំបាកយ៉ាងខ្លាំង។ ពួកគេត្រូវរងគ្រោះដោយសារភាពអត់ឃ្លានបន្ទាប់ពីធ្វើការងារលំបាកៗ។ គ្មានអាហារដែលមានជាតិប្រូតេអ៊ីន ឬសារធាតុចិញ្ចឹមសម្រាប់ទារកដែលស្រេកឃ្លានរបស់ខ្លួនឡើយ មានតែទឹកដោះម្តាយ ឬបបររាវៗតិចតួចប៉ុណ្ណោះ។ ទឹកដោះម្តាយមិនអាចមានគ្រប់គ្រាន់ដើម្បីចិញ្ចឹមទារកបានទេ ព្រោះម្តាយក៏ខ្វះអាហារូបត្ថម្ភដែរ។ ស្ថានភាពនេះកាន់តែយ៉ាប់ទៅទៀតនៅពេលម្តាយមានកូនផ្សេងទៀតបន្ថែមពីលើកូនតូចនេះ។ ដោយសារតែភាពអត់ឃ្លាន ជំងឺ ឬការវាយប្រយុទ្ធគ្នា ស្ត្រីជាច្រើនបានបាត់បង់កូនរបស់ខ្លួននៅក្នុងសង្គ្រាម។

ប្រសិនបើក្មេងបានអាយុចាប់ពីប្រាំឆ្នាំឡើង ពួកខ្មែរក្រហមបានយកពួកគេទៅធ្វើការនៅក្នុងកងកុមារ ឬកងយុវជន ហើយស្ត្រីជាម្តាយមិនត្រូវបានអនុញ្ញាតឱ្យជួបកូនរបស់ខ្លួនជាច្រើនខែ ពេលខ្លះជាច្រើនឆ្នាំផងដែរ។ លោកស្រី ស រ៉ុន [Sar Ron] អាយុ ៦៣ ឆ្នាំ បាននិយាយថា៖ *"ក្មេងៗជាច្រើនទាក់ឈឺដោយសារពួកគេមិនបានហូបអាហារគ្រប់គ្រាន់។ ក្មេងជាច្រើនបានស្លាប់។ ភាគច្រើន ពួកគេត្រូវបានមើល*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*ផែទាំដោយស្ត្រីវ័យចំណាស់ៗដែលខ្មែរក្រហមចាត់ឱ្យ។ ក្មេងៗអាចរស់បានមួយថ្ងៃ ប៉ុន្តែអាចស្លាប់បាននៅថ្ងៃបន្ទាប់។ ទោះជាពួកគេនៅរស់ក្តី ពួកគេធំឡើងក្នុងស្ថានភាពអាក្រក់។ ក្មេងខ្លះធំឡើងដោយមិនស្គាល់ឪពុកម្តាយរបស់ខ្លួន ដោយសារឪពុកម្តាយរបស់ខ្លួនបានស្លាប់ ឬត្រូវគេសម្លាប់បាត់ទៅហើយ”*[៨]។ នៅពេលក្មេងមានអាយុលើសពី ១៥ ឆ្នាំ ពួកគេត្រូវបានកេណ្ឌឱ្យធ្វើការនៅក្នុងកងយុវជន តែនៅតែបង្ខំឱ្យនៅឆ្ងាយពីម្តាយដដែល។

មានស្ត្រីម្នាក់នៅក្នុងការស្រាវជ្រាវនេះដែលកូនប្រុសរបស់ខ្លួនត្រូវគេបង្ខំឱ្យរៀបការ ហើយគាត់បានក្លាយជាជីដូនគេ នៅក្នុងអំឡុងរបបខ្មែរក្រហម។ សិស្សរបស់ខ្ញុំ លោកស្រី លីនដា [Linda] ក៏បានសម្ភាសជីតារបស់គាត់ដែលបានប្រាប់គាត់ថា កូនប្រុសគាត់ម្នាក់ (ពូរបស់ លីនដា [Linda]) ត្រូវគេបង្ខំឱ្យរៀបការក្នុងអំឡុងរបបខ្មែរក្រហមនេះ។ ការស្រាវជ្រាវនេះមិនបានផ្តោតលើទំហំនៃការព្រួយបារម្ភរបស់ម្តាយអំពីសុវត្ថិភាព និងសុភមង្គលរបស់កូនម្នាក់ៗឡើយ ប៉ុន្តែផ្តោតជាចម្បងលើទុក្ខលំបាក និងក្តីកង្វល់របស់ម្តាយដែលមានកូនង៉ា និងកូនតូចៗដែលបានកើតក្នុងអំឡុងរបបខ្មែរក្រហម។

**ការស្លាប់របស់កូន**

ស្ត្រីជាច្រើនបានបាត់បង់កូនរបស់ខ្លួនក្នុងអំឡុងរបបខ្មែរក្រហម។ ស្ត្រីដែលយើងបានសម្ភាសបានយំយ៉ាងខ្លាំងនៅពេលពួកគេនិយាយអំពីការស្លាប់របស់កូនពួកគេ។ ការមានផ្ទៃពោះគឺជាការលំបាកណាស់ទៅហើយ តែការមើលឃើញកូនរបស់ខ្លួនស្លាប់គឺកាន់តែពិបាកខ្លាំងណាស់ទៅទៀត។ ស្ត្រីពីរនាក់បានបាត់បង់កូនក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីកើត រីឯស្ត្រី ៩ នាក់បានបាត់បង់កូនក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីកើត។ គ្មាននរណាម្នាក់នៅក្នុងការសិក្សានេះបានរាយការណ៍ថា ពួកខ្មែរក្រហមបានសម្លាប់កូនរបស់ខ្លួនដោយចេតនាទេ ប៉ុន្តែស្ត្រីទាំងនោះពិតជាបានដឹងពីករណីដែលក្មេងៗត្រូវបានពួកខ្មែរក្រហមយកទៅទាំងសម្លាប់ក្តី ឬមិនដែលវិលត្រឡប់មកវិញក្តី។

ស្ត្រីភាគច្រើនបាននិយាយថា ពួកគេបានទទួលរងទុក្ខយ៉ាងខ្លាំងនៅពេលពួកគេបាត់បង់កូន។ ចំនួនកូនដែលបាត់បង់ច្រើនបំផុតរបស់ស្ត្រីម្នាក់ដែលយើងសម្ភាស គឺ ៦ នាក់។ គាត់បានរំលឹកពីការស្លាប់ម្នាក់ៗយ៉ាងច្បាស់ និងចែករំលែករឿងសោកសង្រេងទាំងនោះ។ ផ្ទុយទៅវិញ ស្ត្រីមួយចំនួននិយាយថា ពួកគេមិនមានអារម្មណ៍ថាសោកសង្រេងនោះទេ ព្រោះពួកគេលំបាកវេទនាពេកហើយ ហើយពួកគេត្រូវគិតថាត្រូវធ្វើយ៉ាងឱ្យខ្លួនឯងមានជីវិតរស់។

**អ្នកចូលរួមក្នុងការស្រាវជ្រាវ**

ក្នុងអំឡុងពេលនៃការស្រាវជ្រាវនេះ ចាប់ពីខែ មីនា ដល់ខែ កក្កដា ឆ្នាំ ២០១៥ ស្ត្រីចំនួន ១២១ នាក់ត្រូវបានសម្ភាស (អាយុជាមធ្យម ៦៥ ឆ្នាំ)[៩]។ ក្នុងចំណោមពួកគេ ខ្ញុំបានជួបជាមួយស្ត្រីចំនួន ៥៤ នាក់ដែលបានសម្រាលកូនក្នុងអំឡុងរបបខ្មែរក្រហម។ បុរសចំនួន ១០៤ នាក់ក៏ត្រូវបានសម្ភាសផងដែរ (អាយុ

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

ជាមធ្យម ៦៣ ឆ្នាំ) ហើយបុរស ៣៨ នាក់ក្នុងចំណោមនោះ បានក្លាយជាឪពុកគេក្នុងអំឡុងរបបខ្មែរក្រហម។

ជាសំណាងល្អ ខ្ញុំបានជួបជាមួយឆ្មបដែលមានជំនាញវិជ្ជាជីវៈក្នុងអំឡុងរបបខ្មែរក្រហមម្នាក់ នៅក្នុងខេត្តព្រៃវែង។ គាត់ចិត្តល្អក្នុងការចែករំលែកបទពិសោធន៍ដែលគាត់បានក្លាយជាឆ្មបមុនរបបខ្មែរក្រហម និងបានរៀបរាប់ពីការងារជាឆ្មបរបស់គាត់ក្នុងអំឡុងពេលសង្គ្រាម និងថាតើជីវិតរបស់ស្ត្រីត្រៀមខ្លួនជាម្តាយមានភាពលំបាកយ៉ាងណាក្នុងអំឡុងពេលមានជម្លោះនោះ។

ដោយលើកលែងស្ត្រី ៨ នាក់ និងបុរសម្នាក់ សិស្សរបស់ខ្ញុំបានចូលរួមក្នុងបទសម្ភាន៍ទាំងអស់។ ពួកគេបានទទួលការបណ្តុះបណ្តាលពីរបៀបធ្វើបទសម្ភាសន៍ អនុវត្តតាមកម្រងសំណួរសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ និងត្រូវបានផ្តល់ការណែនាំស្តីពីការស៊ើបអង្កេតលើបញ្ហាពិសេសៗមួយចំនួនដែលស្ត្រីទាំងនោះសំដៅដល់។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

### ទីតាំងនៃការស្រាវជ្រាវ

បទសម្ភាសន៍ត្រូវបានធ្វើឡើងនៅក្នុងខេត្តចំនួន ៦ នៅក្នុងប្រទេសកម្ពុជា ដោយគ្របដណ្តប់លើឃុំចំនួន ១០ ផ្សេងគ្នា៖ ខេត្តសៀមរាប ( ៣ ភូមិ) កំពង់ចាម (១ ភូមិ) បាត់ដំបង (១ ភូមិ) ព្រៃវែង (២ ភូមិ) តាកែវ (៣ ភូមិ) និងរតនគិរី។ បទសម្ភាសន៍មួយត្រូវបានធ្វើឡើងនៅក្នុងទីក្រុង Montreal ប្រទេសកាណាដា។ ស្ត្រីទាំងអស់ដែលបានសម្ភាសនៅក្នុងខេត្តរតនគិរី (១ ភូមិ) គឺជាជនទេសន្តរប្រវេសន៍ មកពីបណ្តាខេត្តនៅក្បែរនោះ។ នៅក្នុងខេត្តផ្សេងៗទៀត ស្ត្រីដែលបានចូលរួម រស់នៅក្នុងខេត្តដដែលនេះតាំងពីកើតមក។

រឿងរ៉ាវ និងបទពិសោធន៍របស់ស្ត្រីមកពីខេត្តនីមួយៗគឺផ្សេងៗគ្នា ហើយឥទ្ធិពលនៃសង្គ្រាម និងជម្លោះផ្ទៃក្នុងបានជះផលប៉ះពាល់ដល់ជីវិតរបស់ស្ត្រីក្នុងរូបភាពជាច្រើន។ ដូចគ្នានេះផងដែរ សូម្បីតែនៅក្នុងខេត្តមួយ អាស្រ័យលើទីតាំងនៅក្នុងខេត្តនោះ បទពិសោធន៍នៃជម្លោះគឺផ្សេងៗគ្នា។ ឧទាហរណ៍ នៅខេត្តបាត់ដំបង ស្ត្រីជាច្រើនបាននិយាយថា នៅក្នុងតំបន់ ៣ ជីវិតមានភាពលំបាកជាងតំបន់ ៤។ នៅខេត្តព្រៃវែង និងតាកែវ បទពិសោធន៍ស្រដៀងគ្នាត្រូវបានចែករំលែក។ នៅខេត្តសៀមរាប រតនគិរី កំពង់ចាម និងតំបន់ភាគព្លៃសានផ្សេងៗទៀត រដ្ឋាភិបាលកុម្មុយនីស្តបានកាន់កាប់រួចទៅហើយ មុនពេលខ្មែរក្រហមឡើងកាន់អំណាចជាផ្លូវការនៅឆ្នាំ ១៩៧៥ ដោយសារតែមានមូលដ្ឋានយោធាខ្មែរក្រហមនៅទីនោះ។

### ការបកប្រែ និងសេចក្តីពន្យល់

សំឡេងរបស់ស្ត្រីត្រូវបានថតទុកជាខ្សែអាត់ទាំងអស់ ហើយសិស្សរបស់ខ្ញុំបានធ្វើការបកប្រែពីបទសម្ភាសន៍ទាំងនោះ។ ខ្ញុំមានធ្វើការពិភាក្សាជាច្រើនជាមួយនឹងសិស្សរបស់ខ្ញុំអំពីការបកប្រែគ្រាមភាសា និងឃ្លាពិបាកខ្លះៗជាភាសាខ្មែរ។ ឧទាហរណ៍ ពាក្យខ្មែរ *"ធម្មតា"* ដែលមានន័យថា "ធម្មតា" ត្រូវបានគេប្រើម្តងហើយម្តងទៀតនៅក្នុងកាលៈទេសៈផ្សេងគ្នាជាច្រើន ហើយយើងព្យាយាមវិភាគថា តើពាក្យ "ធម្មតា" នេះមានន័យដូចម្តេច។ ឧទាហរណ៍ ស្ត្រីជាច្រើនបាននិយាយថា ពួកគេមានអារម្មណ៍ *"ធម្មតា"* នៅពេលពួកគេរៀបការ ឬនៅពេលយើងសួរអំពីជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ។ ប៉ុន្តែ នៅតែមានឃ្លារសើបមួយចំនួនទៀតដែលប្រហែលជាមិនបានបកប្រែត្រឹមត្រូវ។ នៅក្នុងបទសម្ភាសន៍នីមួយៗ ស្ត្រីបាននិយាយរឿងច្រើន។ ស្ត្រីភាគច្រើនមិនបាននិយាយតាមកាលប្បវត្តិទេ ពួកគេរំលឹកពីឧប្បត្តិហេតុមួយចំនួនខណៈពេលពួកគេកំពុងនិយាយអំពីអ្វីមួយផ្សេងទៀត។ ដូច្នេះ ខ្ញុំបានកែសម្រួលពាក្យសម្ដីរបស់ពួកគេឱ្យត្រូវតាមកាលប្បវត្តិដើម្បីឱ្យអ្នកអានងាយយល់។ ស្ត្រីទាំងអស់សុទ្ធតែបានផ្តល់ការអនុញ្ញាត ហើយពួកគេបានយល់ព្រមឱ្យគេ_បើកចំហរឿងរ៉ាវរបស់ពួកគេជាសាធារណៈ រួមទាំងរូបថតផងដែរ។

សៀវភៅនេះគឺការប្រមូលផ្តុំសម្លេងស្ត្រី។ ប៉ុន្តែ អ្នកអានក៏នឹងជួបប្រទះប្រយោគជាច្រើនដែលចាប់ផ្តើមដោយពាក្យ "ខ្ញុំ" ដែលតំណាងឱ្យអ្នកនិពន្ធ។ ប្រការនេះពេលខ្លះអាចនឹងភាន់ច្រឡំ ប៉ុន្តែ ខ្ញុំជឿថា

Deleted: កំណត់ចំណាំបែប

Deleted: សម្លេង

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

ព័ត៌មានជាសារតាបន្ថែមមួយចំនួន ឬការវិភាគរបស់ខ្ញុំជាមួយសិស្ស និងមិត្តភក្តិ អាចនឹងជួយឲ្យអ្នកអានយល់បានកាន់តែប្រសើរអំពីបរិបទនៃអ្វីដែលកំពុងត្រូវបានរៀបរាប់។

**ជំពូកនៃសៀវភៅ**

សៀវភៅនេះត្រូវបានសរសេរឡើងតាមកាលប្បវត្តិ។

បទពិសោធន៍របស់ស្ត្រីត្រូវបានចែករំលែកតាំងពីពេលមុនរបបខ្មែរក្រហម។ ស្ត្រីខ្លះមានឯកសិទ្ធិទៅសិក្សានៅតាមស្ថាប័នសិក្សាខ្ពស់មុនសង្គ្រាម រីឯខ្លះទៀតបានរៀបការ និងមានកូនច្រើនទៀតទៅហើយ។ ដូច្នេះ សៀវភៅនេះបន្តស្វែងរកបទពិសោធន៍របស់ស្ត្រីនៅដើមដំបូងនៃរបបខ្មែរក្រហម បន្ទាប់មក ការមានផ្ទៃពោះ និងការសម្រាលកូនក្នុងអំឡុងរបបខ្មែរក្រហម។ ស្ត្រីចែករំលែករឿងរ៉ាវរបស់ខ្លួនបន្ទាប់ពីការរំដោះនៅខែ មករា ឆ្នាំ ១៩៧៩ ខ្លះបាននិយាយអំពីជីវិតរបស់ខ្លួននៅក្នុងជំរំជនភៀសខ្លួន និងការតស៊ូដើម្បីរស់សូម្បីតែនៅក្រោយរបបខ្មែរក្រហមបានបញ្ចប់ក្តី។ រឿងរ៉ាវទាំងនេះបានបន្តអស់រយៈពេលជាច្រើនទសវត្សរ៍។ មុនពេលបទពិសោធន៍តាមកាលប្បវត្តិត្រូវបានចែករំលែក ខ្ញុំសូមចាប់ផ្តើមជាមួយនឹងរឿងរបស់លោកស្រី ចាន់ សារឿន [Chan Sareoun] ដើម្បីចាប់ផ្តើមជាឧទាហរណ៍ធម្មតាមួយនៃរឿងរ៉ាវជីវិតរបស់ស្ត្រី។

**រឿងរ៉ាវរបស់លោកស្រី ចាន់ សារឿន មកពីខេត្តរតនគិរី**[១០]

លោកស្រី ចាន់ សារឿន [Chan Sareoun] អាយុ ៧៧ ឆ្នាំ បានរៀបការជាមួយទាហានខ្មែរក្រហមម្នាក់។ គាត់មានស្រុកកំណើតនៅខេត្តតាកែវ។ គាត់បានបាត់បង់ឪពុកម្តាយនៅពេលគាត់មាន កូនម្នាក់។ គាត់គឺជាកុមារកំព្រាម្នាក់ក្នុងចំណោមកុមារកំព្រាជាច្រើនដែលត្រូវបានសម្ភាស។ ក្នុងចំណោម ស្ត្រី ៥៤ នាក់ដែលខ្ញុំបានជួប គាត់គឺជាស្ត្រីតែម្នាក់គត់ដែលបានស្នើសុំបញ្ចប់បទសម្ភាសន៍មុនពេលសំណួរទាំងអស់ត្រូវបានសួរ។ បន្ទាប់ពីគាត់យំ ហើយឈប់ពេលខ្លះ ទីបំផុតគាត់និយាយថា៖ “បទពិសោធន៍របស់ខ្ញុំគឺជូរចត់ជាងគេបំផុតក្នុងចំណោមស្ត្រីទាំងអស់។ គ្មានស្ត្រីណារងទុក្ខគ្មានខ្ញុំនោះទេ។ ខ្ញុំមិនចង់និយាយអំពីរឿងនេះទៀតទេ”។

*នៅក្នុងបទសម្ភាសន៍ គាត់បានញញឹមពព្រាយម្តង នៅពេលគាត់និយាយអំពីការធ្វើដំណើរទៅកាន់ខេត្តតាកែវកាលពីឆ្នាំមុន។ គាត់បានទៅលេងសាច់ញាតិខាងប្តីរបស់គាត់ដែលកំពុងរស់នៅក្នុងខេត្តតាកែវ។ វាគឺជាដំណើរដ៏រីករាយមួយសម្រាប់ការជួបជុំក្រុមគ្រួសារ។*

*ខ្ញុំបានធំឡើងជាក្មេងកំព្រា ហើយយើងបានរស់នៅក្នុងខេត្តតាកែវមុនពេលរបបខ្មែរក្រហម។ ម្តាយខ្ញុំបានស្លាប់នៅពេលខ្ញុំទើបនឹងបានអាយុ ៣ ឆ្នាំប៉ុណ្ណោះ ហើយឪពុកខ្ញុំបានស្លាប់នៅពេលខ្ញុំអាយុ ១២ ឆ្នាំ។ បងស្រីខ្ញុំបានរ៉ាប់រងទំនួលខុសត្រូវជំនួសឪពុកម្តាយខ្ញុំ។ គាត់មើលថែខ្ញុំ និងបងប្អូនខ្ញុំ ៧ នាក់ផ្សេងទៀត។ ឪពុកម្តាយខ្ញុំជាកសិករទាំងពីរនាក់ ហើយយើងក្រីក្រណាស់។ ខ្ញុំមិនបានចូលសាលារៀនទេ ដោយសារតែ*

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

*ភាពក្រីក្រ ហើយយើងស្ទើរតែគ្មានអ្វីបរិភោគ។ ដូច្នេះ ការចូលសាលារៀនគឺគ្រាន់តែជាក្តីសុបិនមួយប៉ុណ្ណោះសម្រាប់ពួកយើង។ ប៉ុន្តែ ខ្ញុំគឺជាក្មេងឆ្លាត ទោះជាខ្ញុំមិនចេះសរសេរ និងមិនចេះអានក្តី។*

*នៅពេលខ្ញុំបានអាយុ ១៩ ឆ្នាំ មុនពេលរបបខ្មែរក្រហមចូលកាន់អំណាច បងស្រីខ្ញុំបានរៀបចំឱ្យខ្ញុំរៀបការជាមួយបុរសម្នាក់ដែលរស់នៅក្នុងខេត្តជាមួយគ្នា (ខេត្តតាកែវ) ប៉ុន្តែស្រុកផ្សេងគ្នា។ ខ្ញុំបានជួបប្តីខ្ញុំនៅថ្ងៃរៀបមង្គលការរបស់យើង ហើយខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តនឹងរៀបការទេ ប៉ុន្តែតើខ្ញុំអាចធ្វើអ្វីបាន? ប៉ុន្តែ ខ្ញុំយល់ចិត្តបងស្រីខ្ញុំ។ ខ្ញុំដឹងថា គាត់ត្រូវតែធ្វើបែបនេះចំពោះខ្ញុំ។ គាត់ត្រូវផ្គត់ផ្គង់ និងមើលថែបងប្អូនផ្សេងៗទៀតរបស់យើង។ បន្ទាប់ពីខ្ញុំបានរៀបការជាមួយប្តីខ្ញុំមក យើងបានរស់នៅក្នុងផ្ទះឪពុកម្តាយក្មេករបស់ខ្ញុំ។ ប្តីខ្ញុំគឺជាមនុស្សល្អ គាត់មិនលេងល្បែង ឬផឹកស្រាទេ។ យើងត្រូវបានប្រទានពរដោយមានកូនពីរនាក់នៅមុនរបបខ្មែរក្រហម។*

*ពេលខ្មែរក្រហមកាន់កាប់ក្នុងតំបន់របស់ខ្ញុំ នៅឆ្នាំ ១៩៧៥ ពួកគេបានបញ្ជាឱ្យទាហាន និងជនស៊ីវិលស្លៀកពាក់ឈុតពណ៌ខ្មៅ កាត់សក់ឱ្យខ្លីដូចមនុស្សប្រុស។ ទ្រព្យសម្បត្តិរបស់យើងក៏ត្រូវបានរឹបអូសផងដែរ។ នៅពេលនោះ ខ្ញុំមានផ្ទៃពោះប្រាំមួយខែ ខ្ញុំបានរត់ចេញជាមួយកូនពីរនាក់របស់ខ្ញុំទៅជាយខេត្តតាកែវ ប៉ុន្តែប្តីរបស់ខ្ញុំបានក្លាយជាទាហាន ហើយគាត់ចាំបាច់ត្រូវចូលរួមភារកិច្ចរបស់ខ្លួន និងអនុវត្តតាមបទបញ្ជារបស់អ្នកដឹកនាំ។ ប្តីរបស់ខ្ញុំអាចមកលេងយើងតែពីរដងប៉ុណ្ណោះក្នុងមួយខែ ហើយគាត់អាចនៅជាមួយខ្ញុំ និងកូន បី ឬបួនថ្ងៃ។ គាត់ចិត្តល្អ និងទន់ភ្លន់ណាស់នៅពេលណាដែលយើងជួបគ្នា។*

*ជីវិតរបស់យើងក្នុងរបបខ្មែរក្រហមពិតជាលំបាកណាស់ យើងភ័យខ្លាចជាប់រហូត និងរស់នៅក្រោមភាពភ័យខ្លាចថានឹងត្រូវគេសម្លាប់។ យើងទាំងអស់គ្នាត្រូវគេបង្ខំឱ្យធ្វើការដោយផ្ទុយនឹងឆន្ទៈរបស់យើង។ សូម្បីតែនៅពេលខ្ញុំមានផ្ទៃពោះប្រាំមួយខែទៅហើយក្តី ខ្ញុំនៅតែត្រូវធ្វើការដូចអ្នកផ្សេងទៀតដែរ។ ប៉ុន្តែ ពួកខ្មែរក្រហមមិនធ្វើអាក្រក់ដាក់ខ្ញុំខ្លាំងនោះទេ ដូច្នេះ ខ្ញុំធ្វើតាមសម្រួលនៅពេលណាដែលត្រូវសម្រាក ឬចាំរហូតដល់ខ្ញុំបញ្ចប់កិច្ចការរបស់ខ្ញុំ។ ប៉ុន្តែ ខ្ញុំពេញចិត្តនឹងបញ្ចប់កិច្ចការរបស់ខ្ញុំជាង សម្រាប់ខ្ញុំ ការធ្វើការងារច្រើនមិនមែនជារឿងអាក្រក់ពេកទេ ប៉ុន្តែអ្វីដែលពិបាកបំផុតនោះគឺត្រូវនៅឆ្ងាយ ឬរស់នៅបែកពីប្តីរបស់ខ្ញុំ។ រួមនឹងកូនតូចពីរនាក់ ហើយខ្ញុំមានផ្ទៃពោះ ខ្ញុំមានអារម្មណ៍ថា ពិបាកនឹងរ៉ាប់រងណាស់។*

*ខ្ញុំមានផ្ទៃពោះពីរដងក្នុងអំឡុងរបបខ្មែរក្រហម និងមានកូនប្រុស ២ នាក់។ ពួកគេឈ្មោះ ផន និង រស្មី។ នៅមុនរបបខ្មែរក្រហម ខ្ញុំមានកូនពីរនាក់រួចហើយ ដូច្នេះជាសរុប ខ្ញុំមានកូន ៤ នាក់។ នៅពេលខ្ញុំពរពោះកូនប្រុសរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាឈឺ ខ្ញុំចាញ់ ក្បាលរបស់ខ្ញុំវិល ហើយពេលខ្លះខ្ញុំមានអារម្មណ៍ថាពោះរបស់ខ្ញុំឡើងរឹង ហើយខ្ញុំពិតជាមិនចង់ធ្វើអ្វីនោះឡើយ។ ប៉ុន្តែ ដើម្បីរស់ យើងត្រូវតែធ្វើតាមបញ្ជារបស់ខ្មែរក្រហម និងត្រូវធ្វើកិច្ចការគ្រប់យ៉ាងដែលគេណែនាំឱ្យយើងធ្វើ។ ខ្ញុំមិនចង់ចេញពីផ្ទះឡើយដោយសារតែអាការៈចាញ់កូននេះ ប៉ុន្តែពួកខ្មែរក្រហមបានបង្ខំឱ្យខ្ញុំទៅធ្វើការ។ គ្មានថ្នាំដើម្បីបន្ថយការឈឺចាប់របស់ខ្ញុំ*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

ទេ។ យើងត្រូវស៊ូទ្រាំនឹងជីវិតជូរចត់ និងលំបាកបែបនេះក្នុងអំឡុងរបបខ្មែរក្រហម អ្វីគ្រប់យ៉ាងក៏ត្រូវបានដាក់កម្រិតផងដែរ ហើយយើងមានធ្វើតាមច្បាប់របស់ខ្មែរក្រហម។

នៅពេលខ្ញុំកើតកូនទី ៣ ប្ដីរបស់ខ្ញុំនៅទីនោះជាមួយខ្ញុំ។ ខ្ញុំកើតនៅផ្ទះ ដោយសារតែគ្មានមន្ទីរពេទ្យណាបើកទេ។ ខ្ញុំឈឺពោះបីម៉ោង បន្ទាប់មកខ្ញុំក៏បានកើតកូនប្រុសទីបីរបស់ខ្ញុំ។ ប្ដីរបស់ខ្ញុំនៅជាមួយខ្ញុំបាន ៧ ថ្ងៃ ហើយយើងគួរណាស់តែរីករាយដែលបានឃើញកូនដែលទើបនឹងកើតរបស់យើង។ ប៉ុន្តែ យើងហាក់ដូចជាគ្មានអារម្មណ៍រីករាយបន្តិចទាល់តែសោះ។ យើងមានអារម្មណ៍ពិបាកចិត្តយ៉ាងខ្លាំងពេលយើងឃើញកូន។ មូលហេតុគឺដោយសារតែយើងបានដឹងពីស្ថានភាពដែលយើងកំពុងស្ថិតនៅ។ ពេលនោះគឺមិនសមរម្យ ឬមិនមែនជាពេលល្អក្នុងការមានកូននោះទេ។ ខ្ញុំខ្លាចថា ខ្ញុំនឹងមិនអាចមើលថែកូនរបស់ខ្ញុំឬមិនអាចចិញ្ចឹមកូនឱ្យបានត្រឹមត្រូវ។ គឺដោយសារ ខ្ញុំដឹងថា ខ្ញុំមិននៅផ្ទះមើលថែកូនបាន។ ខ្ញុំក៏បានគិតអំពីអ្វីដែលពួកខ្មែរក្រហមនឹងនិយាយ ឬធ្វើ បើសិនខ្ញុំមិនត្រឡប់ទៅធ្វើការវិញ។ ពីរសប្ដាហ៍បន្ទាប់ពីសម្រាល ខ្ញុំនៅតែមានអារម្មណ៍ថាខ្សោយ និងមានអារម្មណ៍ថាឈឺ។ ខ្ញុំគិតថា អាការៈនេះគឺដោយសារតែខ្វះអាហារបរិភោគ និងគ្មានថ្នាំសម្រាប់លេបខ្លួនឯង។ ខ្ញុំមិនអាចទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់។ រូបកាយខ្ញុំត្រូវការអាហារូបត្ថម្ភ និងថ្នាំល្អៗបន្ទាប់ពីសម្រាលកូនរួច ប៉ុន្តែ ខ្ញុំមានតែថ្នាំបុរាណ ដូចជាឫសឈើ និងស្លឹកឈើតែប៉ុណ្ណោះ។ ខ្ញុំត្រូវត្រឡប់ទៅធ្វើការរបស់ខ្ញុំវិញ ដូចជាច្រូតស្រូវ បេះបន្លែ និងសម្អាតរបងគោ ខណៈពេលដែលកូនរបស់ខ្ញុំត្រូវបានចាស់ៗមើលថែជាមួយនឹងទារកផ្សេងទៀតនៅកន្លែងតែមួយ។

ខ្ញុំរីករាយណាស់នៅពេលដែលរបបខ្មែរក្រហមបានបញ្ចប់នៅក្នុងឆ្នាំ ១៩៧៩។ ប្ដីរបស់ខ្ញុំបានត្រឡប់មកវិញ ហើយយើងទាំងអស់គ្នាបានបន្តរស់នៅជាមួយគ្នាជុំគ្រួសារ ហើយយើងក៏មានកូនពីរនាក់បន្ថែមទៀត ដូច្នេះ ជាសរុបយើងមានកូន ៦ នាក់។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

[Chapter 3]

## ជំពូកទី ៣៖ អាពាហ៍ពិពាហ៍ និងការលែងលះនៅមុនរបបខ្មែរក្រហម

នៅក្នុងការស្រាវជ្រាវនេះ ស្ត្រី ៧៥ នាក់ (N=១២១, ៦២%) បានរៀបការរួចហើយនៅមុនរបបខ្មែរក្រហម។ យើងបានសួរថាតើអាពាហ៍ពិពាហ៍របស់ពួកគេត្រូវបានរៀបចំឡើងដោយរបៀបណា និងថាតើពួកគេមានអារម្មណ៍បែបណាចំពោះអាពាហ៍ពិពាហ៍របស់ពួកគេ។ ភាគច្រើន ឪពុកម្តាយ ឬចាស់ព្រឹទ្ធាចារ្យជាអ្នករៀបចំអាពាហ៍ពិពាហ៍ឲ្យស្ត្រី។ កត្តាគួរឲ្យចាប់អារម្មណ៍មួយគឺនៅដើមទសវត្សរ៍ឆ្នាំ ១៩៧០ ស្ត្រីជាច្រើនរៀបការ ដោយសារតែឪពុកម្តាយព្រួយបារម្ភអំពីសន្តិសុខរបស់ពួកគេ។

Deleted: ព្រឹទ្ធាចារ្យ

### ដំណើរការតាមប្រពៃណីសម្រាប់អាពាហ៍ពិពាហ៍

តាមប្រពៃណី អាពាហ៍ពិពាហ៍នៅក្នុងសង្គមកម្ពុជាត្រូវបានរៀបចំឡើងដោយចាស់ព្រឹទ្ធាចារ្យ ឬដោយឪពុកម្តាយ។ ព្រឹត្តិការណ៍នេះគឺជាព្រឹត្តិការណ៍សំខាន់ខ្លាំងណាស់សម្រាប់គ្រួសារ និងសាច់ញាតិរបស់ស្ត្រី ព្រោះគេចាត់ទុកគ្រួសារជាស្ថាប័នដ៏សំខាន់មួយនៅក្នុងសង្គម។ កូនខ្មែរភាគច្រើនធំឡើង និងរស់នៅជាមួយឪពុកម្តាយរបស់ពួកគេរហូតដល់រៀបអាពាហ៍ពិពាហ៍ ហេតុនេះ ការរៀបអាពាហ៍ពិពាហ៍របស់កូនគឺជាកាតព្វកិច្ចសំខាន់មួយរបស់ឪពុកម្តាយ។

កូនខ្មែរ ជាពិសេសកូនស្រីត្រូវគេរំពឹងថានឹងគោរព និងធ្វើតាមការសម្រេចចិត្តរបស់ឪពុកម្តាយរបស់ពួកគេ។ លោកស្រី ម៉ែន រ៉ុម [Maen Rom] អាយុ ៦៣ ឆ្នាំ បានថ្លែងថា៖ *"កូនគួរតែធ្វើតាមការសម្រេចចិត្តរបស់ឪពុកម្តាយខ្លួនចំពោះរឿងអាពាហ៍ពិពាហ៍ ព្រោះវាជាប្រពៃណីរបស់យើង។ កូនមានកាតព្វកិច្ចអនុញ្ញាតឲ្យឪពុកម្តាយគិតគូរ និងធ្វើការសម្រេចចិត្តអំពីអាពាហ៍ពិពាហ៍របស់ពួកគេ"*[៣០]។ កូនប្រុសក៏ត្រូវគេរំពឹងថាធ្វើតាមការសម្រេចចិត្តរបស់ឪពុកម្តាយខ្លួនដែរ ប៉ុន្តែពួកគេអាចផ្តួចផ្តើមដំណើរការអាពាហ៍ពិពាហ៍នេះបានដោយសាកសួរឪពុកម្តាយរបស់ខ្លួនអំពីការសម្រេចចិត្តរបស់ពួកគេ។ ទង្វើនេះនៅតែត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅក្នុងសង្គមកម្ពុជាដដែល។ កូនប្រុសមានសេរីភាពច្រើនជាង ឬអំណាចក្នុងការសម្រេចចិត្តខ្លាំងជាង ដើម្បីចាប់ផ្តើមយ៉ាងសកម្មមុននូវអាពាហ៍ពិពាហ៍ផ្ទាល់របស់ពួកគេ រីឯកូនស្រីនៅតែស្ថិតក្នុងតួនាទីអកម្មដដែល។

ឪពុកម្តាយរៀបចំអាពាហ៍ពិពាហ៍ឲ្យកូនស្រីតាមប្រពៃណី បានក្លាយជាផ្នត់គំនិត "ធម្មតា" ទៅហើយសម្រាប់ស្ត្រី។ ស្ត្រីភាគច្រើនដែលយើងសម្ភាសជឿថា ឪពុកម្តាយពួកគេនឹងស្វែងរកអនាគតប្តីឲ្យពួកគេ និងកូនស្រីគួរតែនៅឲ្យឆ្ងាយពីប្រុសៗរហូតដល់ពេលរៀបអាពាហ៍ពិពាហ៍។ លោកស្រី ប៉ែន យ៉េត [Pen Yet] អាយុ ៧៨ ឆ្នាំ មានរដូវដំបូងនៅអាយុ ១៥ ឆ្នាំ ឪពុកម្តាយរបស់គាត់បានរៀបចំអាពាហ៍ពិពាហ៍ឲ្យគាត់ភ្លាម[៣១]។ អ្វីដែលគួរអោយភ្ញាក់ផ្អើលនោះ មានស្ត្រីដែលមានរដូវដំបូងនៅក្រោយរៀបអាពាហ៍ពិពាហ៍រួចដែលបង្ហាញពីអំណាចសម្រេចចិត្តរបស់ឪពុកម្តាយលើអាពាហ៍ពិពាហ៍របស់កូនស្រីខ្លួន។

Deleted:

Deleted:

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

លោកស្រី មួន ជប់ [Mouon Chob] អាយុ ៧១ ឆ្នាំ ក៏បានចែករំលែកទស្សនៈទូទៅដែលឪពុកម្ដាយគួរតែរៀបចំអាពាហ៍ពិពាហ៍ឱ្យកូនស្រីផងដែរ[៣២]។

*ខ្ញុំចង់រៀបការជាមួយបុរសដែលឪពុកម្ដាយខ្ញុំបានជ្រើសរើស និងរៀបចំឱ្យ ជាជាងជាមួយមនុស្សដែលខ្ញុំជ្រើសរើស។ ខ្ញុំរង់ចាំ និងព្យាយាមយល់ព្រមជាមួយការផ្ដល់យោបល់ពីសំណាក់ឪពុកម្ដាយខ្ញុំ។ ខ្ញុំមិនដែលគិតថាចង់មានស្នេហាដោយគ្មានការអនុញ្ញាតពីឪពុកម្ដាយខ្ញុំទេ។*

ចំពោះកូនស្រី ជារឿងសំខាន់ណាស់ដែលពួកគេសងគុណឪពុកម្ដាយរបស់ពួកគេដោយទឹកចិត្តស្មោះសក្រោមទម្រង់ជាអាពាហ៍ពិពាហ៍ដែលជោគជ័យ ហើយមានតែឪពុកម្ដាយប៉ុណ្ណោះ ជាជាងខ្លួនឯង អាចរៀបចំអាពាហ៍ពិពាហ៍ឱ្យបានល្អបាន។ ដូចគ្នាសម្រាប់ស្ត្រីខ្លះផងដែរ ជាធម្មតាទេដែលត្រូវធ្វើតាមការសម្រេចចិត្តរបស់ឪពុកម្ដាយខ្លួន។ លោកស្រី ហ៊ុន សុន [Hun Son] អាយុ ៦១ ឆ្នាំ បានរៀបការនៅពេលគាត់មានអាយុ ១៧ ឬ ១៨ ឆ្នាំ ជាមួយបុរសម្នាក់មកពីភូមិដូចគ្នា។ គាត់បានរំលឹកថា គាត់មានអារម្មណ៍រីករាយណាស់នៅថ្ងៃអាពាហ៍ពិពាហ៍ ព្រោះ *"ខ្ញុំយល់ថា វាជាពិធីមួយដើម្បីបង្ហាញពីការដឹងគុណដោយស្មោះរបស់ខ្ញុំជាកូនចំពោះឪពុកម្ដាយខ្ញុំ"*[៣៣]។

ជារឿងធម្មតាផងដែរ ដែលស្ត្រីមិនស្គាល់ប្ដីរបស់ខ្លួនទាល់តែសោះមុនថ្ងៃរៀបអាពាហ៍ពិពាហ៍។ លោកស្រី ស៊ូ សាវ៉ន [Su Savorn] បាននិយាយថា៖ *"អាពាហ៍ពិពាហ៍របស់ខ្ញុំត្រូវបានរៀបចំដោយគ្រួសាររបស់ខ្ញុំ។ នៅពេលនោះ ខ្ញុំមិនស្គាល់ប្ដីរបស់ខ្ញុំទេ។ ម្ដាយរបស់ខ្ញុំសួរយោបល់ខ្ញុំអំពីអាពាហ៍ពិពាហ៍នោះ ដូច្នេះខ្ញុំបានឆ្លើយថា៖ "ស្រេចតែលើម៉ែចុះ។ ខ្ញុំនឹងធ្វើតាមការសម្រេចចិត្តរបស់ម៉ែ"។ បន្ទាប់មក ម្ដាយរបស់ខ្ញុំបានសម្រេចចិត្តយ៉ាងរហ័សឱ្យខ្ញុំរៀបការជាមួយគាត់។ នោះគឺជាហេតុផលដែលខ្ញុំបានរៀបការជាមួយប្ដីរបស់ខ្ញុំ"*[៣៤]។ លោកស្រី រុធ ក៏បានរៀបការនៅក្នុងរបប លន់ នល់ ផងដែរ ហើយថា៖ *"ខ្ញុំមិនដែលស្គាល់មុខប្ដីរបស់ខ្ញុំទេរហូតដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍តែម្ដង"*[៣៥]។

លោក យាយ សុខ [Yeay Sok] បានបាត់បង់ឪពុកតាំងពីពេលគាត់នៅក្មេងម្ល៉េះ។

*នៅមុនរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំរស់នៅក្នុងខេត្តតាកែវ ហើយប្ដីរបស់ខ្ញុំក៏រស់នៅក្នុងខេត្តតាកែវដែរ។ បងប្រុសរបស់ប្ដីខ្ញុំបានណែនាំគាត់ទៅឱ្យម្ដាយរបស់ខ្ញុំ។ ម្ដាយខ្ញុំបានសួរយោបល់ខ្ញុំអំពីអាពាហ៍ពិពាហ៍នេះ ហើយខ្ញុំក៏បានយល់ព្រម។ ដូច្នេះ ខ្ញុំមិនត្រូវបានឪពុកម្ដាយខ្ញុំបង្ខំឱ្យរៀបការនោះឡើយ។ ទោះជាយ៉ាងណា នេះគឺជារបៀបដែលខ្ញុំបានរៀបការជាមួយគាត់ និងក្លាយជាប្រពន្ធគាត់។ ម្ដាយរបស់ខ្ញុំជាអ្នករៀបចំអាពាហ៍ពិពាហ៍នោះ។ ជាធម្មតា នៅពេលនោះ ពិធីមង្គលការត្រូវបានប្រារព្ធឡើងក្នុងរយៈពេលមួយថ្ងៃពេញ និងមួយយប់។ សាច់ញាតិ និងអ្នកជិតខាងជុំវិញផ្ទះខ្ញុំបានមកចូលរួមពិធីមង្គលការរបស់ខ្ញុំដែរ។ យើងមានម្ហូបអាហារយ៉ាងច្រើនសម្រាប់ភ្ញៀវ។ ខ្ញុំសប្បាយចិត្តណាស់នៅពេលដែលខ្ញុំបានរៀបការជាមួយប្ដីខ្ញុំ ទោះជាខ្ញុំមិនដែលស្គាល់គាត់មុនពេល*

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*រៀបការក្តី។ ខ្ញុំមានអារម្មណ៍ខ្មាស់អៀន និងអាម៉ាស់បន្តិចក្នុងពិធីមង្គលការដោយសារតែខ្ញុំមិនដែលស្គាល់គាត់សោះ។*

ជាសំណាងល្អ បន្ទាប់ពីមួយខែក្រោយរៀបការរួច គាត់ចាប់ផ្តើមស្គាល់ប្តីរបស់គាត់ ហើយគាត់ពិតជាចាប់ផ្តើមស្រឡាញ់ប្តីគាត់ហើយ។

ជាទូទៅ ម្តាយខាងកូនប្រុសជាអ្នកទាក់ទងម្តាយខាងកូនស្រីដើម្បីសាកសួរអំពីសំណើសុំរៀបអាពាហ៍ពិពាហ៍។ វាអាចជាសំណើដែលធ្វើឡើងដោយកូនប្រុសខ្លួនឯង ឬឪពុកម្តាយជាអ្នកជ្រើសរើសកូនក្រមុំដែលសក្តិសមសម្រាប់កូនរបស់ខ្លួន។ លោកស្រី អ៊ីរ៉ា [Era] បានរៀបការជាមួយបងប្អូនជីដូនមួយរបស់គាត់ដែលបានស្រឡាញ់គាត់ និងសុំការអនុញ្ញាតតាមរយៈមីងរបស់គាត់ ដែលបានជូនដំណឹងបន្តទៅម្តាយ និងបន្ទាប់មកទៅឪពុករបស់លោកស្រី អ៊ីរ៉ា [Era]។

*ប្តីរបស់ខ្ញុំបានសុំឲ្យចាស់ទុំក្នុងគ្រួសារគាត់ទៅនិយាយជាមួយឪពុកម្តាយខ្ញុំ ដើម្បីសុំការអនុញ្ញាតឲ្យគាត់រៀបការជាមួយខ្ញុំ។ ថ្ងៃមួយ មីងរបស់ខ្ញុំម្នាក់បានមកផ្ទះរបស់ខ្ញុំដើម្បីខ្ចីលុយឪពុកម្តាយរបស់ខ្ញុំ ហើយក៏បានឃើញប្តីរបស់ខ្ញុំពេលគាត់នៅលីវ។ មីងបាននិយាយជាមួយប្តីខ្ញុំ និងបានហៅឈ្មោះហៅក្រៅរបស់គាត់ ហើយនិយាយថា "អា យុយ ម៉េចក៏ឯងមិនរៀបការ? តើឯងស្រឡាញ់នរណាគេ? ចាំ មីងជួយ"។ គាត់ក៏ឆ្លើយថា៖ "ខ្ញុំចាប់ចិត្តស្រឡាញ់ស្រីម្នាក់។ តើមីងអាចចូលទៅនិយាយជាមួយគ្រួសារគាត់សុំឲ្យខ្ញុំរៀបការបានទេ"? មីងខ្ញុំខ្លាចឪពុកខ្ញុំណាស់។ នៅពេលនោះ ឪពុកខ្ញុំជាមនុស្សដែលមានអំណាចណាស់។ គាត់អាចចូលរួមក្នុងបដិវត្តន៍ប្រឆាំងនឹងព្រះបាទសីហនុផងព្រោះគាត់មានតំណែងសំខាន់ណាស់នៅក្នុងវិស័យតុលាការ។ អំណាចរបស់គាត់មានពេញផ្ទៃប្រទេសកម្ពុជា មានន័យថា គាត់កាន់កាប់អំណាចធំណាស់។ ហើយពូរបស់ខ្ញុំក៏មានអំណាចខ្លាំងណាស់ដែរ។ សាច់ញាតិរបស់ខ្ញុំជាច្រើនធ្វើការក្នុងជួរកងទ័ព និងកាន់តំណែងធំៗផងដែរ។ នៅពេលនោះ ខ្ញុំមិនបានដឹងថា គ្រួសាររបស់ខ្ញុំគឺជាគ្រួសារដ៏មានអំណាចបែបនោះទេ ប៉ុន្តែនៅពេលណាដែលខ្ញុំចេញពីផ្ទះ ឪពុកម្តាយខ្ញុំមិនឲ្យខ្ញុំទៅតែម្នាក់ឯងទេ ពួកគាត់តែងតែចាត់ឲ្យអ្នកបើកឡានបើកឡានជូនខ្ញុំទៅជានិច្ច។ ឪពុកម្តាយខ្ញុំមិនឲ្យខ្ញុំដើរតែម្នាក់ឯងទេ ព្រោះនៅពេលនោះក្នុងអំឡុងឆ្នាំ ១៩៧១ ដល់ឆ្នាំ ១៩៧២ ប្រទេសយើងគ្មានស្ថេរភាពទេ ដូច្នេះ ពួកគាត់ខ្លាចខ្ញុំត្រូវមនុស្សមិនស្គាល់មុខចាប់ជំរិត។ នេះក៏ជាមូលហេតុមួយដែលឪពុកម្តាយខ្ញុំប្រញាប់ឲ្យខ្ញុំរៀបការ។ ខ្ញុំបានរៀបការនៅអាយុ ២២ ឆ្នាំ។*

*តាមការសាកសួររបស់មីងខ្ញុំអំពីរឿងរៀបការ ប្តីរបស់ខ្ញុំបានឆ្លើយថា៖ "បាទ មានមនុស្សម្នាក់ដែលខ្ញុំចង់រៀបការជាមួយ។ តើមីងអាចចូលសួរគ្រួសារខាងស្រីសុំការអនុញ្ញាតឲ្យខ្ញុំរៀបការជាមួយគាត់បានទេ? បើមីងគិតថាអាចជួយខ្ញុំបាន ខ្ញុំនឹងប្រាប់ឈ្មោះគាត់ឲ្យមីងដឹង"។ ខ្ញុំអស់សំណើច*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*ណាស់ពេលគាត់ប្រាប់ខ្ញុំរឿងនេះ គាត់ខ្លាចនឹងសុំគេរៀបការជាមួយខ្ញុំណាស់ ព្រោះខ្ញុំជាអ្នកមកពីគ្រួសារដែលមានអំណាច។ ប៉ុន្តែ ក្រោយមកគាត់បាននិយាយទៅកាន់មីងគាត់ថា៖ "មនុស្សស្រីដែលខ្ញុំចង់រៀបការជាមួយនោះគឺ កូនស្រីរបស់ តា ប៉ាន់"។ ឪពុកខ្ញុំឈ្មោះ "លី កុន ប៉ាន់" ហើយសាច់ញាតិខ្ញុំទាំងអស់ហៅគាត់ថា តា ប៉ាន់ និងស្រឡាញ់ឪពុករបស់ខ្ញុំណាស់ដោយសារតែគាត់ពិតជាមនុស្សចិត្តល្អមែន។ ប្ដីរបស់ខ្ញុំនិយាយថា គាត់ស្រឡាញ់កូនស្រីតា ប៉ាន់។ ប៉ុន្តែ នៅពេលគ្រប់គ្នាលឺដូចនេះ ពួកគេខ្លាច។ បញ្ហាទីមួយគឺឪពុកខ្ញុំគឺជាមនុស្សម្នាក់ដែលហ្មត់ចត់ខ្លាំងណាស់។ ទីពីរ តាមប្រពៃណីចិន អ្នកដែលមកពីគ្រួសារតែមួយមិនអនុញ្ញាតឲ្យរៀបការជាមួយគ្នាបានទេ ហើយប្ដីរបស់ខ្ញុំ និងខ្ញុំមាននាមត្រកូលដូចគ្នា។ ដូច្នេះ មីងរបស់ខ្ញុំឆ្លើយថា៖ "មនុស្សស្រីមានច្រើនណាស់ក្នុងស្រុកខ្មែរ។ ម៉េចក៏ឯងទៅចាប់ចិត្តនឹងកូនស្រី តា ប៉ាន់វិញ? កូនស្រីគាត់នោះឆ្នាស់ខ្លាំងណាស់"។ ប៉ុន្តែ ប្ដីរបស់ខ្ញុំសុំឲ្យមីងគាត់ព្យាយាម ដូច្នេះមីងខ្ញុំក៏និយាយថា៖ "អញ្ចឹងក៏បាន ចាំមីងសាកនិយាយជាមួយម្ដាយនាងមុនសិន"។ តាមប្រពៃណីខ្មែរ យើងទៅនិយាយជាមួយម្ដាយជាមុនសិនមុននឹងសុំការអនុញ្ញាតពីឪពុក។ ចូលដល់ម្ដាយមុនសិន រួចទើបម្ដាយយកទៅប្រាប់ និងពិភាក្សាជាមួយឪពុក។ ដូច្នេះ មីងខ្ញុំក៏មកនិយាយជាមួយម្ដាយខ្ញុំមុន ហើយម្ដាយខ្ញុំបានប្រាប់គាត់ឲ្យរង់ចាំឪពុកខ្ញុំ ព្រោះគាត់មិនអាចធ្វើការសម្រេចចិត្តណាមួយឡើយ។ ព្រោះបញ្ហាធ្ងន់ធ្ងរគឺយើងមាននាមត្រកូលដូចគ្នា។ នោះមានន័យថា យើងគឺជាសាច់ញាតិនឹងគ្នា ហើយជាធម្មតាគេមិនអនុញ្ញាតឲ្យរៀបការជាមួយគ្នាឡើយតាមប្រពៃណីចិន។ បន្ទាប់ពីឪពុកខ្ញុំមកដល់ផ្ទះ ម្ដាយខ្ញុំបាននិយាយជាមួយឪពុកខ្ញុំអំពីការចូលស្ដីនិងស្នើសុំនេះ។ ជាការភ្ញាក់ផ្អើល ឪពុកខ្ញុំបាននិយាយថា គាត់អនុញ្ញាតឲ្យពួកយើងរៀបការ។ រឿងនេះជាការពិត ព្រោះឪពុកខ្ញុំខ្លាចថាខ្ញុំនឹងត្រូវជនល្មើស ចាប់ជំរិតដោយសារតែខ្ញុំស្អាតកាលពីនៅក្មេង។ បន្ទាប់ពីពិភាក្សាគ្នារួច ឪពុកខ្ញុំបានប្រាប់ឲ្យប្ដីខ្ញុំភ្ជាប់ពាក្យជាមួយខ្ញុំ។ ឪពុកខ្ញុំមិនចង់បានអ្វីពីកូនៗទេ គាត់គ្រាន់តែចង់ឲ្យកូនៗរបស់គាត់មានសុភមង្គលតែប៉ុណ្ណោះ។ ឪពុកខ្ញុំស្រឡាញ់ខ្ញុំខ្លាំងណាស់ ខ្លាំងជាងម្ដាយខ្ញុំស្រឡាញ់ខ្ញុំទៅទៀត។ ម្ដាយខ្ញុំស្រឡាញ់កូនប្រុសជាងកូនស្រី។ ក្រោយពីយើងបានភ្ជាប់ពាក្យរួច តាមវប្បធម៌ខ្មែរ យើងអាចរៀបការបាននៅក្រោយភ្ជាប់ពាក្យបានមួយឆ្នាំប៉ុណ្ណោះ។*

គាត់បានយល់ព្រមរៀបការជាមួយប្ដីគាត់ ហើយពួកគេបានរៀបការនៅក្នុងទីក្រុង ដោយមានមនុស្សយ៉ាងច្រើនចូលរួម។

លោកស្រី ម៉យ រ៉ុម [Moy Rom] អាយុ ៦១ ឆ្នាំ បានរៀបការជាមួយទាហានសម័យ លន់ នល់ម្នាក់នៅមុនរបបខ្មែរក្រហម[៣៦]។

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

*នៅមុនរបបខ្មែរក្រហម ខ្ញុំបានស្រឡាញ់បុរសម្នាក់ដែលធ្វើការជាទាហានឱ្យរដ្ឋាភិបាល លន់ នល់។ ប្តីរបស់ខ្ញុំបានចាប់ចិត្តស្រឡាញ់ខ្ញុំមុន ហើយខ្ញុំក៏ប្រែជាស្រឡាញ់គាត់ដែរ។ ដូច្នេះ គាត់ក៏បានប្រាប់ឪពុកម្តាយគាត់ថា គាត់ចង់រៀបការជាមួយខ្ញុំ ហើយក្រោយមកឪពុកម្តាយរបស់គាត់បានចូលស្ដីឪពុកម្តាយខ្ញុំដើម្បីឱ្យកូនប្រុសពួកគេបានរៀបការជាមួយខ្ញុំ។ ខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់នៅពេលដំណើរការនេះកើតឡើង ហើយខ្ញុំអាចរៀបការជាមួយ គាត់បាន។ ពិធីអាពាហ៍ពិពាហ៍របស់យើងគឺជាពិធីធម្មតា។ ក្រោយពីរៀបការរួច យើងបានទៅរស់នៅក្នុងមូលដ្ឋានយោធាជាមួយក្រុមគ្រួសារទាហានផ្សេងទៀត ដែលមានទីតាំងស្ថិតនៅទីរួមខេត្តសៀមរាប។ មានប្រមាណជា ២០០ គ្រួសារ ឬសឹងតែច្រើនជាងនេះផងនៅក្នុងមូលដ្ឋានយោធានោះ។ កន្លែងនោះធំខ្លាំងណាស់។*

លោកស្រី មួយ គា [Muy Kea] គឺជាកូនស្រីនៃគ្រួសារដែលមានទ្រព្យសម្បត្តិមួយនៅមុនសង្គ្រាម ប៉ុន្តែម្តាយរបស់គាត់បានលាចាកលោកនៅពេលគាត់មានអាយុ ៦ ឆ្នាំ ហើយជីវិតរបសគាត់ក៏បានផ្លាស់ប្តូរ។ គាត់បានឈប់រៀន ហើយគាត់មានម្តាយថ្មីដែលមានកូនក្មេងជាងគាត់។ ម្តាយក្មេករបស់គាត់បានរៀបចំមង្គលការឱ្យគាត់ជាមួយសាច់ញាតិរបស់គាត់[៣៧]។

*ប្តីរបស់ខ្ញុំគឺជាសាច់ញាតិរបស់ម្តាយចុងខ្ញុំ។ ពួកគេត្រូវស្វែងរកប្រពន្ធឱ្យគាត់ ដូច្នេះ ចាស់ទុំក៏បានរៀបចំឱ្យគាត់រៀបការជាមួយខ្ញុំ។ ទាំងម្តាយក្មេក និងមីងរបស់ខ្ញុំបានព្យាយាមភ្ជាប់ទំនាក់ទំនងខ្ញុំជាមួយនឹងគាត់។ នៅពេលខ្ញុំនៅលីវ ខ្ញុំមិនដែលមានសង្សារទេ ដោយសារតែបទដ្ឋានប្រពៃណីខ្មែរមិនអនុញ្ញាតឱ្យស្ត្រីនៅលីវស្រឡាញ់បុរសណាមុនពេលរៀបការឡើយ។ បើនរណាម្នាក់ស្រឡាញ់យើង នោះគេនឹងចូលមកប្រាប់ចាស់ទុំឱ្យពួកយើងភ្ជាប់ពាក្យនឹងគ្នាហើយ។ តាមពិត មានបុរសជាច្រើនដែលចាប់ចិត្តនឹងខ្ញុំ ប្រហែលជា ២០ នាក់ ប៉ុន្តែខ្ញុំមិនចាប់អារម្មណ៍នឹងនរណាម្នាក់សោះ ហើយខ្ញុំមិនស្រឡាញ់ពួកគេទេ។ ដូច្នេះ ចុងក្រោយ ខ្ញុំព្រមទទួលយកប្តីរបស់ខ្ញុំ ព្រោះខ្ញុំគិតថា គាត់គឺជាមនុស្សល្អគ្រប់គ្រាន់។ ដូចគ្នានេះផងដែរ សង្គ្រាមក៏ចាប់ផ្តើមមាន ដូច្នេះ ខ្ញុំត្រូវការមនុស្សម្នាក់នៅជាមួយខ្ញុំ កុំឱ្យនៅលីវ និងនៅតែម្នាក់ឯង ដើម្បីសន្តិសុខ។*

ហេតុផលសន្តិសុខឧស្សាហ៍ត្រូវបានលើកឡើង ជាការលើកទឹកចិត្តឱ្យឪពុកម្តាយរបស់ពួកគេរៀបចំអាពាហ៍ពិពាហ៍ឱ្យកូនស្រីរបស់ពួកគេណាស់។ លោកស្រី ហួត យ៉ុន [Hout Yon] អាយុ ៦២ ឆ្នាំ បាននិយាយថា៖ *"នៅឆ្នាំ ១៩៧៣ ខ្ញុំត្រូវឪពុកម្តាយខ្ញុំបង្ខំឱ្យរៀបការ។ ពួកគាត់ព្រួយបារម្ភពីសន្តិសុខ។ ពួកគាត់បារម្ភខ្លាចនរណាម្នាក់ចាប់ជំរិតខ្ញុំ។ នោះគឺជាមូលហេតុដែលពួកគាត់បង្ខំខ្ញុំ"*[៣៨]។

អ្វីដែលគួរឱ្យចាប់អារម្មណ៍ លោកស្រី ជូ ជួប [Chou Choub] បានរៀបរាប់ឡើងវិញពីដំណើរការដែលគាត់ទៅចុះលិខិតអាពាហ៍ពិពាហ៍របស់គាត់នៅកន្លែងអាជ្ញាធរមូលដ្ឋាន[៣៩]។

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*នៅមុនរបបខ្មែរក្រហមបាន ខ្ញុំបានរៀបការរួចហើយ។ ម្តាយខ្ញុំបានសម្រេចចិត្តលើមង្គលការរបស់ខ្ញុំ។ ខ្ញុំគ្រាន់តែធ្វើតាមការសម្រេចចិត្តរបស់គាត់ប៉ុណ្ណោះ។ នៅពេលពួកយើងត្រូវរៀបការ យើងបានជួបប្រធានភូមិដើម្បីប្រាប់គាត់ថាយើងនឹងរៀបការ។ បន្ទាប់មក គាត់បានផ្តល់លិខិតអនុញ្ញាត។ វាជាលិខិតដែលអនុញ្ញាតឱ្យយើងរៀបការ ដែលអាចបង្ហាញថា ភាគីម្ខាងៗគ្មានប្តី ឬប្រពន្ធណាផ្សេងទៀតទេ។ យើងត្រូវតែបញ្ជាក់ថា យើងនៅលីវមុនពេលយើងរៀបការ។ ដូច្នេះ យើងអាចរៀបការបាន។*

ស្ត្រីភាគច្រើនមិនបានចាំអ្វីច្រើនអំពីការចុះលិខិតអាពាហ៍ពិពាហ៍របស់ពួកគេទេ ប៉ុន្តែឪពុកម្តាយរបស់ពួកគេជាអ្នកធ្វើរឿងនេះ។

**ពិធីអាពាហ៍ពិពាហ៍**

ឪពុកម្តាយ ឬអាណាព្យាបាលជាអ្នករៀបចំពិធីអាពាហ៍ពិពាហ៍។ ភាគច្រើន ពិធីនេះជាព្រឹត្តិការណ៍សំខាន់ និងធំមួយសម្រាប់ក្រុមគ្រួសារ និងសហគមន៍។ លោកស្រី សារ៉ន ទូន [Saron Toun] បាននិយាយថា គាត់បានជូនម្តាយរបស់គាត់ចែកលិខិតអញ្ជើញចូលរួមពិធីមង្គលការរបស់គាត់ដោយថ្មើរជើង នៅក្នុងភូមិ[៤០]។

បទពិសោធន៍អំពីពិធីមង្គលការគឺប្លែកៗពីគ្នា អាស្រ័យលើឆ្នាំ និងទីតាំង។ លោកស្រី មួយ គា [Muy Kea] រំលឹកពីពិធីមង្គលការរបស់ឪពុកគាត់នៅពេលគាត់រៀបការសាជាថ្មី បន្ទាប់ពីប្រពន្ធគាត់បានលាចាកលោកទៅ[៤១]។

*ឪពុកខ្ញុំបានរៀបការម្តងទៀតនៅពេលខ្ញុំមានអាយុ ៩ ឆ្នាំ។ មង្គលការរបស់គាត់ធ្វើឡើងធំដុំណាស់ ព្រោះគាត់ជាអ្នកមាន។ ប្រពន្ធទីពីរ ត្រូវជាម្តាយចុងរបស់ខ្ញុំ ត្រូវការប្រាក់ច្រើនណាស់ពីឪពុកខ្ញុំសម្រាប់ពិធីមង្គលការនេះ ព្រោះវាជាពិធីមង្គលការដំបូងរបស់គាត់។ ឪពុកម្តាយគាត់បានស្នើឱ្យឪពុកខ្ញុំវេចនំ ៦០ គីឡូក្រាមសម្រាប់ភ្ញៀវ។ នៅពេលនោះ ជីដូនរបស់ខ្ញុំនៅរស់ទេ ប៉ុន្តែជីតារបស់ខ្ញុំបានស្លាប់ហើយនៅក្នុងប្រទេសចិន។ ដូច្នេះ គឺជីដូនរបស់ខ្ញុំជាអ្នករៀបចំ និងប្រារព្ធពិធីមង្គលការសម្រាប់ឪពុកខ្ញុំ។ ខ្ញុំសប្បាយចិត្តដែលឃើញឪពុកខ្ញុំរៀបការម្តងទៀត។ បីឆ្នាំហើយបន្ទាប់ពីម្តាយខ្ញុំបានលាចាកលោកទៅ ហើយខ្ញុំប្រហែលជាមិនចងចាំអនុស្សាវរីយ៍អំពីម្តាយរបស់ខ្ញុំទេ។*

លោកស្រី លាង វុធ [Leang Vuth] កើតនៅខេត្តកំពង់ចាម ប៉ុន្តែមិនយូរប៉ុន្មានមុនរបបខ្មែរក្រហមរស់នៅក្នុងខេត្តព្រៃវែង។ គាត់បានរៀបការនៅឆ្នាំ ១៩៧៣ ក្នុងសម័យ លន់ នល់ ហើយពិធីមង្គលការរបស់គាត់ធំណាស់ ដោយមានភ្ញៀវចូលរួមជាង ៤០០ នាក់[៤២]។

*ឪពុកខ្ញុំជាអ្នករៀបចំមង្គលការឱ្យខ្ញុំ ទោះជាយើងមិនបានរស់នៅជាមួយគ្នាក្តី។ ខ្ញុំមិនស្គាល់ប្តីរបស់ខ្ញុំទេមុនថ្ងៃរៀបការ។ ខ្ញុំមិនដែលជួបគាត់ពីមុនទេ។ សម្រាប់ពិធីមង្គលការរបស់ខ្ញុំ យើងបានប្រារព្ធ*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*ធ្វើមួយយប់មួយថ្ងៃ យើងមានតន្ត្រី ម្ហូបអាហារ និងពិធីប្រពៃណីជាច្រើនសម្រាប់មង្គលការរបស់យើង។ មានភ្ញៀវជាច្រើនដែលចូលរួមក្នុងពិធីមង្គលការរបស់ខ្ញុំ ប្រមាណជា ៥០ តុ មានន័យថាប្រហែលជា ៤០០ នាក់។ នៅពេលនោះ មួយតុគឺសម្រាប់មនុស្ស ៨ នាក់។ នេះគឺដោយសារតែឪពុកម្តាយក្មេករបស់ខ្ញុំគឺជាអ្នកមាន។ ខ្ញុំគ្មានអារម្មណ៍ពិសេសណាមួយចំពោះអាពាហ៍ពិពាហ៍របស់ខ្ញុំទេ ព្រោះខ្ញុំគ្មានក្តីស្រឡាញ់ផង។ ខ្ញុំបានជួបប្តីរបស់ខ្ញុំនៅថ្ងៃដែលយើងរៀបការ។ ខ្ញុំមានអាយុ ១៨ ឆ្នាំ ហើយប្តីខ្ញុំមានអាយុ ២៥ ឆ្នាំ នៅពេលដែលយើងរៀបការនោះ។ ប្តីរបស់ខ្ញុំស្រឡាញ់ខ្ញុំ និងថែទាំខ្ញុំបានដិតដល់ណាស់។ មុនពេលរៀបការ ខ្ញុំមិនដឹងថាស្នេហាមានន័យយ៉ាងណានោះទេ ហើយក៏គ្មានបុរសណាម្នាក់ស្រឡាញ់ខ្ញុំដែរ។ ជាអកុសល ពួកខ្មែរក្រហមបានសម្លាប់ប្តីខ្ញុំនៅក្នុងខេត្តកំពង់ចាម ក្នុងឆ្នាំ ១៩៧៨។ គឺទើបតែបាន ១០ ថ្ងៃប៉ុណ្ណោះបន្ទាប់ពីកូនរបស់យើងកើត។*

សម្រាប់ស្ត្រីទាំងអស់ដែលរៀបការ នៅពេលការវាយប្រយុទ្ធគ្នាបានកើតមាននៅដើមទសវត្សរ៍ឆ្នាំ ១៩៧០ គ្មានតន្ត្រី និងភ្លើងចម្រុះពណ៌សម្រាប់ប្រើប្រាស់ឡើយ។ ស្ត្រីជាច្រើនដែលបានរៀបការមុនពេលមានសង្គ្រាម គឺកាន់តែស្ងប់ស្ងាត់ទៅទៀតដោយគ្មានតន្ត្រី។ រឿងនេះនៅតែជាការសោកស្តាយមួយសម្រាប់ពួកគេ ពួកគេចង់ឱ្យមានការប្រារព្ធពិធីធំជាងនេះ។ លោកស្រី មួយ គា [Muy Kea] បានរំលឹកអំពីពិធីមង្គលការរបស់គាត់ទាំងការសោកស្តាយ ដោយសារតែពិធីនោះស្ងាត់ពេក[៤៣]។ ពិធីមង្គលការរបស់គាត់មិនធំណាស់ណាទេ គឺមានមនុស្សតែ ៦០ នាក់ប៉ុណ្ណោះបានចូលរួមដោយសារតែមានសង្គ្រាម។

*យើងមិនអាចមានពេលក្រេបទឹកឃ្មុំទេ ព្រោះសង្គ្រាមបានចាប់ផ្តើមមានរួចទៅហើយនៅពេលនោះ។ ពួកខ្មែរក្រហមបានកំណត់សិទ្ធិរបស់យើងមិនឱ្យផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ។ យើងបានឃើញយន្តហោះជាច្រើនហោះទម្លាក់គ្រាប់បែក។ ខ្ញុំបានឃើញយន្តហោះទម្លាក់គ្រាប់បែកជាច្រើន និងក៏បានឃើញភ្លើងធំៗនៅលើមេឃផងដែរ។ ដូច្នេះ ខ្ញុំពិតជាមិនរីករាយនឹងរៀបការសោះនៅពេលនោះ គឺនៅពេលមានសង្គ្រាមដូចនោះ។ សូម្បីតែពេលដែលយើងត្រូវចម្អិនអាហារ យើងត្រូវលាក់មិនឱ្យមានផ្សែងចេញពីចង្ក្រាន។ យើងខ្លាចថា យន្តហោះអាចមើលឃើញយើង ហើយទម្លាក់គ្រាប់បែកមកលើយើង។*

មិនមែនស្ត្រីទាំងអស់ដែលរៀបការរួចនៅមុនរបបខ្មែរក្រហម សុទ្ធតែបានរៀបចំពិធីមង្គលការនោះទេ។ លោកស្រី ពិន មឿន [Pin Moeun] អាយុ ៧៦ ឆ្នាំ មិនមានពិធីមង្គលការដែលមានភ្ញៀវចូលរួមឡើយ។ គាត់បាននិយាយថា៖ *"គ្រួសាររបស់ខ្ញុំក្រណាស់។ ឪពុកម្តាយខ្ញុំគ្មានលទ្ធភាពរៀបចំពិធីជប់លៀងធំ ហើយគ្រួសារខាងប្តីរបស់ខ្ញុំក៏ដូចគ្នា។ ដូច្នេះយើងគ្រាន់តែរៀបចំពិធីសាសនាតូចមួយនៅផ្ទះប៉ុណ្ណោះ"*[៤៤]។

នៅមុនរបបខ្មែរក្រហម ឪពុកម្តាយ ឬចាស់ព្រឹទ្ធាចារ្យដើរតួនាទីយ៉ាងសំខាន់ក្នុងមង្គលការកូនស្រីរបស់ពួកគេ ហើយពិធីមង្គលការត្រូវបានរៀបចំឡើងតាមប្រពៃណីដោយក្រុមគ្រួសាររបស់ពួកគេ។ ដំណើរ

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

ការទាំងនេះភាគច្រើនមិនត្រូវបានពួកខ្មែរក្រហមអើពើឡើយ នៅពេលពួកគេបានចាប់ផ្ដើមប្រព័ន្ធអាពាហ៍ពិពាហ៍រួម។

**ការសម្រាលកូនមុនរបបខ្មែរក្រហម**

ស្ត្រី ៥៥ នាក់ដែលត្រូវបានសម្ភាសមានកូនយ៉ាងហោចណាស់មួយរួចទៅហើយនៅមុនរបបខ្មែរក្រហម (បុរស ៤៤ នាក់មានកូនមុនរបបខ្មែរក្រហម)។ លោកស្រី យូន ហត [Youn Hot] រំលឹកទាំងសើចថា៖ *"នៅពេលនោះ គ្មាននរណាម្នាក់ដឹងថាមានថ្នាំដែលអាចបង្ការកុំឱ្យមានកូននោះទេ។ យើងមិនបានពីវិធីការពារបែបនោះទាល់តែសោះ។ យើងទាំងអស់សុទ្ធតែល្ងង់។ ដូច្នេះ នៅពេលនោះ ស្ត្រីម្នាក់ៗមានកូនពី ៤ ទៅ ១០ នាក់ ព្រោះគ្មាននរណាម្នាក់ដឹងពីរបៀបការពារនោះទេ។ យើងដូចមនុស្សល្ងីល្ងើអញ្ចឹង ព្រោះនៅពេលឪពុកម្ដាយយើងរៀបចំឱ្យយើងរៀបការ យើងមិនដែលបដិសេធទេ។ យើងក៏មិនដឹងពីរបៀបបង្ការកុំឱ្យមានកូនដែរ"*[៤៥]។

ស្ត្រីជាច្រើនមានផ្ទៃពោះ នៅពេលពួកខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ ១៩៧៥។ លោកស្រី ប៊ុន ផល្លា [Bun Phalla] អាយុ ៦៧ ឆ្នាំ គឺជាមនុស្សម្នាក់ក្នុងចំណោមនោះ។ ដោយសារតែមានការប្រយុទ្ធគ្នាខ្លាំងក្លានៅក្នុងតំបន់របស់គាត់ គាត់បានរត់គេចខ្លួនជាមួយម្ដាយគាត់ទៅកន្លែងមានសុវត្ថិភាព ដោយមិនដឹងថា គាត់ទៅទីណានោះទេ។ ខណៈពេលដែលគាត់ដើរកាត់ព្រៃនៅពេលយប់ គាត់បានកើតកូន ហើយមានតែម្ដាយគាត់ប៉ុណ្ណោះដែលជួយ។ ជាអកុសល កូនប្រុសរបស់គាត់បានស្លាប់ភ្លាមៗ ហើយគាត់មានអារម្មណ៍ *"សោកស្ដាយ និងរន្ធត់យ៉ាងខ្លាំងសម្រាប់ការបាត់បង់នេះ"*[៤៦]។

លោកស្រី យាយ សុខ [Yeay Sok] គឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីមួយចំនួនតូចដែលបានសម្រាលកូននៅក្នុងមន្ទីរពេទ្យនៅមុនរបបខ្មែរក្រហម[៤៧]។

*ប្ដីខ្ញុំគឺជាគ្រូពេទ្យក្នុងជួរកងទ័ព លន់ នល់ និងធ្វើដំណើរច្រើនណាស់។ ប៉ុន្តែ ភាគច្រើន កន្លែងធ្វើការសំខាន់របស់គាត់គឺនៅក្នុងទីក្រុងភ្នំពេញ។ គាត់គឺជាគ្រូពេទ្យនៅមន្ទីរពេទ្យមុនីវង្ស។ ខ្ញុំរស់នៅខេត្តតាកែវ ធ្វើស្រែចម្ការ។ ដោយសារតែការងាររបស់ប្ដីខ្ញុំ កូនទីមួយរបស់ខ្ញុំបានកើតនៅមន្ទីរពេទ្យរុស្ស៊ីក្នុងទីក្រុងភ្នំពេញ ដែលជារឿងមិនធម្មតា និងពិសេសខ្លាំងណាស់នៅពេលនោះសម្រាប់ស្ត្រីមានផ្ទៃពោះនៅតំបន់របស់ខ្ញុំ។ ស្ត្រីភាគច្រើនបានសម្រាលកូននៅផ្ទះ ហើយពួកគេមិនដែលបានទៅមន្ទីរពេទ្យទេ។*

លោកស្រី ជូ ជួប [Chou Choub] ក៏បាននិយាយផងដែរថា៖ *"នៅពេលនោះ យើងជាធម្មតាមិនបានទៅមន្ទីរពេទ្យដើម្បីពិនិត្យសុខភាព ឬសម្រាលកូននោះទេ។ យើងប្រើតែវិធីសាស្ត្របែបបុរាណប៉ុណ្ណោះ"*[៤៨]។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

ភាគច្រើន ស្ត្រីសម្រាលកូននៅផ្ទះដោយមានជំនួយពីឆ្មបបុរាណ។ វាជារឿងធម្មតានៅក្នុងខេត្តបាត់ដំបង ដែលស្ត្រីត្រូវគេឱ្យផឹកស្រាសបន្ទាប់ពីសម្រាលកូនរួច។

**ការលែងលះគ្នានៅមុនរបបខ្មែរក្រហម**

ក្នុងចំណោមស្ត្រី ១២១ នាក់ដែលយើងបានជួប មានតែស្ត្រីម្នាក់ប៉ុណ្ណោះ គឺ លោកស្រី នួប គង់ អាយុ ៧៧ ឆ្នាំ បានរាយការណ៍ថា គាត់បានលែងលះជាមួយប្តីនៅមុនរបបខ្មែរក្រហម។ *"គាត់គឺជាព្រាននារី ហើយតែងតែព្យាយាមទាក់ទាញចំណាប់អារម្មណ៍ពីស្រីៗនៅគ្រប់កន្លែង"*[៤៦]។ វាគឺជាទង្វើដាច់ខាតមួយ ដែលប្រពន្ធជាអ្នកផ្តើមសុំលែងលះ ប៉ុន្តែ លោកស្រី នួប គង់ បានធ្វើរឿងនេះ។

*ឪពុកម្តាយខ្ញុំបានរៀបចំមង្គលការឱ្យខ្ញុំ។ ប៉ុន្តែ តាមពិតប្តីរបស់ខ្ញុំស្រឡាញ់ខ្ញុំខ្លាំងណាស់។ គាត់បានសុំឱ្យឪពុកម្តាយគាត់ចូលស្តីខ្ញុំពីឪពុកម្តាយខ្ញុំដើម្បីបានរៀបការ។ យើងបានប្រារព្ធធ្វើពិធីមង្គលការតាមប្រពៃណីខ្មែររយៈពេលបីថ្ងៃ។ ប្តីរបស់ខ្ញុំគឺជាអ្នកបើកបរតាក់ស៊ី។ បន្ទាប់ពីខ្ញុំរៀបការរួច ខ្ញុំបានចាកចេញពីឪពុកម្តាយខ្ញុំ និងចាប់ផ្តើមជីវិតថ្មីជាមួយប្តីខ្ញុំ។ ដោយសារឪពុកម្តាយខ្ញុំ និងឪពុកម្តាយគាត់សុទ្ធក្រីក្រ យើងចង់រកកន្លែងថ្មីដើម្បីរស់នៅ និងមានជីវិតល្អប្រសើរជាងមុន។ ដូច្នេះ ខ្ញុំនិងប្តីបានសម្រេចចិត្តផ្លាស់ទៅនៅខេត្តកំពង់ចាមដើម្បីស្វែងរកការងារធ្វើនៅទីនោះ។ ចាប់ផ្តើមដំបូង ប្តីខ្ញុំ និងខ្ញុំទាំងពីរនាក់បានធ្វើការនៅចម្ការកៅស៊ូ។ ប៉ុន្តែ លក្ខខណ្ឌគ្រួសាររបស់ខ្ញុំ និងជីវិតរបស់យើងនៅតែលំបាកយ៉ាងខ្លាំង ដោយសារតែយើងខ្វះខាតធនធាន។ យើងនៅតែក្រ។ នៅពេលនោះគ្រួសាររបស់ខ្ញុំពឹងផ្អែកសំខាន់លើប្រាក់ចំណូលរបស់ប្តីខ្ញុំ។ ខ្ញុំក៏ជួយគាត់ដោយធ្វើការនៅចម្ការកៅស៊ូដែរដើម្បីជីវភាពគ្រួសារ។*

*ទោះជាយ៉ាងណា បន្ទាប់ពីនៅជាមួយប្តីខ្ញុំបានជាច្រើនឆ្នាំ ខ្ញុំបានសម្រេចចិត្តលែងលះគាត់ ដោយសារតែគាត់មិនស្មោះត្រង់ជាមួយខ្ញុំ។ ឧទាហរណ៍ ពេលគាត់ជិះឡានក្រុងទៅកន្លែងណាមួយ គាត់ព្យាយាមរកមនុស្សស្រី និងទាក់ទាញឱ្យនាងក្លាយជាមិត្តស្រីរបស់គាត់។ គាត់ក៏បានស្រឡាញ់ស្រីមួយចំនួនផ្សេងទៀតនៅខាងក្រៅផ្ទះផងដែរ។ ខ្ញុំស្អប់ទង្វើរបស់គាត់។ ខ្ញុំមិនអាចទ្រាំមើលគាត់បោកប្រាស់ខ្ញុំតាមរបៀបនោះទៀតទេ។ ដូច្នេះហើយទើបខ្ញុំសម្រេចចិត្តលែងលះគាត់ទោះ ជាខ្ញុំមានកូនពីរនាក់ជាមួយគាត់ហើយក្តី។ ដូច្នេះ ខ្ញុំបានចាកចេញពីគាត់។*

បន្ទាប់ពីលែងលះប្តីរបស់គាត់មក គាត់បានសម្រេចចិត្តចិញ្ចឹមកូនគាត់តែម្នាក់ឯង ដោយធ្វើការនៅចម្ការកៅស៊ូបារាំងមួយ។

*កូនខ្ញុំ និងខ្ញុំបានផ្លាស់ទៅរស់នៅកន្លែងមួយផ្សេងទៀតដើម្បីស្វែងរកការងារធ្វើ។ ខ្ញុំបានធ្វើការនៅចម្ការកៅស៊ូដែលស្ថិតក្រោមការគ្រប់គ្រងរបស់ជនជាតិបារាំង។ ពួកគេបានផ្តល់លំនៅដ្ឋានដល់យើង ដូច្នេះ កូនខ្ញុំ និងខ្ញុំបានស្នាក់នៅជាមួយគ្នានៅផ្ទះដែលបារាំងផ្តល់ឱ្យនោះ ហើយផ្ទះនោះស្ថិត*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*នៅក្បែរចម្ការកៅស៊ូស្រាប់។ ខ្ញុំមិនបានទទួលប្រាក់ខែអ្វីនោះទេ ប៉ុន្តែពួកគេបានផ្តល់ជាអង្ករឱ្យខ្ញុំជំនួសវិញ។ ក្នុងមួយខែៗ ខ្ញុំទទួលបានអង្ករ ២៥ គីឡូក្រាមដើម្បីផ្គត់ផ្គង់គ្រួសារខ្ញុំ។ លើសពីនេះទៀត បើយើងមានកូន យើងនឹងទទួលបានអង្ករបន្ថែមទៀត ដូច្នេះ បើយើងមានកូនកាន់តែច្រើន យើងនឹងទទួលបានអង្ករបន្ថែមកាន់តែច្រើនដែរ។ ដូច្នេះ ក្រៅពីអង្ករ ២៥ គីឡូក្រាម ដែលខ្ញុំទទួលបានដោយការធ្វើការ ខ្ញុំអាចទទួលបានអង្ករកាន់តែច្រើនដោយសារតែខ្ញុំមានកូនពីរនាក់បន្ថែមទៀតនៅក្នុងគ្រួសារ។ ជាមធ្យម ខ្ញុំអាចជៀរជ័រកៅស៊ូពីចម្ការកៅស៊ូបានពី ៣០ ទៅ ៣៥ លីត្រ ហើយមានមនុស្សជាច្រើនដែលចាំពិនិត្យមើលការងាររបស់យើង។ ប្រសិនបើខ្ញុំខ្ជិល ខ្ញុំនឹងត្រូវគេស្តីបន្ទោស។ ទោះជាយ៉ាងណា ពួកគេបានផ្តល់អាហារបីពេលក្នុងមួយថ្ងៃដល់យើង។ ផ្ទុយទៅវិញ បើយើងមិនប្រឹងប្រែងធ្វើការទេ យើងនឹងមិនទទួលបានអាហារបន្តិចឡើយពីពួកគេ នោះយើងនឹងត្រូវដាច់ពោះមិនខាន។ ខ្ញុំចាប់ផ្តើមធ្វើការតាំងពីព្រឹកពីម៉ោងប្រាំ រហូតដល់ពេលល្ងាចម៉ោងបួន ហើយពួកគេអនុញ្ញាតឱ្យយើងសម្រាកនៅពេលបាយថ្ងៃត្រង់។*

គាត់គឺជាម្តាយតែម្នាក់ឯងដែលតស៊ូដើម្បីរស់។ ទោះជាយ៉ាងណា ឪពុកម្តាយរបស់គាត់ព្រួយបារម្ភពីគាត់ និងកូនរបស់គាត់ណាស់ ហើយបានរៀបចំមង្គលការឱ្យគាត់ម្តងទៀត។ នៅក្នុងសង្គម ស្ត្រីដែលនៅលីវរហូតមិនអាចទទួលយកបានទេ។ គាត់បានរៀបការនឹងពោះម៉ាយម្នាក់ ដែលមានកូនម្នាក់រួចទៅហើយពីអាពាហ៍ពិពាហ៍មុន។ ប្រពន្ធរបស់គាត់បានស្លាប់ ហើយគាត់គឺជាឪពុកតែម្នាក់ឯង។

## ស្ត្រីនៅលីវនៅមុនរបបខ្មែរក្រហម

មានស្ត្រីរឹងទទឹងមួយចំនួននៅមុនរបបខ្មែរក្រហម ដែលបានបដិសេធមិនព្រមរៀបការតាមការរៀបចំរបស់ឪពុកម្តាយគេ។ ប៉ុន្តែ ករណីនោះកម្រណាស់។ ដូចបានកត់សម្គាល់ពីមុនមក ស្ត្រីភាគច្រើនក្នុងសង្គមខ្មែរមុនរបបខ្មែរក្រហម បានទទួលយកផ្នត់គំនិតដែលត្រូវរៀបការជាមួយអ្នកដែលឪពុកម្តាយខ្លួនជ្រើសរើសឱ្យទៅហើយ យ៉ាងហោចណាស់ម្តងក្នុងមួយជីវិតរបស់ពួកគេ។ អាពាហ៍ពិពាហ៍មិនមែនជា "ដំណើរការមួយ" ដើម្បីបន្តសុភមង្គលក្នុងជីវិតរបស់ស្ត្រីនោះទេ ប៉ុន្តែ វាត្រូវគេចាត់ទុកថាជាផ្នែកមួយនៃគោលបំណងធំៗក្នុងជីវិតរបស់ស្ត្រី។ សូម្បីតែស្ត្រីវ័យក្មេងសព្វថ្ងៃក៏ប្រកាន់ការយល់ឃើញបែបនេះ និងគោលបំណងនៃអាពាហ៍ពិពាហ៍ថាជាគោលដៅសំខាន់នៅក្នុងជីវិតរបស់ពួកគេផងដែរ ។

ទោះជាយ៉ាងណា សូម្បីតែនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ មានស្ត្រីមួយចំនួនដែលបានជ្រើសមិនព្រមរៀបការទោះជាឪពុកម្តាយខ្លួនសុំ ឬបញ្ជាម្តងហើយម្តងទៀតក្តី។ លោកស្រី នូ នួន [Nou Noun] អាយុ ៦២ ឆ្នាំ បាននិយាយថា៖ *"ខ្ញុំមិនចង់រៀបការទេ (មុនពេលពួកខ្មែរក្រហមចូលមក)។ ដូច្នេះ ខ្ញុំបានបដិសេធនឹងបញ្ជារបស់ឪពុកម្តាយខ្ញុំ។ ខ្ញុំនៅលីវរហូតដល់អាយុ ២៧ ឆ្នាំ។ បើសិនជាខ្ញុំធ្វើតាមការសម្រេចចិត្តរបស់*

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*ឪពុកម្តាយខ្ញុំ នោះខ្ញុំនឹងរួចរៀបការរួចហើយនៅអាយុ ២០ ឆ្នាំ”*[៥០]។ ជាអកុសល គាត់ត្រូវបានបង្ខំឱ្យរៀបការនៅក្នុងរបបខ្មែរក្រហម ហើយ *“ជីវិតរបស់ខ្ញុំបានប្រែជាជូរចត់ និងលំបាក”*។

លោកស្រី ផុម អួន [Phom Oun] ក៏បដិសេធមិនព្រមរៀបការជាមួយបុរសដែលម្តាយរបស់គាត់ជ្រើសរើសឱ្យគាត់ដែរ ហើយបន្ទាប់មកប្អូនស្រីគាត់ត្រូវបានបង្ខំឱ្យរៀបការជាមួយបុគ្គលនោះទៅ[៥១]។

*ខ្ញុំចង់ក្លាយជាគ្រូពេទ្យ។ ព្រោះខ្ញុំមានសាច់ញាតិច្រើនណាស់ដែលធ្វើជាគ្រូពេទ្យ។ ឪពុកខ្ញុំមិនជំទាស់នឹងការសម្រេចចិត្តរបស់ខ្ញុំទេ ប៉ុន្តែម្តាយខ្ញុំហាក់មិនពេញចិត្តទេ ហើយជំនួសមកវិញ គាត់ចង់ឱ្យខ្ញុំរៀបការ។ គាត់ប្រាប់ខ្ញុំឱ្យរៀបការជាមួយបុរសដែលគាត់ពេញចិត្តចង់បានជាកូនប្រសារ ប៉ុន្តែ ខ្ញុំមិនយល់ព្រមទេ។ ដូច្នេះ គាត់បានបង្ខំប្អូនស្រីរបស់ខ្ញុំឱ្យរៀបការជាមួយបុរសនោះជំនួសខ្ញុំវិញ។*

ស្ទើរតែគ្មានជម្រើសទៅហើយសម្រាប់ស្ត្រីដែលអាចនៅលីវបានមុនរបបខ្មែរក្រហម។ ស្ត្រីត្រូវគេរំពឹងថានឹងធ្វើតាមការសម្រេចចិត្តរបស់ឪពុកម្តាយខ្លួនចំពោះការរៀបការ និងការមានកូន។ ភារកិច្ចទាំងនេះត្រូវគេចាត់ទុកថាជាភារកិច្ចសំខាន់បំផុតមួយចំនួនក្នុងនាមជាកូនស្រី។

*[រូបភាព]*

លោកស្រី ជូ ជួប [Chou Choub] មកពីខេត្តបាត់ដំបង ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

[Chapter 5]

## ជំពូកទី ៥៖ អាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម

គ្មានវិធីរៀបអាពាហ៍ពិពាហ៍ជាប្រព័ន្ធនោះទេក្នុងអំឡុងរបបខ្មែរក្រហម ប៉ុន្តែវិធីដែលស្ត្រីរៀបការគឺខុសៗគ្នា[៦៨]។ ក្នុងចំណោមស្ត្រី ១២១ នាក់ដែលបានសម្ភាសនៅក្នុងការស្រាវជ្រាវនេះ ស្ត្រី ៣១ នាក់ (២៦%) បានរៀបការនៅក្នុងរបបខ្មែរក្រហម។ ស្ត្រីខ្លះបានរៀបការជាមួយគូស្នេហ៍របស់ខ្លួន ខ្លះឪពុកម្តាយជាអ្នករៀបចំឱ្យបន្ទាប់ពីមានការអនុញ្ញាតពីខ្មែរក្រហម ឬខ្លះត្រូវបានបង្ខំឱ្យរៀបការជាមួយជនចម្លែកដោយពួកខ្មែរក្រហម។

### ការអនុញ្ញាតដោយពួកខ្មែរក្រហម

ស្ត្រីជាច្រើននៅក្នុងការសិក្សានេះបានរាយការណ៍ថា មានស្ត្រីនៅលីវជាច្រើនដែលចង់រៀបការនៅក្នុងរបបខ្មែរក្រហម ដោយសារតែឋានៈជាប្រពន្ធនឹងកាត់បន្ថយបន្ទុកការងាររបស់គាត់ និងអាចជួយធានាឱ្យស្ត្រីនូវឯកសិទ្ធិស្នាក់នៅជិតឪពុកម្តាយរបស់គាត់ ជាពិសេសម្តាយរបស់គាត់។ តាមប្រពៃណីខ្មែរ កូនស្រីទទួលបន្ទុកមើលថែទាំឪពុកម្តាយ ដូច្នេះស្ត្រីនៅលីវជាច្រើនសុខចិត្តរៀបការក្នុងអំឡុងរបបខ្មែរ ក្រហម។ ទោះជាយ៉ាងណា ការយល់ព្រមនេះមិនមែនជាជម្រើសអស្ចារ្យនោះទេ ហើយសំណើ ឬការលើកទឹកចិត្តឱ្យរៀបការបែបនោះត្រូវបានជំរុញដោយការចង់រស់រាន និងរស់នៅក្នុងពេលដ៏គួរឱ្យភ័យខ្លាចមួយនេះ។

លោកស្រី ស្វាយ សារិន [Svay Sarin] អាយុ ៦៣ ឆ្នាំ ដែលរស់នៅក្នុងខេត្តកណ្តាលក្នុងរបបខ្មែរក្រហម គឺជាស្ត្រីម្នាក់ដែលបានជ្រើសរើសរៀបការ[៦៩]។

*ខ្ញុំពិតជាចង់រៀបការណាស់ក្នុងរបបខ្មែរក្រហម។ ប៉ុន្តែ ពួកគេអនុញ្ញាតឱ្យតែមនុស្សអាយុចាប់ពី ២៧ ទៅ ៣០ ឆ្នាំប៉ុណ្ណោះ។ ខ្ញុំមានអាយុតិច ដូច្នេះគេមិនអនុញ្ញាតទេ។ ខ្ញុំចង់រៀបការព្រោះបើនរណាម្នាក់បានរៀបការ ពួកគេអាចគេចផុតពីពលកម្មលំបាកៗ ហើយពួកគេត្រូវបានអនុញ្ញាតឱ្យស្នាក់នៅជាមួយឪពុកម្តាយខ្លួននៅក្នុងភូមិបានទៀត។*

ទាំងបុរស និងស្ត្រីដែលត្រូវបានសម្ភាសបានលើកឡើងស្រដៀងគ្នា។ ខ្មែរក្រហមអនុញ្ញាតឱ្យគូស្វាមីភរិយាមានឯកសិទ្ធិមួយចំនួន ដែលទាក់ទាញឱ្យស្ត្រីនៅលីវដាក់សំណើសុំរៀបការ។ អ្នកផ្តល់បទសម្ភាសន៍បានរាយការណ៍ថា មិនមែនសំណើទាំងអស់របស់ស្ត្រីសុទ្ធតែត្រូវគេទទួលយកនោះទេ ហើយមានស្ត្រីជាច្រើនដែលមិនអាចរៀបការ ដោយសារខ្មែរក្រហមបដិសេធសំណើរបស់ពួកគេចោល។

ស្ត្រីជាច្រើនបានរៀបការជាមួយមនុស្សដែលខ្លួនស្រឡាញ់ ហើយស្ត្រីជាច្រើនរៀបការដោយសារអាពាហ៍ពិពាហ៍ដែលរៀបចំឡើងដោយឪពុកម្តាយរបស់ខ្លួន។ អាពាហ៍ពិពាហ៍ទាំងនេះនៅតែត្រូវបានអត់ឱនឱ្យដោយពួកខ្មែរក្រហម។ ក្នុងករណីទាំងនោះ ជំហានសម្រាប់អាពាហ៍ពិពាហ៍ធ្វើឡើងតាមប្រពៃណី ឪពុកម្តាយខាងប្រុសចូលស្តីដល់ឪពុកម្តាយខាងស្រី និងទទួលបានការយល់ព្រម ក្រោយមកត្រូវដាក់សំណើទៅ

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

ខ្មែរក្រហមដើម្បីសុំការអនុញ្ញាត ហើយដោយហេតុនេះ ត្រូវចូលរួមពិធីមង្គលការរួម។ លោកស្រី សារ៉ន ទូន [Saron Toun] គឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីដែលចង់រៀបការ និងបានរៀបការជាមួយគូស្នេហ៍របស់គាត់តាំងពីនៅរៀនម្ល៉េះ[៧០]។

*ពីរបីខែក្រោយពេលពួកខ្មែរក្រហមកាន់អំណាច ខ្ញុំបានរៀបការ។ គ្មាននរណាម្នាក់បង្ខំខ្ញុំឱ្យរៀបការនោះទេ។ ឪពុករបស់ប្តីខ្ញុំបានសួរឪពុកម្តាយខ្ញុំថាតើខ្ញុំយល់ព្រមរៀបការជាមួយគាត់ឬអត់។ ម្តាយខ្ញុំបានយល់ព្រមជំនួសខ្ញុំ ព្រោះគាត់ប្រហែលជាដឹងថា ខ្ញុំត្រូវគេណែនាំឱ្យផ្លាស់ទីទៅតំបន់មួយទៀតហៅថា ភូមិអូតាគី។ បើសិនខ្ញុំរៀបការ ខ្ញុំអាចនៅក្នុងភូមិនេះជាមួយឪពុកម្តាយខ្ញុំបាន។ ខ្ញុំមិនចង់រស់នៅបែកពីឪពុកម្តាយ ពីក្រុមគ្រួសារខ្ញុំទេ។ លើសពីនេះទៀត ខ្ញុំបានស្គាល់ប្តីរបស់ខ្ញុំតាំងពីខ្ញុំនៅរៀនម្ល៉េះ ដូច្នេះខ្ញុំបានទទួលសំណើ។ ការរៀបការមិនមែនជាបញ្ហាធ្ងន់ធ្ងរទេ ហើយខ្មែរក្រហមបានអនុញ្ញាតឱ្យប្តីខ្ញុំរៀបការជាមួយខ្ញុំ។ គឺដូចគ្នានឹងគូស្វាមីភរិយាផ្សេងទៀតដែរដែលពួកគេចង់រៀបការ ហើយសុំពួកខ្មែរក្រហម។ ខ្ញុំបានរៀបការនៅអាយុប្រហែល ១៨ឆ្នាំ ប្រហែលជានៅឆ្នាំ ១៩៧៦។ នោះគឺជាអាពាហ៍ពិពាហ៍ដំបូងដែលរៀបចំដោយពួកខ្មែរក្រហម និងមានគូស្វាមីភរិយាចំនួន ២៤ គូ។*

តាម_របៀបស្រដៀងគ្នានេះ លោកស្រី ស៊ិន សារ៉េត [Sin Sareth] ក៏បានរៀបការជាមួយបុរសម្នាក់ដែលឪពុកម្តាយគាត់បានយល់ព្រម និងពួកខ្មែរក្រហមបានយល់ព្រមចំពោះការស្នើសុំរបស់ពួកគេដែរ[៧១]។

*ប្តីរបស់ខ្ញុំបានសុំឱ្យចាស់ទុំរៀបចំមង្គលការគាត់ជាមួយខ្ញុំ។ គាត់បានសួរឪពុកម្តាយខ្ញុំមុន បន្ទាប់មកឪពុកម្តាយរបស់ភាគីទាំងពីរបានព្រមព្រៀងគ្នា ហើយខ្ញុំក៏បានទទួលយកការផ្តល់ឱ្យនេះផងដែរ។ នៅពេលនោះ ខ្ញុំមិនមានបុរសពិសេសណាម្នាក់ឡើយ។ ប្តីរបស់ខ្ញុំស្គាល់ខ្ញុំ ព្រោះនៅពេលនោះ យើងធ្វើការជាមួយគ្នានៅក្នុងកងយុវជន។ ប៉ុន្តែតាមពិត កងរបស់គាត់នៅមួយចំហៀងភូមិខាងនេះ ឯខ្ញុំវិញនៅមួយចំហៀងភូមិខាងនោះ។ ទោះយ៉ាងណា គាត់ស្គាល់ខ្ញុំខ្លះដែរ។ ប្តីខ្ញុំបានស្នើសុំទៅខ្មែរក្រហមដើម្បីអនុញ្ញាតឱ្យពួកយើងបានរៀបការនៅក្នុងឆ្នាំ ១៩៧៦។ គឺនៅក្នុងខែ មិថុនា។ (ចំណាំ៖ ប្តីរបស់គាត់និយាយថា គាត់រៀបការនៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ១៩៧៦)។ មួយថ្ងៃមុនថ្ងៃរៀបការរបស់យើង ខ្មែរក្រហមបានប្រកាសថា បើមាននរណាម្នាក់ចង់រៀបការ គួរមកដាក់ពាក្យស្នើចុះ។ ដូច្នេះ ឪពុកម្តាយយើងបានពិភាក្សាគ្នាអំពីរឿងនេះ ហើយយើងបានដាក់ពាក្យស្នើទៅ។ នៅពេលនោះ យើងបានហូបអាហារជុំគ្នា ហើយខ្ញុំបានរស់នៅក្នុងកងយុវជន។*

លោកស្រី ស៊ិន ត្រូវបានសម្ភាសពីរដង។ លើកទីមួយគឺតែជាមួយគាត់ម្នាក់ឯងប៉ុណ្ណោះ ហើយលើកទីពីរជាមួយប្តីរបស់គាត់ លោក នួន គាង [Noun Keang]។ ពួកគេបាននាំខ្ញុំទៅមើលផ្ទះរបស់ពួកគេ ដែលផ្ត

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

ល់ដោយ ពួកខ្មែរក្រហមក្រោយពេលមង្គលការរបស់ពួកគេត្រូវបានយល់ព្រម។ គូស្វាមីភរិយាទាំងអស់ដែលបានរៀបការនៅថ្ងៃនោះជាមួយ លោកស្រី ស៊ិន ត្រូវគេផ្តល់ឱ្យនូវខ្ទមមួយដែលសង់ឡើងជាជួរក្បែរ_ទន្លេ។ លោក នួន បាននិយាយថា៖ *"យើងដឹងថា ការរស់នៅក្នុងកងយុវជនពិតជាលំបាកណាស់។ បើយើងបានរៀបការ ជីវិតយើងនឹងមានភាពងាយស្រួលជាង។ អ្នកដែលរៀបការហើយអាចនៅផ្ទះ មិនចាំបាច់ត្រូវទៅធ្វើការនៅទីឆ្ងាយ។ ដូច្នេះ ខ្ញុំបានស្នើសុំខ្មែរក្រហមរៀបការជាមួយគាត់ទៅ"*[៧២]។

លោកស្រី សែន ប៉ូល [Sen Pual] អាយុ ៥៧ ឆ្នាំ ក៏បានរៀបការដោយសារការរៀបចំរបស់ឪពុកម្ដាយផងដែរ[៧៣]។

> *មុនពេលខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំនៅលីវទេ ព្រោះខ្ញុំនៅក្មេង។ ក្នុងអំឡុងរបបខ្មែរក្រហម ខ្មែរក្រហមមិនបានបង្ខំខ្ញុំឱ្យរៀបការឡើយ។ ប៉ុន្តែ ខ្ញុំបានរៀបការដោយសារការរៀបចំរបស់ឪពុកម្ដាយទាំងសងខាង។ យើងស្រឡាញ់គ្នា ដូច្នេះគ្មានការបង្ខំឱ្យរៀបការបានកើតឡើងចំពោះខ្ញុំឡើយ។ គាត់រស់នៅក្នុងភូមិតែមួយ ហើយយើងស្គាល់គ្នាទៅវិញទៅមក។ ឪពុកម្ដាយខ្ញុំបានជូនដំណឹងដល់ខ្មែរក្រហម ហើយពួកគេបញ្ជាឱ្យពួកយើងរៀបការនៅកន្លែងរបស់ពួកគេ។ ដូច្នេះ យើងត្រូវរៀបការនៅកន្លែងរបស់ខ្មែរក្រហម។ នោះគឺជាបញ្ហា។ គូស្វាមីភរិយាប្រហែលជា ២០ ទៅ ៥០ គូបានរៀបការនៅថ្ងៃនោះ។ មានពិធីជប់លៀងតូចមួយក្នុងពិធីអាពាហ៍ពិពាហ៍នោះ ហើយឪពុកម្ដាយខ្ញុំ ឪពុកម្ដាយខាងប្ដីរបស់ខ្ញុំ ព្រមទាំងមេដឹកនាំថ្នាក់ស្រុកក្នុងតំបន់នោះក៏បានចូលរួមផងដែរ។*
>
> *ក្នុងចំណោមគូស្វាមីភរិយាដែលបានរៀបការជាមួយយើង គ្មាននរណាម្នាក់ត្រូវគេបង្ខំឡើយ។ បន្ទាប់ពីមង្គលការពួកយើង ខ្មែរក្រហមបានចាប់ផ្តើមប្រព័ន្ធអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងភូមិរបស់ខ្ញុំ។ ពួកគេខ្លះបានបដិសេធ ប៉ុន្តែគ្មានការផ្តន្ទាទោសចំពោះពួកគេឡើយ។ ភូមិដែលខ្ញុំរស់នៅមិនសូវតឹងរឹងខ្លាំងដូចនៅកន្លែងផ្សេងទៀតទេ។ យើងនៅតែជាប្តីប្រពន្ធនឹងគ្នា និងបន្តស្រឡាញ់គ្នាដដែល។*

ដោយមិនគិតពីទីតាំង ស្ត្រីនៅលីវជាច្រើនអាចប្រហែលជាចង់រៀបការក្នុងអំឡុងរបបខ្មែរក្រហម និងស្នើសុំខ្មែរក្រហមឱ្យអនុញ្ញាតឱ្យពួកគេរៀបការ។ លោកស្រី សាន វង្ស [San Vong] អាយុ ៥៧ ឆ្នាំ ក៏បានរៀបការក្នុងអំឡុងរបបខ្មែរក្រហមផងដែរជាមួយនឹងគូស្វាមីភរិយា ១០០ គូ។ *"គូស្វាមីភរិយាទាំងអស់បានដាក់ពាក្យសុំរៀបការ ហើយខ្មែរក្រហមបានយល់ព្រម"*[៧៤]។ លោកស្រី ប៉ូ ចាន់ណាក់ [Po Channak] និស្សិតស្រីម្នាក់ដែលធ្វើការជាជំនួយការស្រាវជ្រាវសម្រាប់ការសិក្សានេះ បានឱ្យដឹងថា *"ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំងដោយដឹងថា ស្ត្រីជាច្រើនអាចរៀបការជាមួយមនុស្សដែលខ្លួនស្រឡាញ់បាន។ នៅខេត្តបាត់ដំបង មនុស្សភាគច្រើនដែលខ្ញុំបានជួបនិយាយថា ពួកគេបានរៀបការក្នុងអំឡុងរបបខ្មែរក្រហម ប៉ុន្តែខ្មែរក្រហមមិនបានបង្ខំពួកគេទេ។ ខ្ញុំក៏បានជួបអ្នកខ្លះទៀតនៅក្នុងខេត្តតាកែវសម្រាប់ការស្រាវជ្រាវរៀបចំនេះ*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*ហើយពួកគេក៏បាននិយាយថា ពួកគេមិនត្រូវគេបង្ខំឱ្យរៀបការនៅក្នុងអំឡុងរបបខ្មែរក្រហមដែរ។ នេះគឺខុសពីអ្វីដែលខ្ញុំបានរៀននៅវិទ្យាល័យ និងអ្វីដែលប្រព័ន្ធផ្សព្វផ្សាយបានលើកឡើង។ ខ្ញុំធ្លាប់គិតថា អាពាហ៍ពិពាហ៍ទាំងអស់ត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹងដោយពួកខ្មែរក្រហម ប៉ុន្តែឥឡូវនេះខ្ញុំបានជួប ជាមួយស្ត្រីទាំងនោះដែលចង់រៀបការ និងបានរៀបការនៅក្នុងអំឡុងរបបខ្មែរក្រហម*[៧៥]។

អាពាហ៍ពិពាហ៍ដែលត្រូវបានអនុញ្ញាតដោយខ្មែរក្រហម ដោយឆ្លើយតបតាមសំណើរបស់គូស្វាមីភរិយាត្រូវបានរាយការណ៍នៅក្នុងខេត្តកំពង់ចាម បាត់ដំបង និងសៀមរាប។ នៅក្នុងខេត្តរតនគិរី យើងមិនបានជួបស្ត្រីណាដែលបានរៀបការក្នុងអំឡុងរបបខ្មែរក្រហម ដោយការដាក់ពាក្យស្នើសុំទៅខ្មែរក្រហមឡើយ ប៉ុន្តែ លោកស្រី ឡេង វុធ [Leng Vuth] បាននិយាយថា៖ *"ខ្មែរក្រហមបានសួរយោបល់ខ្ញុំថាព្រមទទួលយកការផ្តល់ឱ្យនេះឬទេ ដូច្នេះខ្ញុំក៏បានយល់ព្រម។ គេផ្តល់ជម្រើសឱ្យខ្ញុំបដិសេធដែរ ប៉ុន្តែខ្ញុំនិយាយថាទេ ខ្ញុំព្រមរៀបការ។ មានគូស្វាមីភរិយា ៧០ គូដែលបានរៀបការស្របពេលជាមួយគ្នាខ្ញុំនោះ។ ក្រោយពេលខ្ញុំរៀបការរួច គូស្វាមីភរិយាប្រមាណជា ៣០០ គូបានរៀបការរួមគ្នា។ មានស្ត្រីច្រើនណាស់ដែលបានស្នើសុំរៀបការពីពួកខ្មែរក្រហម"*[៧៦]។

**អាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្មែរក្រហម**

ផ្នែកនេះទាក់ទងទាំងស្រុងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងរបបខ្មែរក្រហម[៧៧]។ មានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាច្រើន ស្ត្រីមិនត្រូវបានផ្តល់ជម្រើសឱ្យនោះទេ ប៉ុន្តែត្រូវធ្វើតាមការណែនាំរបស់ពួកខ្មែរក្រហម។ មួយចំនួននៃស្ត្រីទាំងនោះបានរៀបការមុនរបបខ្មែរក្រហម ប៉ុន្តែបានបាត់បង់ប្តីរបស់ខ្លួន រីឯខ្លះទៀតនៅលីវនៅពេលខ្មែរក្រហមឡើងកាន់អំណាច។ ទោះជាយ៉ាងណា ស្ត្រីមួយចំនួនដែលត្រូវគេបង្ខំឱ្យរៀបការនេះព្រមទទួលយកបញ្ជារបស់ពួកខ្មែរក្រហម ដើម្បីជាមធ្យោបាយកាត់បន្ថយកាតព្វកិច្ចធ្វើការងារលំបាកៗរបស់ខ្លួន។ ស្ត្រីជាច្រើន ក៏ដូចជាឪពុកម្តាយរបស់ពួកគេដែរ គិតថា អាពាហ៍ពិពាហ៍អាចនាំមកនូវការការពារ និងសន្តិសុខមួយចំនួនក្នុងអំឡុងពេលសង្គ្រាមបែបនោះ។

ជាទូទៅ អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាផ្នែកមួយនៃមធ្យោបាយមជ្ឈការរបស់ខ្មែរក្រហមដើម្បីដកហូតសិទ្ធិស្វ័យភាពរបស់ស្ត្រី និងដើម្បីគ្រប់គ្រងលក្ខណៈផ្លូវភេទរបស់ស្ត្រី។ ទង្វើនេះគឺជាការរំលោភលើសិទ្ធិរបស់ឪពុកម្តាយក្នុងការជ្រើសរើសអនាគតប្តីឱ្យកូនស្រីរបស់ខ្លួន តាមប្រពៃណីខ្មែរ[៧៨]។ ស្ត្រីដែលត្រូវគេបញ្ជាឱ្យរៀបការ គឺគ្រាន់តែបានទទួលដំណឹងពីខ្មែរក្រហម ហើយបន្ទាប់មកត្រូវបញ្ជាឱ្យទៅចូលរួមក្នុងពិធីមង្គលការនោះតែម្តង។ យោងតាមការសិក្សានេះ ក្នុងករណីភាគច្រើននៃអាពាហ៍ពិពាហ៍ដោយបង្ខំ ស្ត្រីត្រូវគេបញ្ជាឱ្យចូលរួមប្រជុំ ឬពិធីរៀបអាពាហ៍ពិពាហ៍នៅពេលព្រឹក ហើយបន្ទាប់មក ក៏បានរៀបការរួចនៅត្រឹមពេលព្រលប់។ ដូច្នេះ ការជួបនឹងគូអនាគតរបស់ខ្លួនដំបូង និងការរៀបមង្គលការបានកើតមានឡើងនៅថ្ងៃដដែលនោះតែម្តង។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

ស្ត្រីជាច្រើនបានរាយការណ៍ថា ពួកគេមានការខកចិត្ត និងតូចចិត្តយ៉ាងខ្លាំងនៅពេលពួកគេត្រូវបានបញ្ជាឱ្យរៀបការផ្ទុយនឹងឆន្ទៈរបស់ខ្លួនដូចនេះ។ លោកស្រី រ៉ុន [Ron] បាននិយាយថា គាត់ខឹងសម្បារយ៉ាងខ្លាំងនៅពេលគេបង្ខំគាត់ឱ្យរៀបការនោះ[៧៩]។

*នៅពេលដែលខ្ញុំត្រូវគេបង្ខំឱ្យរៀបការ ខ្ញុំពិតជាខឹងខ្លាំងណាស់។ ដោយសារខ្ញុំមិនបានស្រឡាញ់ប្តីរបស់ខ្ញុំផង ប៉ុន្តែខ្មែរក្រហមនៅតែបង្ខំខ្ញុំទៀត។ ពិធីអាពាហ៍ពិពាហ៍ត្រូវបានរៀបចំនៅក្នុងភូមិនេះ។ ខ្ញុំមិនសប្បាយចិត្តទេ ព្រោះខ្ញុំមិនស្រឡាញ់បុរសម្នាក់នោះផង។ នៅថ្ងៃដែលខ្ញុំរៀបការនោះ គេគ្រាន់តែហៅខ្ញុំខណៈពេលខ្ញុំកំពុងធ្វើការនៅឯស្រែឱ្យមកចូលរួមក្នុងពិធីនោះប៉ុណ្ណោះ ដោយសារពួកគេរៀបចំមង្គលការឱ្យខ្ញុំ។ ខ្ញុំមិនចង់រៀបការទេ។ ប៉ុន្តែ ខ្ញុំត្រូវតែធ្វើតាមបញ្ជារបស់ខ្មែរក្រហម។ បើមិនដូច្នោះទេ ខ្ញុំដឹងថា ខ្មែរក្រហមនឹងសម្លាប់ខ្ញុំ ដូច្នេះ ខ្ញុំខ្លាចខ្លាំងណាស់។*

លោកស្រី នន់ នួន [Non Nuon] ត្រូវគេបង្ខំឱ្យរៀបការចំនួនបីដងក្នុងអំឡុងរបបខ្មែរក្រហម ជាមួយនឹងបុរសបីនាក់ផ្សេងគ្នា[៨០]។ គាត់ត្រូវគេបង្ខំ និងគំរាមកំហែង ហើយគាត់ត្រូវតែចាប់ផ្តើមជីវិតថ្មីជាមួយនឹងប្តីរបស់គាត់នៅឯផ្ទះថ្មី ដែលពួកខ្មែរក្រហមផ្តល់ឱ្យនៅលើយប់ថ្ងៃរៀបការនោះ។ ស្ត្រីមួយចំនួនបានរងការគំរាមកំហែងថានឹងត្រូវគេសម្លាប់ ប្រសិនបើពួកគេបដិសេធមិនទទួលយកការផ្តល់ឱ្យនេះ។ ស្ត្រីមួយចំនួនបាននិយាយថា វាមិនត្រឹមតែជាការគំរាមកំហែងដល់ជីវិតនាងប៉ុណ្ណោះទេ ប៉ុន្តែជាការគំរាមកំហែងដល់ក្រុមគ្រួសារទាំងមូលរបស់គាត់ទៀតផង បើសិនជាគាត់បដិសេធនឹងបញ្ជារបស់ពួកខ្មែរក្រហម។

លោកស្រី ពូត មេរី [Pout Mery] បច្ចុប្បន្នអាយុ ៦២ ឆ្នាំ ត្រូវគេបង្ខំឱ្យរៀបការជាមួយបុរសម្នាក់ដែលរស់នៅក្នុងភូមិជាមួយគ្នានោះ និងបានរៀបការនៅពេលដូចគ្នាជាមួយនឹងគូស្វាមីភរិយា ៨ គូផ្សេងទៀតផងដែរ។ គាត់ត្រូវពួកខ្មែរក្រហមបង្ខំចំនួនពីរដង ប៉ុន្តែលើកទីមួយ ខ្មែរក្រហមបានសួរយោបល់របស់គាត់ ហើយគាត់បានបដិសេធ។ លើកទីពីរ គឺមួយខែបន្ទាប់ពីការបដិសេធរបស់គាត់ ហើយទីបំផុតគាត់ក៏បានរៀបការ។ ខ្មែរក្រហមបានហៅគាត់ឱ្យទៅបន្ទប់ប្រជុំ ប៉ុន្តែគាត់មិនដឹងថាមានរឿងអ្វីកើតឡើងនោះទេ[៨១]។

*ខ្មែរក្រហមបានណែនាំគូស្វាមីភរិយាទាំងអស់នៅទីនោះឱ្យចាប់ដៃគ្នា និងធ្វើការព្រមព្រៀងថានឹងស្រឡាញ់គ្នាពីពេលនេះតទៅ រួចក៏ចប់ទៅ។ ពិធីអាពាហ៍ពិពាហ៍របស់ខ្ញុំគឺធ្វើឡើងបែបនោះ។*

តាមពិត ប្តីរបស់គាត់ ដែលជាមេដឹកនាំនៅក្នុងភូមិនោះ ស្រឡាញ់គាត់ ហើយប្តីគាត់បានជ្រើសរើសគាត់ជាប្រពន្ធ ខណៈពេលពួកគេនៅក្នុងពិធីអាពាហ៍ពិពាហ៍។ គាត់មិនដែលគិតអំពីរឿងស្នេហានោះទេ មិនដឹងថាបុរសប្រភេទណាដែលគាត់អាចនឹងស្រឡាញ់នោះដែរ។ បន្ទាប់ពីពិធីអាពាហ៍ពិពាហ៍របស់គាត់ ឪពុកម្តាយគាត់បានសម្លាប់មាន់មួយសម្រាប់កូនស្រីឱ្យមានសុភមង្គលនៅក្នុងគ្រួសារថ្មីរបស់គាត់។ ប្តីរបស់គាត់លោក ចឹម ជួង [Cherm Choung] អាយុ ៦៦ ឆ្នាំ គឺជាមេដឹកនាំក្នុងភូមិ និងគ្រប់គ្រងមនុស្សជាងសាមសិប

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

នាក់នៅក្នុងរបបខ្មែរក្រហម។ លោក បាននិយាយថា៖ *"ដោយសារតែខ្ញុំជាមេដឹកនាំ គ្មាននរណាម្នាក់ឆែកឆេរផ្ទះរបស់ខ្ញុំទេ ដូច្នេះខ្ញុំអាចលាក់ម្ហូបអាហារជាច្រើននៅក្នុងផ្ទះរបស់ខ្ញុំ។ ពេលពួកយើងដឹកអ៊ុសទៅភូមិមួយទៀត យើងអាចប្តូរអ៊ុសទាំងនោះយកអង្ករ និងសាច់ជាសម្ងាត់ ដូច្នេះ យើងគ្មានបញ្ហារឿងម្ហូបអាហារនោះទេ"*[៨២]។ ដោយសារតែគាត់អាចជ្រើសរើសយកប្រពន្ធរបស់គាត់បាន គាត់បានមើលថែប្រពន្ធរបស់គាត់យ៉ាងខ្លាំងអំឡុងពេលមានផ្ទៃពោះ និងធានាយ៉ាងណាឲ្យប្រពន្ធរបស់គាត់មានម្ហូបអាហារហូប។

អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានដាក់ចេញទាំងលើបុរស និងស្ត្រី។ លោកស្រី ទូច អួន [Touch Oun] ត្រូវគេបង្ខំឲ្យរៀបការជាមួយបុរសម្នាក់ដែលមិនចង់រៀបការជាមួយគាត់ ប៉ុន្តែ ទោះជាយ៉ាងណាគាត់មានកូនម្នាក់នៅក្នុងរបបនោះ[៨៣]។

> *ខ្ញុំត្រូវគេបង្ខំឲ្យរៀបការនៅឆ្នាំ ១៩៧៥ ដោយពួកខ្មែរក្រហម។ គូស្វាមីភរិយា ១០ គូបានរៀបការស្របពេលជាមួយខ្ញុំដែរ។ ប្តីរបស់ខ្ញុំមិនសប្បាយចិត្តទេ ហើយខ្ញុំក៏មិនសប្បាយចិត្តដែរ។ ខ្ញុំយំនៅពេលគេបង្ខំខ្ញុំឲ្យរៀបការ។ យើងមិនដែលស្គាល់គ្នាទេមុនពេលរៀបការ។ គាត់រស់នៅជាប់មាត់ទន្លេ ឯខ្ញុំរស់នៅឆ្ងាយពីទន្លេ។ យើងមិនដែលជួបគ្នាឡើយមុនពេលរៀបការនោះ។ នៅពេលយើងរៀបការ គាត់គឺជាបុរសពោះម៉ាយ គាត់បានរៀបការម្តងរួចមកហើយ។ ប៉ុន្តែ ក្រោយពេលប្រពន្ធគាត់សម្រាលកូន ទាំងម្តាយ និងកូនក៏ស្លាប់បាត់ទៅ។*
>
> *មង្គលការរបស់ខ្ញុំកើតមានភ្លាមៗ និងធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលណាស់។ ថ្ងៃមួយ ខ្មែរក្រហមបានហៅខ្ញុំ ហើយពួកគេបញ្ជាឲ្យខ្ញុំរៀបការ។ ពួកគេបានប្រាប់ខ្ញុំនៅថ្ងៃរៀបការនោះ។ ខ្មែរក្រហមបានប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំគឺម្នាក់នេះ ហើយនេះគឺជាឈ្មោះរបស់គាត់ ហូរហែរមក។ យើងមិនអាចបដិសេធបានទេ យើងត្រូវតែធ្វើតាមបញ្ជាពួកគេ។ នៅពេលនោះ ខ្ញុំនិយាយអ្វីមិនចេញទាំងអស់ ព្រោះខ្ញុំខ្លាចខ្លាំងណាស់។ ក្រោយពេលខ្ញុំរៀបការរួច ស្វាមីខ្ញុំនឹងធ្វើបាបខ្ញុំ ប្រសិនបើខ្ញុំមិនយល់ព្រមដេកជាមួយគាត់ទេ ដូច្នេះ ខ្ញុំត្រូវតែអត់ធ្មត់។ ក្រោយពេលយើងបានកូនមួយ គាត់ប្រែជាមនុស្សល្អ ហើយគាត់ស្រឡាញ់កូនយើង និងខ្ញុំណាស់។*

លោកស្រី ទូច [Touch] បានជួបជាមួយខ្ញុំពីរដង ហើយនៅពេលសម្ភាសន៍លើកទីពីរ យើងបាននិយាយយ៉ាងយូរ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ គាត់បានចែករំលែករឿងឪពុករបស់គាត់ ដែលលោកក៏បានរៀបការក្នុងអំឡុងរបបខ្មែរក្រហមផងដែរ នៅពេលគាត់អាយុ ៦០ ឆ្នាំហើយនោះ ជាមួយនឹងស្ត្រីមេម៉ាយអាយុ ៥៥ ឆ្នាំម្នាក់។ ស្ត្រីមេម៉ាយនោះមានកូន និងចង់បានប្តីម្នាក់ដើម្បីបង្កើតគ្រួសារ ដើម្បីកាត់បន្ថយបន្ទុកការងារ។ គាត់គឺជា "ប្រជាជនថ្មី" និងចង់រៀបការជាមួយនរណាម្នាក់ដែលជាប្រជាជនមូលដ្ឋាន។ ពួកគេបានរៀបការនៅឃ្លាំង ដោយមានគូស្វាមីភរិយា ១០០ គូផ្សេងទៀត។ ឪពុករបស់គាត់ក៏ចង់រៀបការដែរ។ កូនស្រីរបស់គាត់សុំកុំឲ្យគាត់រៀបការម្តងទៀត ព្រោះគាត់ចាស់ណាស់ទៅហើយ។ លោកស្រី ទូច [Touch]

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

បាននិយាយថា៖ *“ឪពុកខ្ញុំបាននិយាយថា “បើពុករៀបការ យ៉ាងហោចណាស់ពុកមានអ្នកមើលថែទាំពេលពុកកាន់តែចាស់ ឬឈឺថ្កាត់”។ ដូច្នេះ បងស្រីខ្ញុំ និងខ្ញុំបានអនុញ្ញាតឲ្យគាត់រៀបការជាមួយស្ត្រីម្នាក់នោះទៅ”*[៨៤]។

ជាញឹកញាប់ គេមិនអនុញ្ញាតឲ្យស្ត្រីនៅលីវទេ បើស្ត្រីនោះមានអាយុគ្រប់គ្រាន់ល្មមនឹងរៀបការហើយនោះ ហើយគាត់ត្រូវចាប់ផ្តើមគ្រួសារបីទោះជាគេមិនច្បាស់ថាតើខ្មែរក្រហមជ្រើសរើសស្ត្រីឲ្យរៀបការដូចម្តេចក្តី។ លោកស្រី នូ នួន ត្រូវគេបង្ខំឲ្យរៀបការបីដងក្នុងអំឡុងរបបខ្មែរក្រហម។ គាត់បានបដិសេធពីរដង ប៉ុន្តែលើកទីបី គាត់មិនអាចគេចផុតទេ ហើយក៏ត្រូវតែរៀបការ។ គាត់យំយ៉ាងខ្លាំង ព្រោះគាត់មិនចង់រៀបការ។ ខ្មែរក្រហមនិយាយជាមួយគាត់ថា គាត់អាយុ ២៧ ឆ្នាំហើយ ដូច្នេះត្រូវតែរៀបការនឹងនរណាម្នាក់[៨៥]។

ស្ត្រីមេម៉ាយក៏ត្រូវគេបង្ខំឲ្យរៀបការម្តងទៀតដែរ។ លោកស្រី ឡេង វុធ [Leng Vuth] បានរៀបការរួចហើយនៅមុនរបបខ្មែរក្រហម និងបានសម្រាលកូនបីដង។ *“នៅពេលខ្ញុំមានផ្ទៃពោះក្នុងអំឡុងរបបខ្មែរក្រហម ប្តីរបស់ខ្ញុំត្រូវគេសម្លាប់នៅឆ្នាំ ១៩៧៨ ហើយក្រោយមកខ្ញុំត្រូវគេបង្ខំឲ្យរៀបការនៅដើមឆ្នាំ ១៩៧៩។ ខ្ញុំត្រូវគេបង្ខំជាមួយនឹងគូស្វាមីភរិយា ៨០ គូផ្សេងទៀត”*[៨៦]។ ប៉ុន្តែគាត់មិនបានស្នាក់នៅជាមួយប្តីថ្មីទេ ព្រោះគាត់ទៅធ្វើការនៅកន្លែងឆ្ងាយមួយទៀត។ ពួកគេបានចែកផ្លូវគ្នាភ្លាមៗក្រោយពេលដាច់របបខ្មែរក្រហម ហើយគាត់មិនបានរៀបការម្តងទៀតទេរហូតមកដល់ឥឡូវនេះ។ លោកស្រី ម៉យ រ៉ុម [Moy Rom] ក៏ត្រូវខ្មែរក្រហមបង្ខំឲ្យរៀបការដែរបន្ទាប់ពីប្តីរបស់គាត់ដែលជាអតីតទាហាន លន់ នល់ ត្រូវគេសម្លាប់[៨៧]។

> *នៅពេលកូនប្រុសខ្ញុំបានអាយុមួយឆ្នាំ ខ្ញុំត្រូវពួកខ្មែរក្រហមបញ្ជាឲ្យរៀបការ។ ខ្ញុំមិនចង់រៀបការទេ។ ខ្ញុំខ្លាចថាអនាគតប្តីរបស់ខ្ញុំនឹងធ្វើបាបកូនពីប្តីមុនរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំបានបដិសេធ។ ពេលនោះគឺពេលព្រឹកដែលគេប្រាប់ខ្ញុំឲ្យមករៀបការ។ នៅពេលនោះ ប្រធានភូមិបានចូលមកនិយាយជាមួយខ្ញុំថា៖ “បើឯងមិនយល់ព្រមរៀបការជាមួយបុរសនោះទេ ឯងនឹងត្រូវគេសម្លាប់ហើយ”។ ហេតុនេះខ្ញុំគ្មានជម្រើសទេ មានតែត្រូវរៀបការជាមួយបុរសនោះ។ ខ្ញុំបានរៀបការជាមួយគាត់នៅពេលល្ងាចថ្ងៃដដែលដែលខ្ញុំត្រូវគេបញ្ជាឲ្យរៀបការនោះ។ ខ្ញុំមិនដែលសប្បាយចិត្តនឹងប្តីម្នាក់នោះទេ ហើយយើងមិនដែលនិយាយរកគ្នាទាល់តែសោះ។ ខ្ញុំគ្មានអារម្មណ៍អ្វីបន្តិចចំពោះគាត់នោះទេ។ បន្ទាប់ពីរៀបការរួច គាត់ត្រូវគេបញ្ជូនឲ្យទៅកន្លែងផ្សេងទៀត ហើយយើងមិនបានស្នាក់នៅ ឬរស់នៅជាមួយគ្នាទេ។ ប្រហែលជាតែម្តងគត់នៅរៀងរាល់បីខែដែលគាត់មកលេងខ្ញុំ។*

លោកស្រី ឆាម សាន [Chham San] អាយុ ៦៩ ឆ្នាំ បាននិយាយថា៖ *“ប្តីរបស់ខ្ញុំបានស្លាប់ដោយសារជំងឺគ្រុនចាញ់បន្ទាប់ពីគាត់ត្រូវគេបញ្ជូនទៅឲ្យធ្វើការនៅភ្នំគូលែន។ ខ្ញុំមានផ្ទៃពោះបីខែនៅពេលនោះ។ ដូច្នេះ ខ្ញុំបានក្លាយជាស្ត្រីមេម៉ាយ។ ប្រធានភូមិបានណែនាំខ្ញុំឲ្យរៀបការម្តងទៀត ប៉ុន្តែខ្ញុំនិយាយថា ខ្ញុំក្រីក្រ*



**Formatted:** Condensed by 0.5 pt

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*ណាស់ និងមិនចង់រៀបការទេ។ បន្ទាប់មក គាត់បាននិយាយថា មិនអីនោះទេ ឯងក្រ ដូច្នេះ ឯងអាចនៅជាស្ត្រីមេម៉ាយអញ្ចឹងក៏បាន’*[៨៨]។

ប្រព័ន្ធបង្កើតគូស្វាមីភរិយាថ្មីតាមរយៈការបង្ខំពីសំណាក់ខ្មែរក្រហមនេះ គឺសម្បូរបែប តែមិនមានលក្ខណៈជាប្រព័ន្ធទេ។ អាពាហ៍ពិពាហ៍ដោយបង្ខំដែលគេរកឃើញនៅក្នុងការសិក្សានេះអាចត្រូវ គេសម្គាល់ថាខុសពីអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ដោយសារតែគ្មានការចូលរួមពីឪពុកម្តាយនៅក្នុងដំណើរការនោះ ហើយគ្មានពិធីរៀបអាពាហ៍ពិពាហ៍បែបប្រពៃណីជាមួយសមាជិកគ្រួសារទេ[៨៩]។

អាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រឹមតែជាការរំលោភបំពានលើសិទ្ធិស្វ័យភាពរបស់ស្ត្រី និងសិទ្ធិជ្រើសរើសគូរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែវាប៉ះពាល់ដល់តួនាទីជាប្រពៃណីរបស់ឪពុកម្តាយក្នុងការរៀបចំអាពាហ៍ពិពាហ៍ឱ្យកូនស្រីរបស់ខ្លួនផងដែរ។ ពីក្របខ័ណ្ឌសិទ្ធិមនុស្ស អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាបទរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិជាមូលដ្ឋានជាច្រើនរបស់ស្ត្រី។ ទោះជាយ៉ាងណា រហូតមកដល់មុនរបបខ្មែរក្រហមបន្តិច ប្រពៃណីខ្មែរតម្រូវឱ្យឪពុកម្តាយជាអ្នករៀបចំមង្គលការឱ្យកូនស្រី ហើយកូនស្រីត្រូវគេរំពឹងថានឹងធ្វើតាមឪពុកម្តាយខ្លួន។ នៅក្រោមបរិបទវប្បធម៌ និងប្រពៃណីដូចនោះ អាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្មែរក្រហមចាំបាច់ត្រូវឱ្យគេយល់ថាជាបញ្ហាផ្ទាល់ខ្លួនផង និងជាបញ្ហាគ្រួសារផង ហើយទង្វើនេះលើសពីការរំលោភលើសិទ្ធិស្ត្រីទៅទៀត។ លោកស្រី សាក់ ចាន់សូនីន [Sak Chansonyn] អាយុ ៧៧ ឆ្នាំ បានរំលឹកពីការឈឺចាប់របស់គាត់ នៅពេលកូនស្រីគាត់ត្រូវគេបង្ខំឱ្យរៀបការក្នុងអំឡុងរបបខ្មែរក្រហម[៩០]។

> *“នាងយំ និងសួរខ្ញុំថាហេតុអ្វីបានជាខ្មែរក្រហមបង្ខំនាងឱ្យរៀបការ។ ខ្ញុំបានត្រឹមតែឆ្លើយប្រាប់នាងថា ល្អបំផុតមានតែឆ្លើយយល់ព្រមជាមួយខ្មែរក្រហមទៅ បើមិនដូច្នេះទេនាងនឹងត្រូវខ្មែរក្រហមសម្លាប់ជាមិនខាន។ ខ្ញុំមានអារម្មណ៍ឈឺចាប់ខ្លាំងណាស់ព្រោះខ្ញុំមិនអាចចូលរួមពិធីមង្គលការកូនស្រីរបស់ខ្លួនបាន”។*

អ្វីដែលគួរឱ្យចាប់អារម្មណ៍ ក្នុងនាមជាម្តាយ គាត់មិនខឹងនឹងខ្មែរក្រហមដែលបង្ខំកូនស្រីរបស់គាត់ឱ្យរៀបការទេ ប៉ុន្តែគាត់សោកស្តាយដែលគេមិនអនុញ្ញាតឱ្យគាត់ចូលរួមពិធីមង្គលការកូនស្រីរបស់គាត់បាន។ ការរៀបរាប់អារម្មណ៍ទាំងអស់នេះបង្ហាញពីរបៀបដែលម្តាយទទួលយកអាពាហ៍ពិពាហ៍ដោយបង្ខំរបស់កូនស្រីក្នុងអំឡុងពេលមានសង្គ្រាម។ លោក ឈួន គី អាយុ ៧៩ ឆ្នាំ ក៏បានលើកឡើងស្រដៀងគ្នាពីការសោកស្តាយនេះផងដែរថា៖ *“កូនប្រុសខ្ញុំ ហេង ត្រូវខ្មែរក្រហមបង្ខំឱ្យរៀបការ។ ជារឿងអកុសលដែលខ្ញុំមិនត្រូវបានអនុញ្ញាតឱ្យចូលរួមពិធីមង្គលការនោះ”*[៩១]។

ជាការលំបាកខ្លាំងណាស់ក្នុងការគេចពីអាពាហ៍ពិពាហ៍ដោយបង្ខំនេះ។ ប៉ុន្តែ ស្ត្រីមួយចំនួនបានរាយការណ៍ថា ពួកគេបានបដិសេធ ហើយគេក៏ព្រមទទួល។ លោកស្រី សោត សូត្រ [Shout Soat] អាយុ ៧៨ ឆ្នាំ ក៏បានរំលឹកដែរថា ទាហានខ្មែរក្រហមម្នាក់ចង់បានកូនស្រីគាត់ធ្វើជាប្រពន្ធ។ *“ខ្ញុំបានឱ្យមាសទៅ*

Deleted: អាពាហ៍ពិពាហ៍

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*គាត់ដើម្បីឲ្យគាត់លែងបង្ខំកូនស្រីខ្ញុំឲ្យរៀបការជាមួយគាត់ទៀត*"។ លោកស្រី អ៊ីរ៉ា [Era] ក៏ចងចាំឧប្បត្តិហេតុស្រដៀងគ្នាអំពីរបៀបដែលប្អូនស្រីគាត់គេចចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំនេះ[៦២]។

> *ប្រធានភូមិនោះចូលចិត្តប្អូនស្រីខ្ញុំ អ៊ីរីយ៉ា [Erya] ហើយគាត់បានសុំម្ដាយខ្ញុំឲ្យកូនប្រុសគាត់រៀបការជាមួយនាង ប៉ុន្តែម្ដាយខ្ញុំមិនយល់ព្រម។ គាត់មិនមែនជាមនុស្សចេះដឹងទេ ដូច្នេះ ម្ដាយខ្ញុំនិយាយថា នាងនៅក្មេងខ្លាំងណាស់ ទើបតែអាយុ ១៦ ឆ្នាំប៉ុណ្ណោះ ហើយនាងមិនទាន់ចង់បានប្ដីទេ។ សំណាងល្អ ខ្មែរក្រហមបានទទួលយកការបដិសេធនេះ។ នៅពេលនោះ ខ្ញុំមានអ្វីហូបដែរ ដូចជាបបរជាដើម ដោយសារតែប្រធាននោះចង់ឲ្យប្អូនស្រីខ្ញុំរៀបការជាមួយកូនប្រុសគាត់ ដូច្នេះ គាត់បានផ្ដល់ម្ហូបអាហារឲ្យខ្ញុំ។*

ដូច្នេះ ប្រសិនបើខ្មែរក្រហមបានទទួលសំណូកបែបនោះ គេក៏អាចគេចផុតពីអាពាហ៍ពិពាហ៍ដោយបង្ខំដែរ។ អាពាហ៍ពិពាហ៍ដោយបង្ខំប្រហែលជាមិនត្រូវបានដាក់ចេញតឹងរ៉ឹងនោះទេនៅតំបន់ខ្លះ ខណៈដែលតំបន់ខ្លះមានច្បាប់វិន័យយ៉ាងតឹងរ៉ឹង។ ការបន្តអាពាហ៍ពិពាហ៍ដោយបង្ខំនេះមិនត្រូវបានបង្ខំទាំងស្រុងទេ ហើយអ្វីដែលគួរឲ្យចាប់អារម្មណ៍ មានស្ត្រីម្នាក់ដែលបានលែងលះបន្ទាប់ពីរៀបការដោយបង្ខំនោះ។ លោកស្រី ឈុន ឡុង [Chhun Long] អាយុ ៥៧ ឆ្នាំ ដែលត្រូវគេបង្ខំឲ្យរៀបការក្នុងអំឡុងរបបខ្មែរក្រហម បានឲ្យដឹងថា៖ *"ខ្ញុំត្រូវគេបង្ខំឲ្យរៀបការជាមួយបុរសម្នាក់នៅក្នុងភូមិដូចគ្នា។ ខ្ញុំបានបដិសេធ ប៉ុន្តែ ប្រធានភូមិបាននិយាយថា ខ្ញុំត្រូវតែរៀបការ។ ប្ដីរបស់ខ្ញុំចង់រៀបការជាមួយខ្ញុំណាស់ ហើយគាត់បានទៅនិយាយជាមួយប្រធានភូមិ។ នៅពេលនោះ ឪពុកម្ដាយខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលឃើញខ្ញុំរៀបការ។ ខ្ញុំបានរៀបការរួមនឹងគូស្វាមីភរិយា ២៥ គូផ្សេងទៀត ហើយត្រូវតែស្លៀកសំលៀកបំពាក់ពណ៌ខ្មៅ"*[៦៣]។ ទោះជាយ៉ាងណា លោកស្រី ឈុន [Chhun] មិនចុះសម្រុងនឹងប្ដីរបស់គាត់ទេ ហើយនៅពេលកូនគាត់បានអាយុ ៤ ខែ គាត់បានលែងលះប្ដីរបស់គាត់។ *"ខ្ញុំបាននិយាយជាមួយប្រធានភូមិថា ខ្ញុំមិនអាចនៅជាមួយប្ដីខ្ញុំបានទេ។ ម្ដាយរបស់ខ្ញុំក៏បានជូនខ្ញុំទៅជួបគាត់។ ប្រធានភូមិបានបោះត្រាឯកសារ ហើយខ្ញុំក៏ត្រូវបានអនុញ្ញាតឲ្យលែងលះ"*[៦៤]។

ទាំងបុរស និងស្ត្រីសុទ្ធតែបានរងគ្រោះទាំងស្មារតី និងរាងកាយដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំនេះ។ ការចាប់គូដោយបង្ខំនេះបានប៉ះពាល់ដល់ជីវិតរបស់ស្ត្រីជាច្រើន ទោះមិនទាំងអស់ក្តី សូម្បីតែនៅក្រោយរបបខ្មែរក្រហមក្តី តាមរូបភាពផ្សេងៗគ្នាជាច្រើន។

## ការរៀបចំពិធីអាពាហ៍ពិពាហ៍

ស្រដៀងគ្នាទៅនឹងអាពាហ៍ពិពាហ៍មុនរបបខ្មែរក្រហមដែរ ក្នុងករណីភាគច្រើន ស្ត្រីបានជួបប្ដីរបស់ខ្លួនជាលើកដំបូងនៅក្នុងពិធីមង្គលការតែម្ដង។ ភាពខុសគ្នារវាង "អាពាហ៍ពិពាហ៍ដែលអនុញ្ញាតដោយខ្មែរ

Deleted: ជាមួយ

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

ក្រហម" និង "អាពាហ៍ពិពាហ៍ដែលរៀបចំដោយខ្មែរក្រហម" គឺការយល់ព្រមរបស់ឪពុកម្ដាយ។ ការយល់ព្រមពីឪពុកម្ដាយភាគច្រើនមិនត្រូវបានអើពើទេចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំជាច្រើនរបស់ខ្មែរក្រហម។ ពិធីរៀបអាពាហ៍ពិពាហ៍ស្ទើរតែទាំងអស់ត្រូវបានរៀបចំដោយខ្មែរក្រហម។ ឪពុកម្ដាយ និងសាច់ញាតិមិនត្រូវបានអនុញ្ញាតឲ្យចូលរួមឡើយ។ ពិធីរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងតាមរបៀបផ្សេងគ្នាជាច្រើន ដូច្នេះ គ្មានការត្រួតពិនិត្យជាប្រព័ន្ធលើការរៀបចំពិធីអាពាហ៍ពិពាហ៍នេះនោះទេ ។

លោកស្រី ប៊ុន ផល្លា [Bun Phalla] ត្រូវគេបង្ខំឲ្យរៀបការ ហើយជាលទ្ធផល មានកូនស្រីម្នាក់ពីអាពាហ៍ពិពាហ៍ដោយបង្ខំនេះ។ លំនៅដ្ឋានរបស់គាត់ក្នុងអំឡុងរបបខ្មែរក្រហមគឺនៅក្នុងខេត្តព្រះវិហារ ហើយគាត់គឺជាប្រជាជនមូលដ្ឋាននៅទីនោះ។

*ខ្ញុំត្រូវគេបង្ខំឲ្យរៀបការជាមួយបុរសម្នាក់ដែលរស់នៅក្នុងភូមិមួយផ្សេងទៀត។ ខ្ញុំមិនដែលស្គាល់គាត់ទេមុនរៀបការ។ ខ្ញុំមានអារម្មណ៍យ៉ាប់ខ្លាំងណាស់ ហើយខ្ញុំពិតជាមិនចង់រៀបការជាមួយគាត់ទេ។ ពិធីមង្គលការត្រូវបានរៀបចំឡើងនៅក្នុងផ្ទះមួយដែលមានដំបូល ជាកន្លែងប្រជុំរបស់ខ្មែរក្រហមមួយប្រភេទ។ គ្មានតន្ត្រីនោះទេ។ ឪពុកម្ដាយខ្ញុំក៏មិនបាននៅទីនោះជាមួយខ្ញុំដែរ។ អ្នកដែលនៅទីនោះគឺមានតែអ្នកដែលត្រូវរៀបការប៉ុណ្ណោះ ដូច្នេះមានបុរស និងស្ត្រីជាច្រើនរយនាក់ដែលមិនធ្លាប់ឃើញ ឬស្គាល់គ្នាពីមុនមក។ មានទាំងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីនៅទីនោះ។ រំពេចនោះ មេដឹកនាំខ្មែរក្រហមនៅកងបុរសបានបញ្ជាឲ្យបុរសទាំងអស់ដែលនៅក្នុងបន្ទប់ឲ្យជ្រើសរើសស្ត្រីណាក៏បានដែលខ្លួនចង់បានធ្វើជាដៃគូ។ បុរសម្នាក់បានចង្អុលមកខ្ញុំ ហើយទាហានខ្មែរក្រហមក៏បានបង្គាប់ឲ្យយើងស្បថចំពោះមុខអង្គការដោយនិយាយថា យើងត្រូវរៀបការជាមួយគ្នា។ ពេលនោះគឺខែ មិថុនា ឬខែ កក្កដា ឆ្នាំ ១៩៧៦។ ដូច្នេះ យើងបានក្លាយជាប្ដីប្រពន្ធនឹងគ្នាចាប់ពីថ្ងៃនោះមក។ នៅពេលនោះ មនុស្សរាប់រយគូត្រូវរៀបការ និងហូបអាហាររួមគ្នាបន្ទាប់ពីពិធីចប់។ គ្មាននរណាម្នាក់អាចបដិសេធនឹងអាពាហ៍ពិពាហ៍នេះបានទេ។ បើសិននរណាម្នាក់បដិសេធ ពួកគេនឹងត្រូវគេសម្លាប់។ ជារឿងអកុសលណាស់ដែលម្ដាយរបស់ខ្ញុំមិននៅទីនោះជាមួយខ្ញុំនៅពេលដែលខ្ញុំត្រូវគេបង្ខំឲ្យរៀបការនោះ។*

គាត់មិនដែលស្រឡាញ់ប្ដីដែលគេបង្ខំគាត់ឲ្យរៀបការជាមួយនេះនោះទេ ប៉ុន្តែរហូតមកដល់ពេលគាត់ស្លាប់កាលពីពីរបីឆ្នាំកន្លងមក ពួកគេបានស្នាក់នៅជាមួយគ្នាជាប្ដីប្រពន្ធ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍ លោកស្រី ស៊ូ អ៊ុំ [Su Oum] បានរៀបការនៅឆ្នាំ ១៩៧២ នៅពេលខ្មែរក្រហមបានគ្រប់គ្រងតំបន់របស់គាត់រួចទៅហើយ ហើយអាពាហ៍ពិពាហ៍របស់គាត់គឺជាអាពាហ៍ពិពាហ៍រួមដែលរៀបចំដោយខ្មែរក្រហម[៥៦]។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

*ពិធីមង្គលការរបស់ខ្ញុំត្រូវបានប្រារព្ធឡើងតាមរបៀបស្រដៀងគ្នានឹងបច្ចុប្បន្នដែរ។ យើងមានភ្ញៀវជាច្រើន។ អ្វីដែលខុសគ្នាធំនោះគឺ យើងមិនមានស្រាឡើយ។ ភ្ញៀវរបស់ខ្ញុំមិនត្រូវបានអនុញ្ញាតឱ្យផឹកស្រានោះទេ។ ទោះជាយ៉ាងណា នៅពេលនោះ យើងមិនមានស្រាទេ ព្រោះខ្មែរក្រហមបានហាមឃាត់។ នៅពេលខ្ញុំរៀបការនៅឆ្នាំ ១៩៧២ ខ្មែរក្រហមបានគ្រប់គ្រងពួកយើងរួចទៅហើយ។ ពួកគេបានបញ្ជាឱ្យយើងច្រៀង រាំ ប៉ុន្តែមិនតឹងរ៉ឹងពេកនោះទេ។ យើងអាចរៀបចំពិធីមង្គលការនៅផ្ទះខ្លួនឯងបាន។ ប៉ុន្តែ ក៏មានពិធីមង្គលការរួមដែលមានគូស្វាមីភរិយា ៣០ ឬ ៤០ គូក្នុងពេលតែមួយផងដែរ។ ប្រសិនបើមានច្រើនគូ ពួកគេត្រូវរៀបការនៅឯឃ្លាំងសន្តិសុខខ្មែរក្រហម។ មិនមានភ្លេងពណ៌ចម្រុះនៅក្នុងពិធីអាពាហ៍ពិពាហ៍នោះទេ។ បន្ទាប់ពីយើងបានរៀបការរួច ប្ដីរបស់ខ្ញុំបានមកនៅផ្ទះខ្ញុំពីរបីថ្ងៃ។ បន្ទាប់មក ខ្ញុំត្រូវទៅរស់នៅផ្ទះខាងប្ដីខ្ញុំ ព្រោះគ្រួសារខាងប្ដីខ្ញុំគ្មានកូនស្រីនោះទេ ហើយម្ដាយក្មេករបស់ខ្ញុំឈឺ។ ខ្ញុំត្រូវទៅរស់នៅទីនោះដើម្បីមើលថែគាត់ និងធ្វើការងារផ្ទះ។*

លោកស្រី ស៊ិន សារ៉េត [Sin Sareth] ដែលបានរៀបការក្នុងអំឡុងរបបខ្មែរក្រហម ដោយទទួលបានការអនុញ្ញាតពីខ្មែរក្រហម បានរៀបរាប់អំពីពិធីអាពាហ៍ពិពាហ៍របស់គាត់[៦៧]។

*អាពាហ៍ពិពាហ៍យើងត្រូវបានប្រារព្ធឡើងនៅកន្លែងដែលយើងហូបអាហារជាធម្មតា។ មានគូស្វាមីភរិយាចំនួន ១៨ គូ ហើយគេដាក់ឱ្យយើងអង្គុយ។ ពីរគូត្រូវបានណែនាំធ្វើជាតំណាងគូស្វាមីភរិយាទាំងអស់។ ពួកគេបានធ្វើការស្បថដោយនិយាយថា យើងនឹងបម្រើអង្គការ។ ខ្ញុំមិនចាំណែនទេដែលយើងមិនបានធ្វើការស្បថ។ យើងទាំងអស់គ្នាស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ និងមានក្រមាមួយ។ គ្មាននរណាម្នាក់ត្រូវគេបង្ខំឱ្យរៀបការនោះទេ។ ប៉ុន្តែ ជាអកុសល គ្មាននរណាម្នាក់ពីគ្រួសារបុគ្គលណាមួយអាចចូលរួមក្នុងពិធីនោះបានទេ។ ខ្មែរក្រហមមិនអនុញ្ញាតឡើយ។ នៅក្នុងពិធីមង្គលការខ្ញុំមានគូស្វាមីភរិយា ១៨ គូ។ ពួកយើងទាំងអស់ទទួលបានបង្អែមម្នាក់មួយចាន។ មេឃុំ ភូមិ និងកងយុវជន និងស្ត្រីក៏នៅទីនោះដែរ។ មានមនុស្សច្រើនណាស់ដែលបានចូលរួមក្នុងពិធីមង្គលការនោះ។ ក្នុងពិធីមង្គលការនោះ ខ្ញុំគ្មានអារម្មណ៍ពិសេសអ្វីទេ។ វាគ្រាន់តែជារឿងធម្មតាប៉ុណ្ណោះចំពោះខ្ញុំ។ បន្ទាប់ពីពិធីដែលរៀបចំដោយខ្មែរក្រហម យើងក៏បានរៀបចំពិធីមួយឱ្យគោរពដល់បុព្វបុរសរបស់យើងនៅផ្ទះរបស់ខ្ញុំតាមប្រពៃណីផងដែរ។ ឪពុកម្ដាយខ្ញុំបានអបអរសាទរខ្ញុំ ហើយនិយាយថា ឥឡូវនេះខ្ញុំរៀបការរួចហើយ។ យើងបានហូបអាហារពិសេសៗមួយចំនួន ដូចជាសាច់មាន់ជាដើម។ ប៉ុន្តែ គ្មានព្រះសង្ឃចូលរួមក្នុងពិធីទាំងនោះទេ។ បានរយៈពេល ២ ថ្ងៃបន្ទាប់មង្គលការ ខ្ញុំត្រូវគេបង្គាប់ឱ្យទៅធ្វើការនៅស្រែ។*

*បន្ទាប់ពីពិធីមង្គលការរួមរបស់យើងរួច គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឱ្យរៀបការនោះទេរហូតដល់ឆ្នាំ ១៩៧៨។ នោះជាពេលដែលគូស្វាមីភរិយា ១០០ គូ ឬច្រើនជាងនេះបានដាក់ពាក្យសុំ*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*ហើយពួកគេបានរៀបការរួមគ្នា។ ប្អូនស្រីរបស់ខ្ញុំគឺម្នាក់ក្នុងចំណោមនោះ។ នាងត្រូវបានអនុញ្ញាតឲ្យរៀបការជាមួយបុរសដែលនាងចង់បាន។ ប៉ុន្តែ មិនមែនគ្រប់គ្នាសុទ្ធតែត្រូវបានអនុញ្ញាតឲ្យជ្រើសរើសដៃគូខ្លួនឯងនោះទេ។ ឧទាហរណ៍ មានអ្នកខ្លះដែលពិការ ហើយពួកគេត្រូវបានផ្ដល់ឯកសិទ្ធិឲ្យជ្រើសរើសដៃគូរបស់ខ្លួន។ ដូចគ្នានេះផងដែរ អ្នកដែលធ្វើការក្នុងថ្នាក់ដឹកនាំខ្មែរក្រហមត្រូវបានអនុញ្ញាតឲ្យរៀបការជាមួយមនុស្សដែលខ្លួនជ្រើសរើស។ សម្រាប់មនុស្សប្រភេទនេះ អាហារពិសេសៗមួយចំនួន ត្រូវបានផ្ដល់ឲ្យសម្រាប់ពិធីមង្គលការនេះ។*

ក៏មានពិធីមង្គលការដែលឪពុកម្ដាយត្រូវគេអនុញ្ញាតឲ្យចូលរួមដែរ។ លោកស្រី សារុន ទួន [Saron Toun] ដែលបានរៀបការជាមួយអ្នកដែលខ្លួនស្រឡាញ់នៅក្នុងរបបខ្មែរក្រហម បាននិយាយថា[៩៨]៖

*ក្នុងពិធីមង្គលការនោះ យើងមានពិធីប្រពៃណីជាច្រើនដូចជា ការសែនដូនតា ការសម្លាប់សត្វជ្រូក និងការចម្អិនអាហារនៅផ្ទះតូចថ្មីដែលគេផ្ដល់ឲ្យយើងនៅវាល។ នៅពេលរសៀល អ្នកដែលត្រូវរៀបការត្រូវគេហៅឲ្យចូលក្នុងសាលប្រជុំនៃការិយាល័យរដ្ឋបាលឃុំ។ យើងបានសន្យាថាស្រឡាញ់គ្នាទៅវិញទៅមកនៅចំពោះមុខខ្មែរក្រហម។ បន្ទាប់មក ខ្មែរក្រហមបានឲ្យដំបូន្មានយើងខ្លះៗ ដូចជា ខិតខំធ្វើការដើម្បីជាប្រយោជន៍សម្រាប់ទាំងអស់គ្នា។ បន្ទាប់មក ពួកគេអនុញ្ញាតឲ្យយើងត្រឡប់ទៅផ្ទះវិញ។ ឪពុកម្ដាយ និងបងប្អូនស្រីរបស់ខ្ញុំ អាចចូលរួមក្នុងពិធីនេះបាន។ នៅពេលនោះ យើងអាចដាំបាយបានដោយខ្លួនឯង។*

នៅពេល លោកស្រី សារ៉ន [Saron] រំលឹកពីមង្គលការរបស់គាត់ ដោយនិយាយថា៖ *"ខ្ញុំខកចិត្តបន្តិចដោយសារតែយើងមិនអាចរៀបចំពិធីមង្គលការត្រឹមត្រូវដូចគេឯងនាពេលបច្ចុប្បន្ន។ ខ្ញុំចូលចិត្តតែងខ្លួន និងចង់ស្លៀកពាក់ស្អាតៗ"*។ ប្ដីរបស់គាត់ញញឹមដាក់គាត់ពេលដែលយើងកំពុងនិយាយគ្នានោះ។

ពិធីអាពាហ៍ពិពាហ៍ភាគច្រើនក្នុងរបបខ្មែរក្រហមគឺដូចជាការប្រជុំ ដែលរៀបចំឡើងដោយថ្នាក់ដឹកនាំខ្មែរក្រហម ឬប្រធានភូមិដូចនោះដែរ។ ភាពស្រដៀងគ្នាត្រូវគេមើលឃើញដោយមិនគិតពីទីតាំងនៃការរៀបអាពាហ៍ពិពាហ៍។ ភាគច្រើន គ្មានអាហារពិសេស គ្មានតន្ត្រី និងគ្មានសមាជិកគ្រួសារមកចូលរួមទេ។ ដូចគ្នា គូស្វាមីភរិយាខ្លះ ឬទាំងអស់ត្រូវគេណែនាំឲ្យធ្វើការស្បថរក្សាចំណងអាពាហ៍ពិពាហ៍នេះដោយកាន់ដៃគ្នាក្នុងពិធីមង្គលការ។ ពិធីមង្គលការគឺជាព្រឹត្តិការណ៍សំខាន់មួយសម្រាប់មនុស្សមួយចំនួន សូម្បីតែនៅពេលពួកគេត្រូវគេបង្ខំឲ្យរៀបការក្ដី។ ឪពុករបស់សិស្សខ្ញុំម្នាក់ លោក សំអឿ សុទីវ៉ាដ ត្រូវពួកខ្មែរក្រហមបង្ខំឲ្យរៀបការ និងបាននិយាយថា៖ "ខ្ញុំចង់បង្ហាញឲ្យអនាគតប្រពន្ធខ្ញុំឃើញ។ ខ្ញុំចង់ឲ្យគាត់ចាប់ចិត្តមកលើខ្ញុំនៅក្នុងពិធីមង្គលការនោះ ព្រោះវាជាលើកដំបូងដែលគាត់ឃើញខ្ញុំ។ ដូច្នេះ ខ្ញុំបានខ្ចីនាឡិកាដៃគេពាក់នៅក្នុងពិធីមង្គលការនោះ"។ ពួកគេនៅតែរស់នៅជាមួយគ្នាដដែល ហើយពួកគេមានកូនឆ្លាតៗដល់ទៅបួននាក់ទៀត[៩៩]។

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

ទោះជាយ៉ាងណា មានភាពខុសគ្នាជាច្រើនក្នុងចំណោមការរៀបចំពិធីមង្គលការ និងគ្មានការណែនាំទាក់ទងទៅនឹងការរៀបចំពិធីមង្គលការរួមនោះទេ។ ឬប្រហែលជារដ្ឋាភិបាលក្នុងតំបន់មិនយល់ ឬមិនអនុវត្តតាមបញ្ជាពីរដ្ឋាភិបាលមជ្ឈិម។ លោកស្រី សៀក អ៊ីម [Seak Im] អាយុ ៦០ ឆ្នាំ ដែលត្រូវគេ "បង្ខំ" ឲ្យរៀបការនៅក្នុងអំឡុងរបបខ្មែរក្រហម បាននិយាយថា៖ *"ខ្ញុំសប្បាយចិត្តណាស់នៅក្នុងពិធីមង្គលការរបស់ខ្ញុំក្នុងរបបខ្មែរក្រហម ដោយសារតែពិធីនោះសម្បូរដោយម្ហូបអាហារ"*[១០០]។ លោកស្រី ម៉ុង រាង [Mong Reang] អាយុ ៧៧ ឆ្នាំ បានលើកឡើងនូវបទពិសោធន៍ស្រដៀងគ្នានេះ៖ *"ពិធីមង្គលការនោះជាពេលដ៏រីករាយសម្រាប់យើងព្រោះខ្មែរក្រហមបានសម្លាប់គោក្របីឲ្យពួកយើងបរិភោគ។ ខ្ញុំនៅចាំបានពីពិធីរៀបមង្គលការពីរក្នុងអំឡុងរបបខ្មែរក្រហម។ ពិធីទីមួយមានគូស្វាមីភរិយា ១០ គូ និងទីពីរមាន ៧ គូ។ យើងទាំងអស់គ្នាសប្បាយចិត្តដែលបានយើងមានម្ហូបអាហារពិសេស ហូបជាមួយគ្នា"*[១០១]។

អ្វីដែលគួរឲ្យចាប់អារម្មណ៍ នៅខេត្តព្រៃវែង ស្ត្រីមួយចំនួនដែលយើងបានសម្ភាសត្រូវគេបង្ខំឲ្យរៀបការនៅវត្ត។ សិស្សរបស់ខ្ញុំ លោក សេង លាង ក៏បានរាយការណ៍ផងដែរថា គាត់បានលឺមនុស្សជាច្រើននិយាយថា ពិធីមង្គលការរួមត្រូវគេប្រារព្ធធ្វើឡើងនៅវត្ត[១០២]។ លោកស្រី ស៊ុំ ចាន់ថា [Sum Chanta] អាយុ ៥៧ ឆ្នាំ បានឲ្យដឹងថា[១០៣]៖

*អ្នកដែលខ្ញុំស្រឡាញ់ដំបូងគឺប្តីរបស់ខ្ញុំ។ យើងបានរៀបការក្នុងអំឡុងរបបខ្មែរក្រហម។ ប៉ុន្តែខ្មែរក្រហមមិនបានបង្ខំខ្ញុំទាល់តែសោះ ហើយខ្ញុំបានរៀបការ។ យើងបានរៀបការនៅវត្ត។*

លោក ឈន ឈិន [Chhorn Chhen] អាយុ ៦៥ ឆ្នាំ ក៏និយាយផងដែរថា គាត់នៅចាំបានថាមានពិធីមង្គលការនៅវត្តនៅក្នុងភូមិមែន ដោយមានគូស្វាមីភរិយា ២០ ទៅ ៣០ គូត្រូវគេបង្ខំឲ្យរៀបការ[១០៤]។ យើងមិនដឹងពីមូលហេតុថាហេតុអ្វីខ្មែរក្រហមប្រើកន្លែងសាសនារៀបចំពិធីបែបនោះទេ ប៉ុន្តែសិស្សស្រីម្នាក់ឈ្មោះ ប៉ូ ចាន់ណាក់ [Po Channak] បានវិភាគលើបាតុភូតនេះ[១០៥]។

*ខ្មែរក្រហមគិតថា វត្តគឺជាកន្លែងល្អសម្រាប់ពលរដ្ឋរៀបការ ព្រោះមនុស្សមានអារម្មណ៍ថា ខ្លួនមានកាតព្វកិច្ចត្រូវតែនិយាយការពិត។ វត្តគឺជាកន្លែងដែលពួកគេមិនអាចកុហកនរណាម្នាក់បាន។ ពួកគេត្រូវបានបង្ខំឲ្យធ្វើការស្បថនៅចំពោះមុខអ្នកផ្សេងទៀតថា ពួកគេនឹងស្រឡាញ់គ្នាជារៀងរហូត ។ល។ ដូច្នេះ បើសិនពួកគេត្រូវបង្ខំឲ្យរៀបការនៅវត្ត នោះមានន័យថា ពួកគេនឹងមិននិយាយអ្វីដែលជាការមិនពិតនោះទេ។*

បន្ទាប់ពីពិធីមង្គលការ គូស្វាមីភរិយាភាគច្រើនត្រូវបែកគ្នាដោយសារត្រូវធ្វើការងារដោយបង្ខំនៅតំបន់ខុសៗគ្នា ហើយពួកគេត្រូវមិនត្រូវបានអនុញ្ញាតឲ្យរស់នៅជាមួយគ្នានោះទេ។ រយៈពេលដែលគូស្វាមីភរិយាថ្មីថ្មោងរស់នៅជាមួយគ្នាក្រោយពីរៀបការរួចគឺមិនទៀងទេ ប៉ុន្តែក៏យ៉ាងហោចណាស់ពីពីរបីថ្ងៃ ទៅមួយសប្តាហ៍ដែរ។ ក្នុងករណីភាគច្រើន ប្រពន្ធត្រូវគេអនុញ្ញាតឲ្យនៅក្នុងភូមិរបស់ខ្លួន រីឯប្តីត្រូវគេបញ្ជូនឲ្យ

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

ទៅឆ្ងាយពីប្រពន្ធ និងកូន។ ទោះជាខ្មែរក្រហមបានបង្ខំប្រជាជនមួយចំនួនឱ្យរៀបការផ្ទុយពីឆន្ទៈរបស់ខ្លួនក្តី ក៏គេមិនអនុញ្ញាតឱ្យគូស្វាមីភរិយាស្នាក់នៅជាមួយគ្នាដែរ។ ហេតុនេះ ពួកគេមិនអាចមានជីវិតអាពាហ៍ពិពាហ៍ដោយខ្លួនឯងបានឡើយ។

Deleted: អាពាហ៍ពិពាហ៍

**ទំនាក់ទំនងយេនឌ័រក្នុងរបបខ្មែរក្រហម**

សង្គ្រាមបាននាំយកការផ្លាស់ប្តូរជាថាមវន្តដល់ប្រពៃណីរបស់សង្គមខ្មែរ។ ការផ្លាស់ប្តូរទាំងនេះបានបះបោរប្រឆាំងនឹងសង្គមមួយដែលជាសង្គមបិតាធិបតេយ្យ។ តាមប្រពៃណី ដូចដែលឃើញនៅក្នុងជំពូក "កុមារភាពមុនរបបខ្មែរក្រហម" ស្ត្រីត្រូវគេណែនាំឱ្យចុះញ៉ម និងស្តាប់បង្គាប់ឪពុកម្តាយរបស់ខ្លួន។ ការស្រាវជ្រាវនេះមិនបានចងក្រងជាឯកសារនូវរឿងរ៉ាវនៃ "កុមារភាពរបស់ក្មេងប្រុស" ដែលអាចត្រូវគេគាបសង្កត់ផងដែរទាក់ទងនឹងសេរីភាព។ ទោះជាយ៉ាងណា ក្មេងស្រីបានទទួលការអប់រំយ៉ាងជាក់ច្បាស់ និងបានទទួលយកគំនិតដែលត្រូវចុះញ៉ម។ ប្រពៃណីនេះគឺជាកត្តាគន្លឹះមួយក្នុងការពង្រឹងសង្គមបិតាធិប_តេយ្យ។ ការបង្ហាញពីប្រព័ន្ធបិតាធិបតេយ្យបែបនេះ គឺជាការប្រព្រឹត្តអំពើហិង្សារបស់បុរសលើដៃគូជិតស្និទ្ធរបស់គាត់ ពោលគឺប្រពន្ធរបស់គាត់នៅក្នុងកាលៈទេសៈជាច្រើន។ ទោះជាយ៉ាងណា គេបានរាយការណ៍ថា អំពើហិង្សាក្នុងគ្រួសារគឺកម្រឃើញមានណាស់នៅក្នុងរបបខ្មែរក្រហម។

ទោះជាស្ត្រីភាគច្រើនមិនបាននិយាយដល់អំពើហិង្សា ភាគច្រើនប្រហែលជាបាននិយាយ ព្រោះការនិយាយពីរឿងដែលកន្លងផុតទៅជាងសែសិបឆ្នាំទៅហើយ ឬក្រោយពីប្តីរបស់គាត់ស្លាប់គឺជាការមិន "សមរម្យ" ទេ។ ទោះជាយ៉ាងណា តាមពិត ស្ត្រីច្រើនណាស់បានរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារមុនរបបខ្មែរក្រហម។ ផ្ទុយទៅវិញ ជាទូទៅ ស្ត្រីបាននិយាយថា គ្មានអំពើហិង្សាក្នុងគ្រួសារអាចកើតមានទៅបានទេក្នុងអំឡុងពេលនោះដោយសារតែមានច្បាប់តឹងរ៉ឹងដែលចែងថា បុរសណាដែលធ្វើបាបស្ត្រីនឹងត្រូវចាប់ខ្លួនបញ្ជូនទៅកសាង។ លោកស្រី ព្រុយ រ័ត្ន [Prui Rat] អាយុ ៥៧ ឆ្នាំ បានរៀបការនៅក្នុងរបបខ្មែរក្រហមដោយសារតែប្តីរបស់គាត់លួចស្រឡាញ់គាត់។ ដូច្នេះ គាត់បានសុំការអនុញ្ញាតពីប្រធានភូមិ។ *"ប្តីរបស់ខ្ញុំគឺជាមនុស្សហិង្សា។ ប៉ុន្តែ ក្នុងរបបខ្មែរក្រហម គាត់មិនប្រើអំពើហិង្សាអ្វីឡើយ។ សូម្បីតែស្រែកគំហកក៏គាត់អត់ដែរ។ ពេលណាគាត់ខឹង គាត់គ្រាន់តែចេញពីផ្ទះប៉ុណ្ណោះ"*[១០៦]។ លោកស្រី ទូច អួន [Touch Oun] បាននិយាយផងដែរថា៖ *"បើយើងរៀបការរួច ហើយមានជម្លោះ នោះខ្មែរក្រហមនឹងដាក់ទោសយើង និងយកយើងទៅកសាងនៅកន្លែងណាមួយមិនខាន"*[១០៧]។ លោក នួន គាង [Noun Keang] ក៏រំលឹកផងដែរថា៖ *"គ្មានអំពើហិង្សាក្នុងគ្រួសារទាល់តែសោះក្នុងសម័យខ្មែរក្រហម។ មិនអាចទៅរួចទេព្រោះបើខ្មែរក្រហមដឹងថាមានជម្លោះណាមួយ នោះអ្នកដែលជាប់ពាក់ព័ន្ធនឹងត្រូវបញ្ជូនទៅកសាង។ គឺដូចគ្នានឹងក្រមលេខ ៦ ស្តីពីបទល្មើសសីលធម៌ ដែរ ហើយយើងមិនហ៊ានឱ្យមានការឈ្លោះប្រកែកគ្នា ឬវាយគ្នាឡើយ"*[១០៨]។

Formatted: Condensed by 0.3 pt

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

អ្នកណាដែលប្រើប្រាស់ហិង្សានឹងត្រូវចាប់ខ្លួនបញ្ជូនទៅកសាង។ ដូច្នេះ គេអាចសន្និដ្ឋានបានថា ជាការកម្រណាស់ដែលប្តីប្រើអំពើហិង្សាផ្លូវកាយលើប្រពន្ធរបស់គាត់ ឬស្រែកគំហកដាក់ប្រពន្ធរបស់គាត់ក្នុងកម្រិតដែលអ្នកក្រៅអាចស្តាប់លឺនោះ។ លោកស្រី នន់ នួន [Non Nuon] ដែលត្រូវគេបង្ខំឱ្យរៀបការនៅក្នុងសម័យខ្មែរក្រហមបាននិយាយថា៖ *"គ្មានអំពើហិង្សាក្នុងគ្រួសារឡើយក្នុងសម័យខ្មែរក្រហមនោះ។ គ្រប់គ្នាទប់កំហឹងរបស់ខ្លួននៅក្នុងចិត្ត និងមិនដែលបង្ហាញកំហឹងនោះដាក់អ្នកដទៃទៀតនោះទេ។ ប្តីរបស់ខ្ញុំមិនដែលខ្វល់ពីកូនរបស់យើងទេ ហើយខ្ញុំខឹងខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនដែលនិយាយអ្វីជាមួយប្តីខ្ញុំទេ។ ខ្ញុំទុកកំហឹងរបស់ខ្ញុំទាំងអស់នៅក្នុងចិត្តខ្លួនឯង"*[១០៩] ។

ដោយសារខ្លាចការដាក់ទណ្ឌកម្ម មនុស្សភាគច្រើនជាទូទៅទំនងជាមិនលឺថាមានជម្លោះក្នុងចំណោមសមាជិកគ្រួសារ ឬដឹងថាមានប្តីណាដែលប្រើប្រាស់អំពើហិង្សាណាស់។ លោកស្រី ហង្ស យ៉ាត [Hang Yat] អាយុ ៦៩ ឆ្នាំ គឺជាស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារពីប្តីរបស់គាត់ ប៉ុន្តែគាត់បានរំលឹកថា ប្តីរបស់គាត់មិនបានប្រើហិង្សាទេក្នុងអំឡុងរបបខ្មែរក្រហម។ គាត់បាននិយាយថា៖ *"ទោះយ៉ាងណា ភាគច្រើនគាត់នៅឆ្ងាយពីខ្ញុំ ហើយយើងស្ទើរតែមិនដែលបានជួបគ្នាផង"*[១១០]។

កំណត់ត្រាគួរឱ្យចាប់អារម្មណ៍មួយគឺថា ប្រសិនបើមានជម្លោះ ឬការមិនចុះសម្រុងគ្នារវាងប្តីប្រពន្ធនោះខ្មែរក្រហមនឹងដោះស្រាយករណីនោះនៅពេលប្រជុំពេលយប់។ លោកស្រី យ៉ាស៊ូកូ ណាអ៊ីតូ [Yasuko Naito] ដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហម បានរាយការណ៍ថា៖ *"មានការប្រជុំជាក្រុមមួយ ឬជាការជួបជុំក្រុមមួយចំនួន។ ការប្រជុំនេះរួមបញ្ចូលទាំងការអប់រំនយោបាយផងដែរ។ ការរិះគន់ត្រូវបានធ្វើឡើងលើបុគ្គលនានាទាក់ទងនឹងអាកប្បកិរិយា និងឥរិយាបថរបស់ពួកគេលើការងារ និងសូម្បីតែការដោះស្រាយពីរឿងគូស្វាមីភរិយាដែលបានរៀបការួចក៏ត្រូវបានពិភាក្សាផងដែរ"*[១១១]។

ជាក់ស្តែង ខ្មែរក្រហមមិនខ្វល់អំពីសារៈសំខាន់នៃតួនាទីរបស់បុរសក្នុងគ្រួសារឡើយ។ នៅក្នុងសង្គមបិតាធិបតេយ្យខ្មែរ តួនាទីរបស់បុរសជាមេគ្រួសារ ចាប់ពីការធ្វើការសម្រេចចិត្តរហូតដល់ "ការការពារ" សមាជិកគ្រួសារ ត្រូវបានគេឱ្យតម្លៃយ៉ាងខ្ពស់។ ទោះជាយ៉ាងណា នៅក្នុងរបបខ្មែរក្រហម តួនាទីប្តីក្នុងការការពារប្រពន្ធរបស់ខ្លួនត្រូវគេមើលរំលង ឬជំនួសដោយខ្មែរក្រហមវិញ ហើយតួនាទីជាឪពុកត្រូវបានជំនួសទាំងស្រុងដោយខ្មែរក្រហម។ ភាគច្រើន បុរសត្រូវគេដកហូតតួនាទីយេនឌ័រដែលមានតាំងពីបុរាណមកនៅក្នុងរបបខ្មែរក្រហម។ ពួកគេមិនត្រូវបានអនុញ្ញាតឱ្យការពារប្រពន្ធ និងសមាជិកគ្រួសាររបស់ខ្លួនឡើយ ជាញឹកញាប់ដោយសារតែពួកគេបានស្លាប់។ ស្ត្រីចំនួន ១៣ នាក់នៅក្នុងការសិក្សានេះបានបាត់បង់ប្តីរបស់ខ្លួនក្នុងអំឡុងរបបខ្មែរក្រហម។ លោកស្រី នូ ខន [Nu Khorn] អាយុ ៧៧ ឆ្នាំ បាននិយាយថា ប្តីរបស់គាត់ត្រូវគេសម្លាប់នៅក្នុងរបបខ្មែរក្រហមនៅពេលដែលកូនរបស់ពួកគេមានអាយុទើបតែបាន ១ ខែប៉ុណ្ណោះ។ គាត់បាននិយាយថា *"ពួកយើងគឺជាប្រជាជនមូលដ្ឋាន (ក្នុងខេត្តតាកែវ) និងរស់នៅក្នុងជីវិត*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*ធម្មតាដូចអ្នកផ្សេងទៀតដែរ។ ប៉ុន្តែ ខ្មែរក្រហមបានយកប្តីខ្ញុំទៅសម្លាប់។ កូនខ្ញុំទើបតែបានអាយុ ១ ខែប៉ុណ្ណោះ។ ពេលនោះគឺនៅមុនពេលរំដោះបន្តិច"*[១១២] ។ ជាក់ស្តែង ស្ត្រីជាច្រើនបំពេញ "តួនាទីរបស់បុរស" ដែលមានតាំងពីបុរាណមកនៅក្នុងគ្រួសាររបស់ពួកគេ។ ពួកគេត្រូវផ្គត់ផ្គង់ និងចិញ្ចឹមគ្រួសារក្នុងអំឡុងពេលសង្គ្រាម ដែលភាគច្រើនបំផុតគ្រប់ពេលទាំងអស់ ព្រោះប្តីរបស់ពួកគេនៅឆ្ងាយពីក្រុមគ្រួសាររបស់ពួកគេ។

*[រូបភាព]*

លោកស្រី ផម អួន [Phom Oun] មកពីខេត្តព្រៃវែង ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥

**[Chapter 6]**

## ជំពូកទី ៦៖ ការមានផ្ទៃពោះនៅពេលសង្គ្រាម

ការស្រាវជ្រាវនេះបានជួបជាមួយស្ត្រីចំនួន ៦៦ នាក់ដែលបានសម្រាលកូនយ៉ាងហោចណាស់ម្តងក្នុងរបបខ្មែរក្រហម។ ជាសរុប ស្ត្រី ៤៨ នាក់មានកូនមួយ ១៦ នាក់មានកូនពីរ និង ២ នាក់មានកូនបី។ ចំនួនទាំងនោះមិនរាប់បញ្ចូលការរលូតកូន ដែលនឹងត្រូវរៀបរាប់នៅពេលក្រោយនោះទេ។

ការស្រាវជ្រាវនេះកើតពីការចង់ដឹងដ៏សាមញ្ញរបស់ខ្ញុំក្នុងការស៊ើបអង្កេតថាតើ ស្ត្រីទទួលយកការមានផ្ទៃពោះរបស់ខ្លួនក្នុងអំឡុងពេលសង្គ្រាមដោយរបៀបណា ឬក៏បដិសេធ និងបញ្ចប់ការមានផ្ទៃពោះនោះ ហើយនៅចុងបញ្ចប់នៃដំណើររយៈពេល ៩ ខែនេះ តើពួកគេស្វាគមន៍ជីវិតថ្មីម្នាក់ទៀតដោយរបៀបណា។ ដូច្នេះ បទសម្ភាសន៍ភាគច្រើនបានចំណាយពេលយូរដើម្បីស្តាប់សម្តីរបស់ស្ត្រី អំពីអារម្មណ៍ បទពិសោធន៍ និងការយល់ឃើញរបស់ពួកគេអំពីការមានផ្ទៃពោះនៅក្នុងរបបខ្មែរក្រហម។

សូម្បីតែនៅពេលមានសង្គ្រាម ស្ត្រីក៏មានផ្ទៃពោះដែរ ប៉ុន្តែរបបខ្មែរក្រហមបាននាំឲ្យមានភាពស្មុគស្មាញខ្លាំងចំពោះការមានផ្ទៃពោះសម្រាប់ស្ត្រី ដែលជាលទ្ធផលនាំឲ្យមានការលំបាក និងភាពមិនសប្បាយចិត្តក្នុងចំណោមស្ត្រីជាម្តាយដែលមានផ្ទៃពោះ។ ភាពស្មុគស្មាញផ្តើមចេញពីការពិតដែលថា ជីវិតអាពាហ៍ពិពាហ៍គឺពុំស្វាគមន៍ជីវិតថ្មីមួយទៀត ការមានផ្ទៃពោះបានកើតមានព្រមជាមួយនឹងការលំបាក ដូចជាការធ្វើការដោយបង្ខំគ្មានទីបញ្ចប់ ភាពអត់ឃ្លាន និងការស្លាប់របស់សមាជិកគ្រួសារ ហើយស្ត្រីជាច្រើនមានផ្ទៃពោះដោយសារការរៀបការដោយបង្ខំ។

ដំបូងគេបង្អស់ "ជីវិតអាពាហ៍ពិពាហ៍" ខ្លួនឯងមិនទាន់មានឡើយនៅក្នុងអំឡុងរបបខ្មែរក្រហម ដោយសារតែ ភាគច្រើន ប្តីប្រពន្ធត្រូវគេបង្ខំឲ្យរស់នៅកន្លែងផ្សេងៗគ្នាដើម្បីធ្វើការដែលគេបង្ខំ។ ស្ត្រីភាគច្រើនដឹងថា ពួកគេមានផ្ទៃពោះខណៈពេលដែលប្តីរបស់ខ្លួននៅកន្លែងមួយឆ្ងាយ។ នៅពេលពួកគេជួបគ្នាប្រពន្ធបានប្រាប់ពីរឿងជីវិតថ្មីបានចាប់កំណើតនៅក្នុងខ្លួនរបស់ពួកគេ។ ប៉ុន្តែ ពួកគេនៅតែត្រូវគេបង្ខំឲ្យបែក

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

គ្នាដើម្បីធ្វើការងារធ្ងន់ៗនៅកន្លែងផ្សេងៗគ្នា។ ដូច្នេះ ដោយមិនគិតពីឆន្ទៈរបស់ប្តី ពួកគេមិនត្រូវគេអនុញ្ញាតឱ្យជួយដល់ប្រពន្ធរបស់ខ្លួនអំឡុងពេលមានផ្ទៃពោះនោះទេ ហើយក្នុងករណីជាច្រើន ពួកគេមិនត្រូវបានអនុញ្ញាតឱ្យជួយពេលសម្រាលកូនផងដែរ។

ទីពីរ ស្ត្រីត្រូវគេបង្ខំឱ្យធ្វើការដោយគ្មានសម្រាក ទទួលរងភាពអត់ឃ្លាន និងភ័យខ្លាចត្រូវគេសម្លាប់នៅពេលណាមួយ។ នៅក្រោមសម្ពាធ និងការគាបសង្កត់ដ៏ខ្លាំងបែបនោះ ស្ត្រីមិនសង្ឃឹមថានឹងមានផ្ទៃពោះនោះឡើយ។ ជីវិតរបស់ពួកគេកំពុងស្ថិតក្នុងហានិភ័យស្រាប់ហើយ ហើយសឹងតែមិនអាចទៅរួចនោះទេដែលពួកគេស្រមៃថា តើពួកគេមានសមត្ថភាពអាចការពារជីវិតមួយទៀតបានដែរ ឬអត់នោះ។ ពួកគេក៏ដឹងដែរថា គ្មាននរណាម្នាក់នៅក្បែរខ្លួនអាចជួយពួកគេបានទេ។

ជាចុងក្រោយ បើទោះបីជាគ្មានស្ត្រីណាផ្សាភ្ជាប់ការមានផ្ទៃពោះនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងមិនចង់បានរបស់ខ្លួនក្តី តាមពិត ស្ត្រីមួយចំនួនបានមានផ្ទៃពោះដោយសារតែការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ដូចដែលបានពិភាក្សានៅក្នុងជំពូកមុន ស្ត្រីត្រូវគេបង្ខំឱ្យរៀបការជាមួយមនុស្សម្នាក់ដែលពួកគេមិនស្គាល់រហូតដល់ថ្ងៃអាពាហ៍ពិពាហ៍របស់ពួកគេតែម្តង ហើយពួកគេប្រហែលជាត្រូវខ្មែរក្រហមបង្ខំឱ្យរួមភេទជាមួយប្តីរបស់ពួកគេទៀតផង។ ដូច្នេះ ស្ត្រីមួយចំនួនបានក្លាយជាមានផ្ទៃពោះ ហើយពួកគេមិនអាចរីករាយនឹងរឿងនោះបានតាំងពីដំបូងមកម្ល៉េះ។

**ការមានផ្ទៃពោះដែលមិនចង់បាន**

ក្នុងពេលធ្វើសម្ភាសន៍ ខ្ញុំតែងតែសួរសំណួរថា៖ "តើអ្នកសប្បាយចិត្តនឹងការមានកូនទេក្នុងរបបខ្មែរក្រហម?" ព្រោះខ្ញុំជឿថា សង្គមគួរតែផ្តល់លក្ខខណ្ឌមួយដល់ស្ត្រីមានផ្ទៃពោះទាំងអស់ឱ្យមានអារម្មណ៍ថាមានសុវត្ថិភាព និងសប្បាយរីករាយខណៈពេលដែលពួកគេមានផ្ទៃពោះ។ វាគឺជាការទទួលខុសត្រូវសង្គមរួមក្នុងចំណោមប្រជាជនក្នុងសហគមន៍។ ដូច្នេះ ជាការសំខាន់ណាស់ក្នុងការស៊ើបសួរថា តើស្ត្រីគាត់មានអារម្មណ៍បែបណាពេលពួកគេមានផ្ទៃពោះនៅចំពេលដែលលំបាកខ្លាំងបំផុត នៅក្នុងជីវិតពួកគេនៅក្នុងរបបខ្មែរក្រហមនេះ។ ស្ត្រីទាំងអស់ដែលខ្ញុំបាននិយាយជាមួយបាននិយាយថា ពួកគេមិនចង់មានផ្ទៃពោះក្នុងអំឡុងរបបខ្មែរក្រហមទេ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ ទោះបីជាស្ត្រីជាច្រើនបានរាយការណ៍ថា ស្វាមីរបស់ពួកគេសប្បាយចិត្តពេលលឺថាប្រពន្ធមានផ្ទៃពោះ។ លោកស្រី ម៉ក់ ប៉ាន [Mork Pan] អាយុ ៨១ ឆ្នាំ បាននិយាយថា៖ *"ប្តីរបស់ខ្ញុំសប្បាយចិត្តខ្លាំងណាស់ពេលគាត់លឺថាខ្ញុំមានផ្ទៃពោះ"*[១១៣]។ សម្តីនេះត្រូវបានលើកឡើងដោយស្ត្រីជាច្រើនតាមរបៀបស្រដៀងគ្នា ដែលគូសបញ្ជាក់ពីភាពខុសគ្នាខាងយែនឌ័រដែលគួរឱ្យចាប់អារម្មណ៍មួយ។

លោកស្រី សៀម ឃុន [Seam Khun] អាយុ ៧១ ឆ្នាំ បាននិយាយថា៖ *"ពេលខ្ញុំមានផ្ទៃពោះ ខ្ញុំហត់នឿយខ្លាំងណាស់ ហើយពេលនោះជាពេលដែលលំបាកខ្លាំងសម្រាប់ខ្ញុំ។ ខ្ញុំគ្មានអាហារគ្រប់គ្រាន់ទេ។ ខ្ញុំ*

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*ព្រួយបារម្ភគ្រប់ពេលថានឹងគ្មានអាហារគ្រប់គ្រាន់"*[១១៤]។ លោកស្រី រ៉ុន [Ron] អាយុ ៨២ ឆ្នាំ ក៏បានរាយការណ៍ផងដែរថា គាត់រងគ្រោះពីភាពអត់ឃ្លាន និងការងារលំបាកៗគ្មានទីបញ្ចប់ ខណៈពេលគាត់មានផ្ទៃពោះ បន្ថែមពីលើភាពភ័យខ្លាចដែលថា គាត់អាចនឹងត្រូវខ្មែរក្រហមផ្តន្ទាទោស ឬសម្លាប់[១១៥]។

> *នៅពេលខ្ញុំដឹងថា ខ្ញុំមានផ្ទៃពោះ ខ្ញុំមានការព្រួយបារម្ភ និងភ័យខ្លាចណាស់។ ខ្ញុំមិនដឹងថាតើត្រូវថែទាំសុខភាពខ្លួនឯងយ៉ាងណានោះទេ ព្រោះខ្មែរក្រហមបានបង្គាប់ខ្ញុំឱ្យបន្តធ្វើការរហូត។ បើសិនខ្ញុំខ្ជិលច្រអូស ពួកគេនឹងហៅខ្ញុំទៅស្តីឱ្យ ឬព្រមាន។ មិនថាកំហុសអ្វីក៏ដោយ បើសិនខ្មែរក្រហមដឹង ពួកគេនឹងបញ្ជូនពួកយើងទៅកសាង។ បន្ទាប់ពីកសាងពីរ ឬបីដង បុគ្គលនោះនឹងមិនវិលត្រឡប់មកវិញរហូត ដូច្នេះយើងដឹងថា ម្នាក់នោះត្រូវខ្មែរក្រហមសម្លាប់ហើយ។ ខ្ញុំត្រូវធ្វើការរហូតដល់កូនខ្ញុំកើត។ គ្មានវេជ្ជបណ្ឌិតណាមើលថែទាំខ្ញុំទេ។*

ដូចគ្នានឹងលោកស្រី រ៉ុន [Ron] ដែរ ស្ត្រីជាច្រើនក៏ខ្លាចការផ្តន្ទាទោស និងត្រូវគេសម្លាប់នេះដែរ។ ចាប់ពីឆ្នាំ ១៩៧៨ តទៅ នៅក្នុងតំបន់ជាច្រើន ការសម្លាប់រង្គាលបានចាប់ផ្តើមកើតមានជាញឹកញាប់។ មនុស្សជាច្រើននៅក្នុងភូមិបានបាត់ខ្លួន ឬអ្នកដែលគេគ្រាន់តែហៅទៅប្រជុំមិនដែលបានត្រឡប់មកវិញឡើយ។ ស្ត្រីភ័យខ្លាចជាខ្លាំងថា ពួកគេក៏នឹងត្រូវគេផ្តន្ទាទោសផងដែរក្នុងអំឡុងពេលមានផ្ទៃពោះនេះ។

លោកស្រី អេង លីន [Eng Lin] អាយុ ៦៣ ឆ្នាំ បានរំលឹកថា៖ *"ក្នុងអំឡុងរបបខ្មែរក្រហម គ្មានអាហារហូបគ្រប់គ្រាន់នោះទេ សូម្បីពេលយើងមានផ្ទៃពោះក្តី។ បន្ថែមពីលើនេះ ខ្ញុំមានអាការៈចាញ់កូនខ្លាំងដល់ថ្នាក់មិនអាចហូបបាន។ ពេលនោះ ខ្ញុំលំបាកខ្លាំងណាស់។ ទោះជាខ្ញុំចាញ់កូនយ៉ាងណា ខ្ញុំត្រូវគេបង្ខំឱ្យធ្វើការដូចស្ត្រីដទៃទៀតដែរ។ គ្មាននរណាម្នាក់បង្រៀនខ្ញុំពីរបៀបថែរក្សាសុខភាពរបស់ខ្ញុំ ក្នុងអំឡុងពេលមានផ្ទៃពោះនោះទេ។ នៅពេលខ្ញុំមានផ្ទៃពោះបានប្រាំបីខែ ខ្ញុំត្រូវគេបញ្ជាឱ្យមើលថែក្មេងតូចៗ។ គ្មានថ្នាំ និងគ្មានអាហារដែលមានអាហាររូបត្ថម្ភល្អសម្រាប់កូនខ្ញុំនោះទេ"*[១១៦]។

ការចាត់ទុកភាពរងទុក្ខ និងការលំបាកៗទាំងនោះថាជារឿងប្រក្រតីបានធ្វើឱ្យប្រជាជនលែងមានអារម្មណ៍ទៀត។ ផ្ទុយទៅវិញ មនុស្សមួយចំនួនបានប្រែជាតូចចិត្ត ព្រួយបារម្ភ និងភ័យខ្លាច។ លោកស្រី សារ៉ន ទូន [Saron Toun] បានរំលឹកថា ការមានផ្ទៃពោះរបស់គាត់គឺជាបទពិសោធន៍គួរឱ្យខ្លាច[១១៧]។

> *ខ្ញុំមានផ្ទៃពោះនៅមួយខែក្រោយពីរៀបការរួច និងសម្រាលកូនដំបូងរបស់ខ្ញុំនៅឆ្នាំ ១៩៧៧។ ខ្ញុំមិនចង់មានផ្ទៃពោះក្នុងរបបខ្មែរក្រហមទេ។ ការមានផ្ទៃពោះនោះជាការលំបាកខ្លាំងណាស់។ នៅពេលខ្ញុំនៅលីវមុនពេលមានសង្គ្រាម ខ្ញុំធាត់ជាងនោះ។ ប៉ុន្តែក្រោយពេលរៀបការរួច ខ្ញុំស្រកទម្ងន់ខ្លាំង និងចុះស្គមទៅៗ។ នេះគឺដោយសារតែអាការៈចាញ់កូនដែលមានរយៈពេលប្រហែលកន្លះខែ។ ខ្ញុំហូបអ្វីមិនបានសោះ។ ខ្ញុំស្ទើរតែស្លាប់ទៅហើយ។ ជាតិសាច់ក្នុងអាហារក៏គ្មាន ថ្នាំល្អៗក៏គ្មាន។ សូម្បីតែពេលខ្ញុំមានផ្ទៃពោះ និងចាញ់កូនខ្លាំងក្តី ខ្មែរក្រហមមិនខ្វល់នោះទេ ហើយនៅតែបញ្ជាខ្ញុំឱ្យទៅ*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*ធ្វើការនៅការដ្ឋានសាងសង់ទំនប់ទៀត។ ខ្ញុំខកចិត្តយ៉ាងខ្លាំង ពេលខ្ញុំដឹងថា ខ្ញុំមានផ្ទៃពោះ ព្រោះខ្ញុំដឹងថា យើងគ្មានអ្វីដើម្បីចិញ្ចឹមកូនរបស់យើងឱ្យបានត្រឹមត្រូវនោះទេ។ ខ្ញុំស្ថិតក្នុងស្ថានភាពលំបាកខ្លាំងណាស់ទៅហើយដើម្បីខ្លួនឯងមានជីវិតរស់នៅ។ ដូច្នេះ ខ្ញុំខ្លាចខ្លាំងណាស់នៅពេលខ្ញុំដឹងថា ខ្ញុំមានផ្ទៃពោះ។ អ្វីដែលកាន់តែភ័យ ពោះរបស់ខ្ញុំកាន់តែធំទៅៗ ហើយរាងកាយរបស់ខ្ញុំចាប់ផ្តើមផ្លាស់ប្តូរ។*

ខណៈពេលលោកស្រី សារ៉ន [Saron] ចែករំលែកបទពិសោធន៍ពីអតីតកាលជាមួយយើង ប្តីរបស់គាត់បានដើរទៅមក និងដាក់ស្វាយ និងទឹកក្រូចកូកាកូឡាមួយចំនួនឱ្យយើងហូប ព្រោះបទសម្ភាសន៍យើងកាន់តែយូរទៅៗ។ គាត់ហាក់ដូចជាបារម្ភណាស់ពេលដឹងពីការសន្ទនារបស់យើងជាមួយប្រពន្ធរបស់គាត់ គឺដូចគ្នានឹងប្តីផ្សេងៗទៀតជាច្រើនទៀតដែរ ដែលខ្ញុំបានឃើញនៅទូទាំងការស្រាវជ្រាវ។ ជាទូទៅ ខ្ញុំបានសុំឱ្យប្តីទាំងអស់ទុកពេលឯកជនឱ្យយើងព្រោះការសម្ភាសន៍របស់យើងមានលក្ខណៈផ្ទាល់ខ្លួន ហើយយើងចង់ស្តាប់រឿងរ៉ាវរបស់ស្ត្រីតែឯងប៉ុណ្ណោះ។ ទោះជាយ៉ាងណា ប្តីរបស់លោកស្រី សារ៉ន [Saron] មើលទៅរួសរាយណាស់ ដោយគាត់ញញឹមដាក់យើង និងយកចិត្តទុកដាក់នឹងប្រពន្ធគាត់ ដោយញញឹមដាក់ប្រពន្ធគាត់ទៀតផង។ ដូច្នេះ ខ្ញុំបានសុំឱ្យសិស្សរបស់ខ្ញុំ ថៃ ឈុនលី ធ្វើការសម្ភាសដាច់ដោយឡែកជាមួយគាត់។ ខ្ញុំគិតថា គាត់ប្រហែលជាមានរឿងគួរឱ្យចាប់អារម្មណ៍ខ្លះចែករំលែកចេញពីការយល់ឃើញរបស់បុរសដែលបានក្លាយជាឪពុកគេ និងឃើញប្រពន្ធរបស់ខ្លួនមានផ្ទៃពោះក្នុងអំឡុងពេលសង្គ្រាម។ ខាងក្រោមនេះ គ្រាន់តែជាផ្នែកមួយនៅពេលដែលគាត់និយាយអំពីបទពិសោធន៍របស់គាត់ដែលបានក្លាយជាឪពុកគេ ក្នុងអំឡុងពេលសង្គ្រាម។

*ដំបូង ប្រពន្ធខ្ញុំ និងខ្ញុំមិនបានដឹងថា យើងមានកូននោះទេ។ ប្រពន្ធខ្ញុំស្គម ខ្សោយណាស់ គ្មានកម្លាំងឡើយ សូម្បីតែកម្លាំងធ្វើការ។ យើងគិតថា ប្រពន្ធខ្ញុំមានជំងឺអ្វីផ្សេង ដូច្នេះគេនាំគាត់ទៅមន្ទីរពេទ្យស្រុក។ ជាអកុសល ខ្ញុំមិនអាចជូនគាត់ទៅដោយខ្លួនឯងបាន។ ប៉ុន្តែ ពេលគាត់ទៅដល់ទីនោះ គ្រូពេទ្យបាននិយាយប្រាប់ប្រពន្ធខ្ញុំថា៖ "អូ ឯងមានផ្ទៃពោះហើយ"។ នៅពេលខ្ញុំលឺដូចនេះ ខ្ញុំគ្មានអារម្មណ៍អ្វីទាំងអស់។ នៅពេលខ្ញុំដឹងថា ប្រពន្ធខ្ញុំមានផ្ទៃពោះ ខ្ញុំគ្មានអារម្មណ៍អ្វីនោះទេ។ ពេលនោះគឺជារដូវវស្សា។ រាល់ព្រឹក ខ្ញុំត្រូវគេបង្ខំឱ្យធ្វើការនៅវាលស្រែ ហើយនៅពេលរសៀល ខ្ញុំត្រូវមើលគោ។ ពេលខ្ញុំធ្វើការ ខ្ញុំបានព្យាយាមឆ្លៀតពេលខ្លះរកថ្នាំមួយចំនួនពីព្រៃមកឱ្យប្រពន្ធខ្ញុំដែលមានផ្ទៃពោះ។ ខ្ញុំមិនដឹងថាថ្នាំអ្វីអាចព្យាបាលអាការៈចាញ់កូនរបស់គាត់ ឬថ្នាំអ្វីដែលគាត់ត្រូវប្រើពេលមានផ្ទៃពោះនោះទេ។ ដូច្នេះ ដើម្បីយល់ពីស្ថានភាពរបស់គាត់កាន់តែប្រសើរ ខ្ញុំបានសួរចាស់ៗដែលនៅជុំវិញនោះដែលដឹងពីបញ្ហាទាំងនេះ។ បន្ទាប់ពីខ្ញុំបានទទួលចំណេះដឹងខ្លះៗ ខ្ញុំបានព្យាយាមស្វែងរកថ្នាំមួយចំនួនសម្រាប់ប្រពន្ធរបស់ខ្ញុំម្តងទៀត។ តាមពិត ខ្ញុំគ្មានពេលច្រើនស្នាក់នៅក្នុងភូមិដែល*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*ប្រពន្ធខ្ញុំស្លាក់នៅនោះទេ។ ភាគច្រើន ប្រពន្ធខ្ញុំស្លាក់នៅក្នុងភូមិមួយផ្សេងទៀតចិញ្ចឹមជ្រូកខ្លះៗ។ ចំណែកខ្ញុំ បន្ទាប់ពីការងារដាំដុះស្រូវនៅរដូវវស្សារួច ខ្ញុំត្រូវចុះបេសកកម្មមួយចំនួន ដូចជា ជួយប្រជាជនក្នុងភូមិផ្សេងទៀតរកថ្នៅ។ ថ្នៅត្រូវគេយកធ្វើជាសំណាញ់នេសាទ។ ពេលដែលប្រពន្ធខ្ញុំមានផ្ទៃពោះ ខ្ញុំគ្មានពេលច្រើនមើលថែទាំគាត់ទេ។ ចាស់ៗប្រាប់ខ្ញុំថា បើខ្ញុំចង់ឱ្យកូនរបស់ខ្ញុំកើតមកមានស្បែកភ្លឺ ខ្ញុំត្រូវរកទឹកដូងឱ្យប្រពន្ធខ្ញុំផឹកពេលមានផ្ទៃពោះដូចនេះ។ ដោយសារតែដំណឹងមួយនេះ ពេលខ្ញុំមកផ្ទះវិញ ខ្ញុំបានលួចដូងមួយចំនួនពីខានៅមុខផ្ទះខ្ញុំឱ្យប្រពន្ធខ្ញុំ។ តាមពិតនោះគឺជាទង្វើគ្រោះថ្នាក់ណាស់ ប៉ុន្តែទោះជាយ៉ាងណា ខ្ញុំធ្វើដូច្នេះដើម្បីប្រពន្ធខ្ញុំ។*

ដូចនឹងស្ត្រីដទៃទៀតជាច្រើនដែរ លោកស្រី ស៊ូ ឱម [Su Om] អាយុ ៦២ ឆ្នាំ មិនចង់មានផ្ទៃពោះទេក្នុងអំឡុងរបបខ្មែរក្រហម។ គាត់បាននិយាយថា៖ *"នៅពេលខ្ញុំរំលឹកពីពេលមានផ្ទៃពោះនៅក្នុងរបបខ្មែរក្រហម គឺពិបាកខ្លាំងណាស់។ ខ្ញុំមិនចង់មានកូនទេនៅពេលនោះ ដោយសារតែពេលនោះលំបាកខ្លាំងពេក។ ខ្ញុំគ្មានអ្វីហូបនោះទេ សូម្បីតែអំបិល ម្រេច ឬខ្ទឹមស។ យើងថែមទាំងគ្មានភ្លើងទៀត ដូច្នេះអ្វីដែលយើងមានគឺមានតែភាពងងឹតប៉ុណ្ណោះ។ ខ្ញុំអាចហូបបានតែបបរប៉ុណ្ណោះ"*[១១៨]។

ស្ត្រីជាច្រើនចង់បញ្ចប់ការមានផ្ទៃពោះរបស់ពួកគេ ប៉ុន្តែ លោកស្រី ស៊ូ សាវ៉ន [Su Savorn] ចង់ធ្វើអត្តឃាត ដោយសារតែការមានផ្ទៃពោះរបស់គាត់លំបាកខ្លាំងពេក[១១៩]។

*គ្មាននរណាម្នាក់ខ្វល់ពីសុខភាពរបស់ខ្ញុំទេ ទោះជាគេដឹងថា ខ្ញុំមានផ្ទៃពោះក្តី។ វាមិនមែនជារឿងរបស់គេនោះទេ។ ថ្នាំក៏គ្មាន។ មានតែម្តាយខ្ញុំប៉ុណ្ណោះ ដែលមានបទពិសោធន៍ខ្លះៗ បានប្រាប់ខ្ញុំពីអ្វីដែលត្រូវធ្វើ ឬមិនត្រូវធ្វើ។ ខ្ញុំមិនសប្បាយចិត្តទេពេលដែលខ្ញុំមានផ្ទៃពោះក្នុងអំឡុងរបបខ្មែរក្រហមនោះ។ ដូចអ្នកបានដឹងហើយ ពេលនោះខ្ញុំពិបាកនឹងរស់រានមានជីវិតណាស់។ បើសិនខ្ញុំមានកូន តើខ្ញុំអាចរក្សាជីវិតរបស់កូនខ្ញុំបានដោយរបៀបណាទៅ។ ប៉ុន្តែ ខ្ញុំគ្មានជម្រើសទេ ព្រោះខ្ញុំមានផ្ទៃពោះទៅហើយ ហើយនោះគឺជាការពិត។ ដូច្នេះ ខ្ញុំបានបន់ស្រន់ព្រះរាល់ថ្ងៃដើម្បីជួយគ្រួសារខ្ញុំ និងខ្លួនខ្ញុំផ្ទាល់។ មានតែប៉ុណ្ណឹង។ ខ្ញុំនៅតែចាំថា ខ្ញុំតែងតែចង់ហូបអ្វីមួយជានិច្ច ព្រោះខ្ញុំឃ្លានរហូត។ ពេលខ្លះ ខ្ញុំចង់ស្លាប់ជាមួយកូនដែលនៅក្នុងផ្ទៃខ្ញុំតែម្តង និងចង់ផឹកថ្នាំបុរាណសម្លាប់ខ្លួន។ នៅពេលខ្ញុំប្រាប់រឿងនេះដល់ប្តីរបស់ខ្ញុំដោយខ្សឹបៗដើម្បីកុំឱ្យពួកឈ្លបខ្មែរក្រហមស្តាប់លឺ ប្តីរបស់ខ្ញុំបានលើកទឹកចិត្តខ្ញុំឱ្យរឹងមាំ និងបន្តរស់តទៅទៀត។*

នៅពេលស្ត្រីគាត់ដឹងថាខ្លួនមានផ្ទៃពោះ ស្ត្រីជាច្រើនភ័យខ្លាច ប៉ុន្តែខ្លះទៀតបានគិតថា មិនមែនជារឿង "អាក្រក់ពេកនោះទេ" នៅពេលពួកគេឆ្លុះបញ្ចាំងមកវិញពីការមានផ្ទៃពោះរបស់ពួកគេឥឡូវនេះ។ លោកស្រី ហួត យ៉ុន [Hout Yon] និយាយថា៖ *"ហ៊ឺ ... សប្បាយក៏មិនដូចសប្បាយពិតប្រាកដទេ។ គឺគ្រាន់*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*តែទារកកើតចេញមក។ យើងត្រូវខំប្រឹងចិញ្ចឹមពួកគេ។ ជាទូទៅ ខ្ញុំមិនសប្បាយចិត្តទេពេលខ្ញុំមានកូននៅក្នុងរបបខ្មែរក្រហមនោះ"*[១២០] ។

ជាទូទៅ ស្ត្រីដែលមានផ្ទៃពោះរស់នៅឆ្ងាយពីប្តី និងគ្រាន់តែអាចប្រាប់ប្តីថា គាត់មានកូននៅពេលប្តីគាត់ត្រឡប់មកជួបគាត់វិញប៉ុណ្ណោះ។ លោកស្រី ស៊ូ ឱម [Su Om] រំលឹកថា គាត់មានផ្ទៃពោះទាំង *"អវត្តមានប្តីរបស់គាត់"*[១២១]។

*ភាគច្រើន ប្តីខ្ញុំនៅឆ្ងាយ ដូច្នេះខ្ញុំមិនអាចប្រាប់គាត់ថា ខ្ញុំមានផ្ទៃពោះបានទេរហូតដល់ខ្ញុំមានផ្ទៃពោះ ៤ ខែទៅហើយ។ នៅពេលខ្ញុំមានផ្ទៃពោះ ខ្ញុំហូបបានតែបបរមួយចានតូចប៉ុណ្ណោះ និងគ្មានត្រីទេ។ បើគេឱ្យត្រីមកខ្ញុំ គឺមានតែឆ្អឹងប៉ុណ្ណោះ។ ការមានផ្ទៃពោះរបស់ខ្ញុំគឺពិតជាលំបាកណាស់ ហើយខ្ញុំគិតតែពីរឿងថាតើត្រូវធ្វើដូចម្តេចដើម្បីរស់បានពីមួយថ្ងៃទៅមួយថ្ងៃ។ ខ្ញុំមិនបានប្រាប់ខ្មែរក្រហមថាខ្ញុំមានផ្ទៃពោះទេ។ សូម្បីតែពេលយើងមានផ្ទៃពោះបាន ៨ ខែហើយក្តី យើងនៅតែត្រូវធ្វើការធម្មតា។ ខ្ញុំមិនបានសម្រាកទេ។ ខ្មែរក្រហមមិនសួរស្ត្រីណាម្នាក់ពីការមានផ្ទៃពោះឡើយ។ នៅពេលយើងហៀបនឹងសម្រាលកូន យើងត្រូវទៅមន្ទីរពេទ្យ។ ស្ត្រីមានផ្ទៃពោះទាំងអស់ក្នុងតំបន់ខ្ញុំសុទ្ធតែធ្វើដូច្នេះ។*

ស្ត្រីមានផ្ទៃពោះសព្វថ្ងៃរីករាយនឹងទិញសម្លៀកបំពាក់ពិសេសសម្រាប់អ្នកមានផ្ទៃពោះ ប៉ុន្តែនៅពេលនោះ ពុំមានសម្លៀកបំពាក់បែបនោះទេ។ លោកស្រី មួយ គា [Muy Kea] បានឱ្យដឹងថា ការមានផ្ទៃពោះរបស់គាត់ពីរដងនៅក្នុងរបបខ្មែរក្រហមសុទ្ធតែលំបាករឿងការស្លៀកពាក់ ព្រោះ *"ខ្ញុំគ្មានសម្លៀកបំពាក់ត្រឹមត្រូវស្លៀកសម្រាប់អ្នកមានផ្ទៃពោះនោះទេ"*[១២២]។ ស្ត្រីជាច្រើនឥឡូវនេះក្លាយជាជីដូនគេអស់ហើយ។ នៅពេលពួកគេក្រឡេកមើលទៅលើការមានផ្ទៃពោះរបស់ពួកគេផ្ទាល់ ក្នុងអំឡុងពេលសង្គ្រាមវិញ ដោយប្រៀបធៀបនឹងការមានផ្ទៃពោះរបស់កូនស្រីពួកគេ ពួកគេអាចចាំបានថា តើពួកគេលំបាកវេទនាយ៉ាងណានៅពេលមានផ្ទៃពោះក្នុងពេលមានសង្គ្រាមនោះ។

**ពលកម្មដោយបង្ខំ និងការអត់ឃ្លាន**

ជាក់ស្តែង ខ្មែរក្រហមគ្មានគោលនយោបាយការពារណាមួយឡើយសម្រាប់ស្ត្រីដែលនឹងក្លាយជាម្តាយ។ ទាក់ទងនឹងរឿងនេះ ច្បាស់ណាស់ដែលថា គេមិនបានយកចិត្តទុកដាក់លើបញ្ហាដែលទាក់ទងនឹងប្រជាជននេះទេ។ ខ្មែរក្រហមមិនបានផ្តល់ព័ត៌មានអំពីបញ្ហាទាក់ទងនឹងការមានផ្ទៃពោះដល់ស្ត្រីមានផ្ទៃពោះឡើយ បើទោះជាឆ្មបមួយចំនួនអាចបង្រៀនស្ត្រីអំពីការថែទាំពេលមានផ្ទៃពោះក្តី។ លើសពីនេះទៀត ស្ត្រីដែលមានផ្ទៃពោះត្រូវគេប្រព្រឹត្តដាក់ស្មើគ្នាទៅនឹងស្ត្រីដទៃទៀតដែរ ហើយពួកគេត្រូវបានបង្ខំឱ្យធ្វើការងារលំបាកៗដូចគ្នានឹងស្ត្រីដែលមិនមានផ្ទៃពោះផ្សេងទៀតដែរ។ ពួកគេភាគច្រើនមិនដែលត្រូវបានអនុញ្ញាតឱ្យឈប់

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

សម្រាកពីការងារលំបាកៗក្នុងអំឡុងពេលមានផ្ទៃពោះឡើយ ហើយពួកគេត្រូវបានជេររិះគន់ បើពួកគេសុំឈប់សម្រាកដោយសារតែការចាញ់កូន។

លោកស្រី ស៊ូ សាវ៉ន [Su Savorn] បានរំលឹកពីការមានផ្ទៃពោះរបស់គាត់ថាជា *"ពេលដ៏វេទនា"*។ នៅពេលគាត់មានផ្ទៃពោះ ប្តីរបស់គាត់បានកត់សម្គាល់ឃើញថា គាត់មានអាការៈចាញ់កូន។ *"ប្តីរបស់ខ្ញុំនិយាយជាមួយខ្ញុំថា៖ "តើឯងមានផ្ទៃពោះមែនទេ?" ហើយខ្ញុំបាននិយាយថា មែន។ បន្ទាប់មក គាត់បាននិយាយថា៖ "យើងគ្មានម្ហូបអាហារទេសូម្បីតែសម្រាប់ខ្លួនយើងក្តី ..."*[១២៣] គាត់និយាយតែប៉ុណ្ណឹង នៅពេលគាត់លឺថា ប្រពន្ធគាត់មានផ្ទៃពោះនោះ។

> *ក្នុងអំឡុងរបបខ្មែរក្រហម ប្តីខ្ញុំភាគច្រើននៅឆ្ងាយ ហើយមិត្តរបស់គាត់ដែលស្នាក់នៅជិតនោះ បានជួយខ្ញុំឱ្យផឹកថ្នាំបុរាណខ្លះៗ។ ពេលប្តីខ្ញុំត្រឡប់មកវិញ យើងបានជជែកគ្នាដោយខ្សឹបៗកុំឱ្យល្បបខ្មែរក្រហមអាចស្តាប់យើងលឺ។ ខ្ញុំចាំបានយ៉ាងច្បាស់ថា ខ្ញុំបាននិយាយប្រាប់គាត់ថា ខ្ញុំចង់សម្លាប់ខ្លួន បើមានស្លឹកឈើពុលណាដែលអាចសម្លាប់ខ្ញុំបាន។ ការមានផ្ទៃពោះពិតជារឿងលំបាកណាស់សម្រាប់ខ្ញុំ ហើយប្តីខ្ញុំនៅឆ្ងាយ ខណៈដែលទុក្ខលំបាកទាំងអស់បានសង្កត់មកលើខ្ញុំ។ នៅឆ្នាំដំបូងនៃរបបខ្មែរក្រហមតែឯង ខ្ញុំបានបាត់បង់សមាជិកគ្រួសាររបស់ខ្ញុំចំនួន ៤ នាក់រួចទៅហើយ។ ខ្ញុំត្រូវគេបង្ខំឱ្យធ្វើការ "ដូចគោក្របីអញ្ចឹង"។*

នៅពេលលោកស្រី សាវ៉ន [Savorn] បានជួបជាមួយប្តីគាត់ ប្តីគាត់តែងតែស្តាប់គាត់ដោយក្តីស្រឡាញ់ និងលើកទឹកចិត្តគាត់ឱ្យបន្តរស់តទៅទៀត និងឱ្យរឹងមាំឡើងដើម្បីកូនរបស់ពួកគេ។ ប៉ុន្តែជាអកុសល នៅពេលកូនកើតមក ប្តីគាត់ត្រូវពួកខ្មែរក្រហមសម្លាប់បាត់ទៅហើយ។

គ្មានការចែកអាហារបន្ថែមឱ្យស្ត្រីមានផ្ទៃពោះឡើយ។ ពួកគេបានហូបតិចតួចណាស់ គឺដូចនឹងស្ត្រីផ្សេងទៀតដែរព្រោះមិនដែលមានម្ហូបអាហារគ្រប់គ្រាន់សម្រាប់គ្រប់គ្នាឡើយ។ លោកស្រី ផម អ៊ុំ បាននិយាយថា៖ *"ខ្មែរក្រហមនិយាយថា យើងត្រូវហូបឱ្យបានច្រើនដើម្បីធ្វើការឱ្យបានខ្លាំងក្លាសម្រាប់បដិវត្តន៍។ នោះគឺជាពាក្យស្លោកមួយ ប៉ុន្តែតាមពិត យើងមិនដែលមានអាហារហូបគ្រប់គ្រាន់ទេ សូម្បីតែនៅពេលខ្ញុំមានផ្ទៃពោះក៏ដោយ។ ខ្ញុំមិនចង់មានផ្ទៃពោះទេ។ សូម្បីតែពេលខ្ញុំមានផ្ទៃពោះក្តី ខ្ញុំព្រួយបារម្ភថាតើត្រូវចិញ្ចឹមកូនរបស់ខ្ញុំដោយរបៀបណា ព្រោះខ្ញុំខ្លួនឯងគ្មានអាហារហូបគ្រប់គ្រាន់ផង"*[១២៤]។

លោកស្រី យាយ សុខ [Yeay Sok] មានបាននិយាយដូចខាងក្រោមផងដែរ[១២៥]។

> *របបខ្មែរក្រហមគឺជាពេលលំបាកខ្លាំងណាស់សម្រាប់ខ្ញុំ។ ប្តីរបស់ខ្ញុំ មុនពេលគាត់ត្រូវគេសម្លាប់ អាចជួបខ្ញុំតែពីរ ឬបីដងប៉ុណ្ណោះក្នុងមួយខែ។ គាត់ត្រូវគេបញ្ជូនឱ្យទៅធ្វើការងារធ្ងន់ៗនៅឆ្ងាយពីខ្ញុំ។ ពេលខ្លះ ពេលដែលខ្ញុំឃ្លានខ្លាំងមែនទែន ខ្ញុំខំដើររកស្លឹកឈើខ្លះៗ។ ខ្ញុំបានព្យាយាមហូបអ្វីៗគ្រប់យ៉ាង ទោះជាស្ត្រីមានផ្ទៃពោះមិនគួរហូបរបស់បែបនោះក្តី។ សូម្បីតែក្រោយខ្ញុំសម្រាលកូនរួច*



Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*ក្តី ខ្ញុំមិនព្រួយបារម្ភអំពីជំងឺ ការចុះខ្សោយ ឬការស្លាប់នោះទេ ព្រោះខ្ញុំមិនដឹងថា ពេលណាខ្ញុំអាចនឹងស្លាប់ផង។ ថ្ងៃណាមួយ ខ្មែរក្រហមអាចនឹងសម្លាប់ខ្ញុំ ព្រោះប្តីរបស់ខ្ញុំបានចូលរួមក្នុងជួរកងទ័ពក្នុងរបប លន់ នល់។ ដូច្នេះ ខ្ញុំហូបអ្វីក៏បានឲ្យតែខ្ញុំអត់ឃ្លាន។*

លោកស្រី ហ៊ុន សុន [Hun Son] បានសម្រាលកូនពីរដងក្នុងរបបខ្មែរក្រហម។ ម្តងនៅឆ្នាំ ១៩៧៥ និងម្តងទៀតនៅឆ្នាំ ១៩៧៨ ប៉ុន្តែកូនទីមួយបានស្លាប់ក្នុងអំឡុងរបបខ្មែរក្រហមបាត់ហើយ[១២៦]។

*ខ្ញុំត្រូវធ្វើការពីព្រឹកព្រលឹមរហូតដល់ល្ងាច ដោយមានតែបបរាវៗហូបប៉ុណ្ណោះ។ ខ្ញុំមិនដឹងថាតើស្រូវទាំងអស់ដែលយើងបានដាំទៅណាអស់ទេ។ នៅពេលខ្ញុំមានផ្ទៃពោះកូនទីពីររបស់ខ្ញុំ ខ្ញុំព្រួយបារម្ភខ្លាំងណាស់ថា តើកូននឹងប្រឈមមុខនឹងជោគវាសនាដូចគ្នានឹងកូនទីមួយដែរឬអត់ទេ។ សូម្បីតែពេលខ្ញុំមានផ្ទៃពោះក្តី ខ្ញុំត្រូវធ្វើការដូចស្ត្រីដទៃទៀតដែរ។ ប៉ុន្តែ ខ្ញុំគ្មានអ្វីហូបទេ។ ថ្នាំពេទ្យក៏គ្មាន។ នៅពេលខ្ញុំមានផ្ទៃពោះបាន ៨ ឬ ៩ ខែ គេអនុញ្ញាតឲ្យខ្ញុំនៅផ្ទះ។ ប៉ុន្តែ សូម្បីតែពេលនោះក្តី ខ្ញុំត្រូវគេបញ្ជាឲ្យជួយអ្នកផ្សេងទៀតនៅផ្ទះបាយ។*

ឪពុករបស់លោកស្រី ហ៊ុន សុន [Hun Son] ត្រូវគេសម្លាប់នៅក្នុងរបបខ្មែរក្រហម រីឯបងស្រីរបស់គាត់ត្រូវគេបង្ខំឲ្យរៀបការ។ គ្រួសារទាំងមូលត្រូវគេបំបែក ហើយប្តីរបស់គាត់ក៏ត្រូវគេបញ្ជូនឲ្យទៅធ្វើការឆ្ងាយក្នុងព្រៃផងដែរនៅពេលគាត់មានផ្ទៃពោះនោះ។ ស្ត្រីជាច្រើនត្អូញត្អែរថា ប្តីរបស់ខ្លួននៅឆ្ងាយ និងមិនអាចជួយរកម្ហូបអាហារឲ្យពួកគេបានឡើយ។ តាមប្រពៃណី ភារកិច្ចរបស់បុរស ឬមេគ្រួសារគឺធ្វើយ៉ាងណាត្រូវរកម្ហូបអាហារដើម្បីកុំឲ្យគ្រួសារគាត់អត់ឃ្លាន។ ជាការពិត ប្តីច្រើនណាស់បានព្យាយាមជួយប្រពន្ធរបស់ខ្លួន ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែអាចជួយប្រពន្ធបានទាំងអស់នោះទេ។ ស្ត្រីជាច្រើនដែលត្រូវគេបង្ខំឲ្យរៀបការនៅក្នុងរបបខ្មែរក្រហមនិយាយថា ពួកគេប្រែជាស្រឡាញ់ប្តីរបស់ខ្លួន ឬថា ពួកគេបានសម្រេចចិត្តនៅជាមួយប្តីរបស់ខ្លួន ដោយសារប្តីរបស់ខ្លួនបានយកម្ហូបអាហារមកឲ្យខ្លួន។ ទង្វើនេះបានធ្វើឲ្យស្ត្រីមានអារម្មណ៍ថា ខ្លួនមានគេយកចិត្តទុកដាក់ និងការពារ។

ស្ត្រីភាគច្រើនដែលយល់ព្រមផ្តល់បទសម្ភាសន៍បានត្អូញត្អែរថា ពួកគេមិនអាចដើររកថ្នាំពេទ្យណាបានទាំងអស់នៅពេលពួកគេមានផ្ទៃពោះ។ ជាការពិតដែលថា ស្ត្រីមានផ្ទៃពោះនៅតាមទីក្រុងឥឡូវអាចរកទិញថ្នាំបាននៅពេលពួកគេមានផ្ទៃពោះនោះ[១២៧]។ ទោះជាយ៉ាងណា ក្នុងអំឡុងរបបខ្មែរក្រហម និងសូម្បីតែមុននោះទៅទៀត គ្មានថ្នាំពេទ្យទំនើបៗលក់នៅតាមតំបន់ជនបទនោះទេ។ ប្រជាជនខ្មែរជាធម្មតាប្រើតែថ្នាំបុរាណដែលធ្វើឡើងពីរុក្ខជាតិថ្នាំប៉ុណ្ណោះ។ ទោះជាយ៉ាងណា សូម្បីតែថ្នាំបុរាណក៏គេលំបាកនឹងរកបានដែរ ព្រោះគេមិនអនុញ្ញាតឲ្យប្រជាជនមានពេលផ្ទាល់ខ្លួនណាមួយឡើយ ហើយពួកគេត្រូវចំណាយពេលទាំងអស់ដើម្បីគោលបំណងបដិវត្តន៍។ ស្ត្រីមួយចំនួនចាំបានថា ប្តីរបស់ពួកគេបានព្យាយាមផ្សំថ្នាំបុរាណឲ្យពួកគេ។ ប្តីរបស់លោកស្រី ស៊ិន សារ៉េត [Sin Sareth] បានមើលថែគាត់បានល្អណាស់ពេលដែលគាត់មានផ្ទៃពោះ

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

នោះ។ *"ពេលមាននរណាម្នាក់ប្រាប់គាត់ពីប្រភេទឫសឈើដែលល្អសម្រាប់ខ្ញុំ គាត់តែងតែរកថ្នាំប្រភេទនោះមកឱ្យខ្ញុំ"*[១២៨]។ សកម្មភាពរបស់ប្រជាជនត្រូវបានឃ្លាំមើលដោយពួកខ្មែរក្រហម ហើយអ្នកដែលមិនបំពេញកាតព្វកិច្ចរបស់ខ្លួននឹងត្រូវគេផ្តន្ទាទោស។ ការជួយស្ត្រីមានផ្ទៃពោះដោយការប្រមូលឫសឈើធ្វើជាថ្នាំបុរាណមិនបានបម្រើឱ្យគោលបំណងនោះឡើយ។

*[រូបភាព]*

ប្តីរបស់លោកស្រី ស៊ាន [Sean] មកពីខេត្តព្រៃវែង ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៥

*[រូបភាព]*

ដំណើររឿងរបស់ឆ្មប លោកស្រី ម៉ៀន រ៉ុម [Maen Rom] មកពីខេត្តព្រៃវែង

*ខ្ញុំបានរៀនធ្វើជាឆ្មបនៅឆ្នាំ ១៩៧១ ជាអ្នកស្ម័គ្រចិត្ត។ នៅពេលនោះ ពួកគេបានប្រកាសថា ពួកគេកំពុងស្វែងរកអ្នកស្ម័គ្រចិត្តឱ្យរៀនពេទ្យ ហើយខ្ញុំក៏ចាប់អារម្មណ៍ចង់ក្លាយជាគ្រូពេទ្យ។ ក្នុងពេលកំពុងបណ្តុះបណ្តាល ខ្ញុំបានស្នាក់នៅសាលានៅក្នុងព្រៃដោយសារតែពួកគេមិនអនុញ្ញាតឱ្យសិស្សណាម្នាក់ត្រឡប់ទៅផ្ទះវិញនៅពេលយប់ទេ។ ដូច្នេះ ខ្ញុំបានស្នាក់នៅក្នុងព្រៃអស់រយៈពេល ៣ ខែ ហើយរស់នៅ និងរៀនជាមួយនឹងសិស្សផ្សេងៗទៀត។*

*ពេលនោះ មានទាំងសិស្សប្រុស និងសិស្សស្រី។ យើងទាំងអស់គ្នារៀនជាមួយគ្នា។ ពួកគេបង្រៀនយើងពីរបៀបសម្អាត ចាក់ថ្នាំ មើលថែទាំទារក និងទ្រីស្តីមួយចំនួនផងដែរ។ ពួកគេក៏អនុញ្ញាតឱ្យ សិស្សអនុវត្តជាក់ស្តែងដោយឱ្យយើងទៅមន្ទីរពេទ្យ និងជាការពិតគឺជួយគ្រូពេទ្យសម្រាលកូនឱ្យស្ត្រី។ នៅពេលខ្ញុំជួយគ្រូពេទ្យជាលើកដំបូង ខ្ញុំមានអារម្មណ៍រីករាយណាស់ ហើយខ្ញុំក៏ចង់បន្ត។ ប៉ុន្តែជាអកុសល ពួកគេមិនបានផ្តល់វិញ្ញាបនបត្រណាមួយដល់យើងបន្ទាប់ពីយើងបញ្ចប់ការសិក្សាឡើយ។*

*បន្ទាប់ពីការបណ្តុះបណ្តាលរយៈពេល ៣ ខែ ខ្ញុំបានបន្តស្នាក់នៅក្នុងមន្ទីរពេទ្យក្នុងព្រៃទៀត។ ប៉ុន្តែនៅពេលខ្មែរក្រហមបានមកដល់នៅឆ្នាំ ១៩៧៥ ខ្ញុំបានរត់ត្រឡប់ទៅផ្ទះខ្ញុំនៅក្នុងភូមិវិញ។*

*ក្នុងអំឡុងរបបខ្មែរក្រហម ខ្ញុំបានជួយស្ត្រីមានផ្ទៃពោះជាច្រើនក្នុងពេលសម្រាលកូន ប្រហែលជា ២ ឬ ៣ នាក់ក្នុងមួយថ្ងៃនៅក្នុងភូមិមួយ។ ខ្ញុំក៏បានជួយទាហានខ្មែរក្រហមជាស្ត្រីមានផ្ទៃពោះសម្រាលកូនផងដែរ។ ជាធម្មតា ខ្មែរក្រហមបានផ្តល់ថ្នាំមួយចំនួនដល់ស្ត្រីមានផ្ទៃពោះ ប៉ុន្តែមិនគ្រប់គ្រាន់ទេ។ ក៏មានការសម្រាលកូនពិបាកជាច្រើនដែលខ្ញុំមិនអាចជួយបានផងដែរ។ នៅពេលខ្ញុំដឹងថា ខ្ញុំមិនអាចជួយពួកគេបាន ខ្ញុំបានសុំឱ្យគ្រួសាររបស់ពួកគេបញ្ជូនពួកគេទៅកាន់មន្ទីរពេទ្យស្រុក។ មន្ទីរពេទ្យនោះនៅឆ្ងាយបន្តិចហើយពីកន្លែងដែលខ្ញុំនៅ ប៉ុន្តែមានមធ្យោបាយដឹកពួកគេទៅទីនោះ។ នៅពេលនោះ នៅពេលទារកហៀបនឹងចេញ*



**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

មក យើងមិនកាត់ទ្វារមាសរបស់ស្ត្រីដូចគេធ្វើបច្ចុប្បន្ននេះទេ។ វាដាច់ដោយខ្លួនឯង ដូច្នេះយើងគ្រាន់តែព្យាយាមមិនឱ្យវារហែកធំពេកប៉ុណ្ណោះ។ បន្ទាប់ពីសម្រាលរួច ម្ដាយជាធម្មតាផឹកស្រាស ប៉ុន្តែស្រានោះត្រូវប្ដី ឬក្រុមគ្រួសារគាត់ផ្ដល់ឱ្យដោយការទិញជាសម្ងាត់ពីអ្នកជិតខាងប៉ុណ្ណោះ។ យើងមិនបានផ្ដល់ស្រាសឱ្យម្ដាយនោះទេ។

មានស្ត្រីមានផ្ទៃពោះមួយចំនួនដែលស្លាប់ក្នុងអំឡុងរបបខ្មែរក្រហម។ ភាគច្រើន ពួកគេស្លាប់ដោយសារការបាត់បង់ឈាមច្រើនពេក។ ដូចគ្នានេះផងដែរ ខ្ញុំចាំបានថា ស្ត្រីមួយចំនួនមិនអាចសម្រាលកូនរួចដោយសារពួកគេចុះខ្សោយពេក។ មានស្ត្រីខ្លះ កូនរបស់ខ្លួនបានស្លាប់បន្ទាប់ពីសម្រាលរួច។ មិនមានទារកច្រើនណាស់ណាទេដែលកើតហើយភ្លាមស្លាប់ភ្លាមនោះ។ ភាគច្រើន ទារកស្លាប់បន្ទាប់ពីពួកគេបានអាយុ ៨ ខែ។

មានស្ត្រីខ្លះសុំឱ្យខ្ញុំរំលូតកូនឱ្យពួកគេ។ មែនហើយ ពួកគេពិតជាពឹងខ្ញុំឱ្យជួយពួកគេមែន។ ខ្ញុំបានរៀនបច្ចេកទេសរំលូតកូននៅពេលខ្ញុំរៀននៅក្នុងព្រៃ។ គ្រូៗបានបង្រៀនខ្ញុំពីវិធីសាស្ត្រនោះ។ ទោះជាខ្ញុំដឹងពីរបៀបរំលូតក្ដី ខ្ញុំមិនបានជួយដល់ស្ត្រីដែលពឹងខ្ញុំឱ្យជួយនោះទេ។ ខ្ញុំគិតថា ការសម្លាប់មនុស្សដែលមិនដឹងអីជាពិសេសទារកគឺជាទង្វើខុសឆ្គង។ ដូច្នេះ ខ្ញុំមិនបានជួយពួកគេទេដោយសារតែខ្ញុំគិតថា ការធ្វើបែបនេះគឺខុសឆ្គង។ បន្ទាប់ពីខ្ញុំបដិសេធនឹងសំណើរបស់ពួកគេ ពួកគេបានព្យាយាមរំលូតកូនដោយខ្លួនឯងផ្ទាល់។ ពេលខ្លះ ពួកគេបានព្យាយាមរំលូតកូនដោយខំប្រឹងធ្វើការធ្ងន់ៗ ឬព្យាយាមផឹកស្រាឱ្យច្រើនដើម្បីខ្លួនពួកគេក្ដៅខ្លាំង។

ក្នុងអំឡុងរបបខ្មែរក្រហម ប្ដីមិនត្រូវបានអនុញ្ញាតឱ្យមកមើលប្រពន្ធខ្លួនខណៈពេលគាត់សម្រាលកូននោះទេ។ ដោយសារតែប្ដីគឺជាមនុស្សប្រុស ហើយមនុស្សប្រុសតម្រូវឱ្យធ្វើការ។ សម្រាប់ម្ដាយ ពួកគេត្រូវបានគេថែទាំ ប៉ុន្តែថែទាំដោយស្ត្រីចាស់ៗប៉ុណ្ណោះ។ ខ្ញុំពិតជាសប្បាយចិត្តណាស់ពេលដែលខ្ញុំបានឃើញទាំងម្ដាយ និងកូនសុខសប្បាយក្រោយពេលសម្រាលហើយ។

នៅពេលខ្ញុំរំលឹកពីពេលនោះមកវិញ ខ្ញុំបានជួយស្ត្រីប្រហែលជាលើសពីមួយពាន់នាក់ជាសរុបក្នុងអំឡុងពេលសម្រាល។ ខ្ញុំមិនបានទទួលប្រាក់ខែអ្វីនោះទេពីការធ្វើជាឆ្មបក្នុងអំឡុងរបបខ្មែរក្រហមនោះ។ ខ្ញុំចង់ជួយមនុស្ស។ ខ្ញុំមិនចង់បានលុយទេ។ នៅក្រោយរបបខ្មែរក្រហម អ្នកជិតខាងខ្ញុំបានមករកខ្ញុំឱ្យជួយពួកគេ ហើយពួកគេចាប់ផ្ដើមឱ្យអំណោយមួយចំនួនដល់ខ្ញុំពេលខ្ញុំជួយពួកគេ។ ប៉ុន្តែ ទោះជាយ៉ាងណា ខ្ញុំបានជួយស្ត្រីដោយឥតគិតថ្លៃ។

នៅពេលទាហានវៀតណាមចូលមក ខ្មែរក្រហមបានផ្លាស់ចេញពីភូមិយើងរួចទៅហើយ។ វៀតណាមមិនបានធ្វើអ្វីអាក្រក់ដាក់យើងនោះទេ នៅពេលពួកគេបានមកដល់ភូមិរបស់យើង។ ពួកគេគ្រាន់តែសុំកន្លែងស្នាក់នៅប៉ុណ្ណោះ។ ខ្មែរក្រហមបានផ្លាស់ចេញទៅភូមិដទៃទៀតរួចទៅហើយ ដូច្នេះ គ្មានការប្រយុទ្ធ



Deleted: Unrevised translation. A revised translation will be provided by ITU upon request.

គ្នាទៀតទេនៅក្នុងភូមិរបស់ខ្ញុំ។ ប៉ុន្តែ មុនពេលខ្មែរក្រហមផ្លាស់ចេញ ពួកគេបានបង្ខំឱ្យប្រជាជនក្នុងភូមិជីករណ្តៅកប់ខ្លួនឯង។ ជាសំណាងល្អ ពួកទាហានវៀតណាមបានចូលមកដល់ទាន់ពេល ដូច្នេះ គ្មាននរណាម្នាក់ត្រូវគេសម្លាប់ឡើយ។ ខ្ញុំនៅតែបន្តធ្វើជាឆ្មបទៀតសូម្បីតែរបបខ្មែរក្រហមរលាយបាត់ក្តី។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**[Chapter 7]**

## ជំពូកទី ៧៖ ការសម្រាលកូន

ការមានផ្ទៃពោះគឺជាបទពិសោធន៍ដ៏លំបាកខ្លាំងណាស់សម្រាប់ស្ត្រីទាំងអស់ នៅក្នុងការស្រាវជ្រាវនេះ ប៉ុន្តែស្ត្រីជាច្រើនបាននិយាយថា ពួកគេសប្បាយចិត្តនៅពេលពួកគេបានឃើញមុខកូនរបស់ខ្លួនភ្លាមក្រោយពេលកើត[១២៩]។ ខ្ញុំតែងតែសួរសំណួរថា "តើអ្នកបានឃើញមុខកូនរបស់អ្នកភ្លាមក្រោយពេលកើតមកភ្លាមឬ? តើអ្នកមានអារម្មណ៍យ៉ាងណា?" ស្ត្រីភាគច្រើនបាននិយាយថា ពួកគេបានឃើញមុខកូនរបស់ខ្លួនហើយមានអារម្មណ៍សប្បាយរីករាយណាស់។ ដូចលោកស្រី សារ៉ន ទូន [Saron Toun] បាននិយាយថា៖ *"ខ្ញុំរំភើបខ្លាំងណាស់ពេលបានឃើញមុខកូនដំបូងរបស់ខ្ញុំភ្លាមក្រោយពេលសម្រាល។ កូនខ្ញុំស្រស់ស្អាតណាស់។ កូនខ្ញុំមើលទៅដូចជាកូនបារាំងអញ្ចឹង"*[១៣០]។ លោកស្រី ប៊ុន ផល្លា [Bun Phalla] បាននិយាយថា៖ *"ខ្ញុំរំភើបខ្លាំងណាស់ដែលបានឃើញមុខកូនស្រីរបស់ខ្ញុំនៅពេលកើតមកភ្លាម។ ខ្ញុំសប្បាយចិត្តរកពាក្យអ្វីមករៀបរាប់បានឡើយ"*[១៣១]។

ជារឿងធម្មតាទេដែលឆ្មបបុរាណ ឬចាស់ៗមួយចំនួនក្នុងភូមិជួយក្នុងការសម្រាលកូននោះ។ លោកស្រី ប៉ែន យ៉េត [Pen Yet] គឺជាស្ត្រីកសិករធម្មតាម្នាក់ ប៉ុន្តែនិយាយថា៖ *"ខ្ញុំបានចូលរួមជួយសម្រាលកូនរបស់ស្ត្រីជាច្រើន។ ដំណើរការសម្រាលត្រូវបានធ្វើឡើងតាមវិធីបុរាណ។ នៅពេលទារកកើតមក ពួកគេលាងសម្អាតទារក ហើយរុំទារកដោយក្រណាត់ចាស់ៗ ហើយប្រគល់ទារកទៅឱ្យម្តាយ ហើយកំដៅពួកគេដោយភ្លើងពីក្រោមលាយនឹងផ្សែងផងដែរ។ ការអនុវត្តតាមបែបបុរាណនេះត្រូវបានធ្វើឡើងដូចគ្នាក្នុងអំឡុងរបបខ្មែរក្រហម។ ទោះជាយ៉ាងណា ខ្មែរក្រហមមិនអនុញ្ញាតឱ្យពួកយើងធ្វើពិធីសាសនាអ្វីទេ។ ជាអកុសលទារកក៏មិនត្រូវបានថែទាំបានល្អដែរ។ វាខុសគ្នាខ្លាំងណាស់ពីការអនុវត្តតាមបែបបុរាណ"*[១៣២] ។

ស្ត្រីភាគច្រើនបានសម្រាលកូននៅផ្ទះ រីឯខ្លះទៀតបានទៅមន្ទីរពេទ្យ ប៉ុន្តែការសម្រាលកូននៅផ្ទះដោយមានការជួយពីឆ្មបក្នុងមូលដ្ឋាននៅពេលនោះគឺជារឿងទូទៅទៅហើយ។ ដូច្នេះ ស្ត្រីក៏យល់ព្រមទទួលយកការសម្រាលកូននៅផ្ទះ ហើយពួកគេមិនត្អូញត្អែរអំពីរឿងនេះឡើយ។ ភាពទុក្ខព្រួយ និងការសោកស្តាយរបស់ពួកគេច្រើនតែកើតមានដោយសារកង្វះពេលសម្រាក និងកង្វះថ្នាំបុរាណមុនពេលសម្រាល ឬកង្វះពេលសម្រាកបន្ទាប់ពីសម្រាលរួច ហើយបន្ទាប់មកពួកគេបានរំលឹកពីការខកចិត្តរបស់ខ្លួនអំពីការរឹតបន្តឹងការអនុវត្តបែបបុរាណដើម្បីស្វាគមន៍កូនកើតក្នុងគ្រួសារពួកគេ។

### ការសម្រាលកូននៅផ្ទះ

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

ក្នុងអំឡុងរបបខ្មែរក្រហម ស្ត្រីភាគច្រើនសម្រាលកូននៅផ្ទះ។ វាជារឿងធម្មតា និងទូទៅហើយ ដែលស្ត្រីសម្រាលកូននៅផ្ទះនៅមុនរបបខ្មែរក្រហម។ លោកស្រី សារ៉ន ទូន [Saron Toun] ក៏បានរំលឹកពីការសម្រាលកូនរបស់គាត់នៅផ្ទះផងដែរ[១៣៣]។

*ខ្ញុំបានសម្រាលកូននៅផ្ទះ។ ខ្ញុំមិនបានគិតដល់ការទៅសម្រាលនៅមន្ទីរពេទ្យទេ ព្រោះមន្ទីរពេទ្យគឺសម្រាប់អ្នកឈឺដែលត្រូវការការព្យាបាល។ ហេតុនេះហើយ មនុស្សភាគច្រើននៅពេលនោះមិនបានទៅមន្ទីរពេទ្យសម្រាលកូន។*

លោកស្រី ស៊ូ សាវ៉ន [Su Savorn] *"មិនសប្បាយចិត្តនឹងការមានផ្ទៃពោះនៅពេលនោះ"* និងសម្រាលកូននៅផ្ទះនោះទេ[១៣៤]។

*ខ្ញុំបានសម្រាលកូនស្រីរបស់ខ្ញុំនៅឆ្នាំ ១៩៧៧ នៅផ្ទះ។ មានស្ត្រីម្នាក់ដែលបានជួយខ្ញុំពេលខ្ញុំសម្រាល។ គាត់មិនមែនជាគិលានុបដ្ឋាយិកាទេ ប៉ុន្តែគាត់បានរៀនពីរបៀបជួយក្នុងអំឡុងពេលសម្រាលកូនពីអ្នកដែលមានបទពិសោធន៍ខ្លះៗ។ គេមិនបានយកខ្ញុំទៅមន្ទីរពេទ្យទេព្រោះម្ដាយខ្ញុំនិយាយថាការសម្រាលកូននៅផ្ទះស្រួលជាង ហើយមិនចាំបាច់នាំខ្ញុំទៅមន្ទីរពេទ្យទេ។ តាមពិត ខ្ញុំឈឺចាប់ខ្លាំងណាស់ ហើយក្រោយមកកូនខ្ញុំបានកើតចេញយ៉ាងលឿន។ មានតែម្ដាយខ្ញុំប៉ុណ្ណោះដែលនៅជាមួយខ្ញុំ ព្រោះប្ដីខ្ញុំបានស្លាប់ហើយ។ ឪពុកខ្ញុំក៏បានស្លាប់ហើយដែរ។*

មានករណីកម្រមួយដែលស្ត្រីម្នាក់បានសម្រាលកូននៅផ្ទះតែម្នាក់ឯង ដោយគ្មាននរណាម្នាក់ជួយគាត់។ លោកស្រី ម៉ោ ម៉ុន អាយុ ៧២ ឆ្នាំ បានសម្រាលកូននៅផ្ទះតែម្នាក់ឯង[១៣៥]។ ខណៈដែលស្ត្រីមួយចំនួនជ្រើសរើសសម្រាលកូននៅផ្ទះ ស្ត្រីខ្លះទៀតចង់ទៅមន្ទីរពេទ្យ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតឡើយ។ លោកស្រី អេង លីន [Eng Lin] បាននិយាយថា៖ *"ខ្ញុំត្រូវសម្រាលកូននៅផ្ទះ ដោយសារតែខ្មែរក្រហមមិនអនុញ្ញាតឱ្យខ្ញុំទៅមន្ទីរពេទ្យឡើយ"*[១៣៦]។ លោកស្រី ប៊ុន ផល្លា [Bun Phalla] គឺជាស្ត្រីម្នាក់ក្នុងចំណោមនោះ[១៣៧]។

*កូនរបស់ខ្ញុំបានកើតនៅផ្ទះ។ ខ្មែរក្រហមមិនអនុញ្ញាតឱ្យខ្ញុំទៅមន្ទីរពេទ្យឡើយ ដោយនិយាយថាគ្មានកន្លែងទំនេរសម្រាប់ខ្ញុំសម្រាលកូនឡើយនៅថ្ងៃនោះ។ ប្ដីខ្ញុំមិននៅទីនោះជាមួយខ្ញុំទេព្រោះគាត់បានទៅធ្វើការនៅឆ្ងាយពីផ្ទះជាយូរមកហើយ។ ខណៈពេលដែលខ្ញុំត្រូវសម្រាលកូនរបស់ខ្ញុំ គាត់មិនបានដឹងទេ រហូតទាល់តែមានគេប្រាប់គាត់។ ឆ្មបក្នុងភូមិម្នាក់ដែលបានក្លាយជាឆ្មបតាំងពីឆ្នាំ ១៩៥០ មក និងជាឆ្មបបុរាណដែលមានបទពិសោធន៍ម្នាក់បានមកជួយខ្ញុំ។*

ស្ត្រីភាគច្រើនមិនបានទទួលការថែទាំសុខភាពមុនសម្រាលនោះទេ ហើយភាគច្រើនសេវាបែបនោះក៏គ្មានទៅទៀត ព្រោះខ្មែរក្រហមមិនបានយកចិត្តទុកដាក់លើសុខភាពស្ត្រីមានផ្ទៃពោះឡើយ។ លោកស្រី ជូ ជួប [Chou Choub] ក៏បានកត់សម្គាល់ផងដែរថា៖ *"នៅពេលនោះ យើងជាធម្មតាមិនទៅមន្ទីរពេទ្យ*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*ដើម្បីពិនិត្យសុខភាព ឬដើម្បីសម្រាលកូនឡើយ*”[១៣៨]។ ដូច្នេះ ជាទូទៅ ស្ត្រីមិនបានដឹងពីសារៈសំខាន់នៃការពិនិត្យសុខភាពមុនពេលសម្រាលនោះទេ។

តាមប្រពៃណី ស្ត្រីមានផ្ទៃពោះផឹកថ្នាំរុក្ខជាតិបុរាណមួយចំនួន ទោះជាយ៉ាងណា ថ្នាំទាំងនោះមិនងាយស្រួលរកទេនៅក្នុងរបបខ្មែរក្រហម។ ដោយសារតែមនុស្សគ្មានពេលទំនេរធ្វើថ្នាំបុរាណទាំងនោះ។ លោកស្រី ប៊ុន ផល្លា [Bun Phalla] បាននិយាយថា ឆ្មបម្នាក់ក្នុងភូមិបានផ្សំថ្នាំធ្វើពីម្រេច និងខ្ទឹមឱ្យគាត់[១៣៩]។ បទពិសោធន៍ស្រដៀងគ្នាដែលមានគេផ្តល់ខ្ទឹមស និងម្រេចឱ្យនេះក៏ត្រូវបានរាយការណ៍ដោយស្ត្រីមួយចំនួនផងដែរនៅក្នុងខេត្តបាត់ដំបង។

ស្ត្រីមួយចំនួនក៏សម្រាលកូននៅពេលដែលមិនបានរំពឹងទុកផងដែរ ដែលភាគច្រើនប្រហែលជាមកពីពួកគេមិនបានទទួលការថែទាំសុខភាពមុនសម្រាល និងមិនបានដឹងថាពេលណាដែលកូនរបស់ខ្លួនគ្រប់ខែនោះដែរ។ លោកស្រី ផម អួន [Phom Oun] បានប្រែជាមានផ្ទៃពោះដោយសារការរៀបការដោយបង្ខំ ហើយបានសម្រាលកូននៅផ្ទះ[១៤០]។

*នៅពេលដែលខ្ញុំហៀបនឹងសម្រាលកូន ខ្ញុំបានសុំការអនុញ្ញាតពីខ្មែរក្រហមដើម្បីសម្រាល ប៉ុន្តែពួកគេបាននិយាយថា៖ “ពោះឯងតូចប៉ុណ្ណឹង តើឯងមកនិយាយថា ឯងឈឺពោះសម្រាលយ៉ាងម៉េចនឹងកើត?” ដូច្នេះ ខ្ញុំក៏មិនត្រូវបានអនុញ្ញាតឱ្យឈប់សម្រាប់សម្រាលកូនទៅ។ នៅពេលខ្ញុំរៀបចំខ្លួនទៅធ្វើការជាធម្មតា ស្រាប់តែកូនរបស់ខ្ញុំកើតតែម្តង។*

លោកស្រី ម៉ុន រ៉ាន [Mon Ran] អាយុ ៦៣ ឆ្នាំ មានកូនពីរនាក់ក្នុងរបបខ្មែរក្រហម ហើយកូនទាំងពីរសុទ្ធតែកើតនៅផ្ទះ[១៤១]។ ភ្លាមៗបន្ទាប់ពីគាត់បានមកដល់ភូមិថ្មី គាត់បានសម្រាលកូន។ គាត់បាននិយាយថា៖ *“ខ្ញុំមិនស្គាល់នរណាម្នាក់ទាំងអស់នៅក្នុងភូមិថ្មីនេះ។ ប្រហែលជាមួយខែក្រោយពីយើងផ្លាស់ទៅភូមិនោះ។ ខ្ញុំបានសម្រាលកូននៅផ្ទះ”*។ ប្តី និងម្តាយរបស់គាត់នៅជាមួយគាត់ រួមជាមួយឆ្មបម្នាក់ដែលចិត្តល្អជួយបង្កើតកូនឱ្យគាត់។ កូនគាត់កើតបញ្ច្រាសជើង ហើយគាត់ភ័យខ្លាំងណាស់ពេលដែលឆ្មបប្រាប់គាត់ថាការសម្រាលកូនរបស់គាត់នឹងពិបាកជាងការការសម្រាលធម្មតា។

*ខ្ញុំឈឺពោះសម្រាលយូរណាស់។ ការសម្រាលនោះគឺយូរមែនទែន។ ខ្ញុំឈឺពោះចាប់ពីម៉ោង ៤ ល្ងាច ហើយកូនរបស់ខ្ញុំកើតនៅម៉ោង ៨ ព្រឹក។ នៅពេលខ្ញុំឈឺពោះសម្រាល ក្បាលរបស់កូនខ្ញុំនៅបញ្ច្រាស។ ជើងរបស់កូនចេញមកមុនក្បាល។ ឆ្មបនិយាយប្រាប់ខ្ញុំថា៖ “កូនឯងចេញជើងមកមុន!” ដូច្នេះ ខ្ញុំដឹងថា កូនរបស់ខ្ញុំចេញមកខុសពីការសម្រាលធម្មតា។ នៅពេលឆ្មបប្រាប់ខ្ញុំអំពីបញ្ហានេះ ខ្ញុំខ្លាចខ្លាំងណាស់។ ប៉ុន្តែ ឆ្មបបានប្រាប់ខ្ញុំថា មិនអីទេ គាត់ប្រាប់ថា គាត់អាចធានាថា ខ្ញុំនឹងសម្រាលកូនបានដោយសុវត្ថិភាព។ ប៉ុន្តែ ការសម្រាលនោះលំបាកខ្លាំងណាស់ ហើយខ្ញុំខ្លាចណាស់នៅពេលនោះ។ ខ្ញុំចាំបានថា ឆ្មបបានដោះជើងកូនខ្ញុំម្តងម្ខាងៗពីខ្លួនខ្ញុំ។ ខ្ញុំដឹងថា ការសម្រាលបែបនោះគឺ*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*លំបាកខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនដឹងថាត្រូវធ្វើដូចម្ដេចនោះទេ ព្រោះខ្ញុំគ្រាន់តែដឹងនៅពេលកូនខ្ញុំចេញរួច។ ប៉ុន្តែ ឆ្មបដឹងថាត្រូវធ្វើដូចម្ដេច។ កូនខ្ញុំបានកើតចេញមកដោយសុវត្ថិភាព។ ខ្ញុំមានអារម្មណ៍រីករាយណាស់នៅពេលបានឃើញមុខកូនខ្ញុំក្រោយពេលសម្រាលរួច។ ខ្ញុំពិតជារីករាយ និងស្រឡាញ់កូនខ្ញុំណាស់។ ប្ដីខ្ញុំក៏សប្បាយចិត្តខ្លាំងដែរ ហើយគាត់មើលថែទាំកូនយើងបានយ៉ាងល្អ។ ប្ដីខ្ញុំឈ្មោះ កុល ដូច្នេះយើងដាក់ឈ្មោះកូនយើងថា កយ [Koi] ។*

ការសម្រាលកូនរបស់គាត់ទទួលបានជោគជ័យ ហើយទាំងម្ដាយ និងឪពុកសប្បាយចិត្តខ្លាំងណាស់នៅពេលកូនរបស់ខ្លួនបានកើតមកដោយសុវត្ថិភាព បន្ទាប់ពីឈឺពោះសម្រាលយ៉ាងយូរ។ គាត់កើតបានកូនមានមួយទៀតក្នុងរបបខ្មែរក្រហម ហើយកូនគាត់ឈ្មោះ ខាន់ [Khan] ប៉ុន្តែគាត់ស្លាប់ទៅវិញនៅពេលកើតបានមួយថ្ងៃ។ ជាអកុសល ប្ដីរបស់គាត់ក៏ត្រូវគេសម្លាប់ផងដែរនៅក្នុងរបបខ្មែរក្រហម។

នៅពេលនោះ ការសម្រាលកូននៅផ្ទះមិនមែនជារឿងចម្លែកទេ ប៉ុន្តែ សូម្បីតែនៅក្នុងករណីត្រូវសង្គ្រោះបន្ទាន់ ក៏ប្រហែលជាគ្មានមន្ទីរពេទ្យ ឬគ្រូពេទ្យជួយដល់ស្ត្រីជាម្ដាយដែរ។

**ការសម្រាលកូននៅមន្ទីរពេទ្យ**

មិនថាស្ត្រីសម្រាលកូននៅផ្ទះ ឬនៅមន្ទីរពេទ្យមិនអាស្រ័យលើឋានៈក្នុងសង្គម ជាប្រជាជនមូលដ្ឋាន ឬប្រជាជនថ្មីឡើយ។ វាអាស្រ័យលើភាពដែលអាចរកបាននៃមន្ទីរពេទ្យ (ឬភាពទំនេរនៅក្នុងមន្ទីរពេទ្យ) តាមតំបន់រស់នៅនោះទៅវិញទេ។ ដូចគ្នាផងដែរ ស្ត្រីមួយចំនួនបានជ្រើសរើសមិនទៅមន្ទីរពេទ្យតែម្ដង។

លោកស្រី ស៊ូ ឱម [Su Om] និង លោកស្រី មុំ ហាន អាយុ ៦៤ ឆ្នាំ សម្រាលកូននៅក្នុងមន្ទីរពេទ្យតែមួយនៅក្នុងខេត្តសៀមរាប។ ពួកគេទាំងពីរបាននិយាយថា ជារឿង "ធម្មតា" ទេដែលស្ត្រីទៅមន្ទីរពេទ្យនោះសម្រាលកូន ទោះជាគ្មាននរណាម្នាក់និយាយពីរឿងនោះក្ដី។ លោកស្រី ស៊ូ ឱម [Su Om] និយាយថា គាត់គ្រាន់តែទៅតាមស្ត្រីផ្សេងៗទៀតទៅមន្ទីរពេទ្យនោះប៉ុណ្ណោះ[១៤២]។

*មានស្ត្រីច្រើនណាស់ដែលបានសម្រាលកូននៅមន្ទីរពេទ្យនោះដូចខ្ញុំដែរនៅពេលនោះ។ ប្រហែលជាជាងសាមសិបនាក់ ប៉ុន្តែខ្ញុំមិនប្រាកដថាប៉ុន្មាននោះទេ។ ពួកគេមកពី ផ្ទង់ ហើយក្រោយមកពួកគេទាំងអស់ប្រមូលផ្ដុំគ្នានៅទីនោះដើម្បីសម្រាលកូន។*

លោកស្រី កែវ កែន [Keo Keon] ក៏បានសម្រាលកូននៅក្នុងមន្ទីរពេទ្យដែរ ប៉ុន្តែនៅក្នុងតំបន់នោះគេកម្រទៅមន្ទីរពេទ្យសម្រាលកូនណាស់នៅពេលនោះ ហើយគាត់បានសូកប៉ាន់គេដើម្បីបានសម្រាលកូននៅមន្ទីរពេទ្យ[១៤៣]។

*ខ្ញុំមិនចង់មានកូនទេក្នុងអំឡុងរបបខ្មែរក្រហម ព្រោះយើងគ្មានម្ហូបអាហារគ្រប់គ្រាន់ហូបនោះទេ។ ខ្ញុំមិនដែលមានសាប៊ូកក់សក់ទេ ហើយខ្ញុំតែងតែស្រមៃចង់ទៅផ្សារទិញសម្លៀកបំពាក់ថ្មីមួយចំនួន។*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

*ខ្ញុំបានសម្រាលកូននៅមន្ទីរពេទ្យដោយសារខ្ញុំស្គាល់គេម្នាក់ដែលធ្វើការនៅមន្ទីរពេទ្យនោះ និងឱ្យមាសទៅគេខ្លះដើម្បីបានថ្នាំ និងស្រាដើម្បីដោះដូរឱ្យខ្ញុំអាចសម្រាលកូននៅមន្ទីរពេទ្យ បាន។*

សំណូកផ្សេងៗត្រូវបានគេរាយការណ៍នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែមានស្ត្រីតែម្នាក់គត់ដែលបានរាយការណ៍ថាបានសូកប៉ាន់គេដើម្បីឱ្យគាត់បានសម្រាលកូននៅមន្ទីរពេទ្យ។ ដោយសារតែការអនុវត្តពីបុរាណមកដែលស្ត្រីសម្រាលកូននៅផ្ទះ ជារឿងធម្មតាទេដែលកូនកើតនៅផ្ទះដោយមានជំនួយពីឆ្មបបុរាណនោះ។

លោកស្រី ឡាច ផុន [Lach Phon] អាយុ ៦៨ ឆ្នាំ គឺជាប្រពន្ធរបស់ទាហានខ្មែរក្រហមម្នាក់ ហើយត្រូវបានអ្នកដឹកនាំខ្មែរក្រហមស្តីបន្ទោសឱ្យដោយសារតែគាត់មិនសម្រាលកូននៅមន្ទីរពេទ្យ[១៤៤]។ *"ខ្ញុំត្រូវគេណែនាំឱ្យទៅមន្ទីរពេទ្យដើម្បីសម្រាលកូន ប៉ុន្តែខ្ញុំចាប់ផ្តើមឈឺពោះសម្រាលភ្លាមៗ។ ខ្ញុំមិនអាចទៅមន្ទីរពេទ្យបានទេ ដូច្នេះ ខ្ញុំបានសម្រាលកូននៅផ្ទះ។ មានថ្នាំពេទ្យច្រើនណាស់នៅមន្ទីរពេទ្យខ្មែរក្រហម។ ប៉ុន្តែសម្រាប់ខ្ញុំ ដោយសារខ្ញុំមិនបានទៅមន្ទីរពេទ្យ ពួកគេមិនបានឱ្យថ្នាំអ្វីមកខ្ញុំនោះទេ។ ពួកគេខឹងខ្ញុំដែលមិនធ្វើតាមការណែនាំរបស់ពួកគេ"*។

**ការសម្រាលកូនដោយគ្មានគ្រូពេទ្យ ឬប្តី**

ស្ត្រីជាច្រើនបានរំលឹកដោយភាពទុក្ខព្រួយ ឬកំហឹងថា ប្តីរបស់ខ្លួនមិនបានមើលថែទាំពួកគេទេនៅពេលសម្រាលកូន។ ភាគច្រើន ប្តីនៅធ្វើការងារឆ្ងាយ ហើយខ្មែរក្រហមមិនអនុញ្ញាតឱ្យពួកគេត្រឡប់មកវិញមើលប្រពន្ធរបស់ពួកគេទេ។ លោកស្រី រ៉ុន [Ron] បាននិយាយថា ប្តីគាត់មិនអាចនៅជាមួយគាត់ទេ ហើយគាត់ខឹងណាស់ដែលគាត់មិនបានមក[១៤៥]។

*ប្តីខ្ញុំមិនបាននៅជាមួយខ្ញុំពេលកូនយើងកើតនោះ។ គាត់ត្រូវធ្វើការ និងនៅឆ្ងាយពីខ្ញុំ។ ខ្ញុំមានអារម្មណ៍ខឹងបន្តិចដែរ ព្រោះខ្ញុំមានតែម្នាក់ឯង។ ខ្ញុំមិនចង់រំលឹកពីពេលនោះទេ។ តាមពិត ខ្ញុំខឹងខ្លាំងណាស់។ ប្តីខ្ញុំ និងខ្ញុំមិនអាចរស់នៅជាមួយគ្នាបានទេនៅពេលនោះ។ ខ្មែរក្រហមមិនបានផ្តល់ថ្នាំអ្វីឱ្យខ្ញុំទេ ដូច្នេះប្តីខ្ញុំបានទៅព្រៃរកថ្នាំបុរាណខ្លះៗ ហើយគាត់កាត់ឫសឈើដាំទឹកឱ្យខ្ញុំផឹក។ យើងមិនអាចធ្វើពិធីប្រពៃណីខ្មែរសម្រាប់កូនខ្ញុំទេ។ ប្តីខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលយើងមានកូន។ ទោះជាយ៉ាងណា ប្តីខ្ញុំបានទៅធ្វើការឆ្ងាយពីពួកយើង។ យើងមិនដែលបានរស់នៅជុំគ្នាទេនៅក្នុងរបបខ្មែរក្រហម។ ខ្មែរក្រហមមិនអនុញ្ញាតឱ្យគាត់រស់នៅជាមួយយើងទេ ដូច្នេះ គាត់ព្យាយាមមកលេងយើងតែពេលខ្លះប៉ុណ្ណោះ។ នៅពេលគាត់ត្រូវចាកចេញពីពួកយើងដើម្បីត្រឡប់ទៅធ្វើការវិញ គាត់មានអារម្មណ៍សោកស្តាយខ្លាំងណាស់ ហើយគាត់តែងតែថើបកូនយើងមុនពេលចាកចេញ។ ខ្មែរក្រហមអាក្រក់ខ្លាំងណាស់។ ពួកគេបានបង្ខំឱ្យយើងធ្វើការ សូម្បីតែពេលយើងមានផ្ទៃពោះក្តី ហើយគេមិនឱ្យយើងនិយាយពីអ្វីទាំងអស់។ ប្រសិនបើយើងនិយាយប្រឆាំងនឹងពួកគេ គេនឹងសម្លាប់យើងមិនខា*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*ន។ បើខ្ញុំអាចជ្រើសរើសជីវិតខ្លួនឯងបាន ខ្ញុំមិនចង់មានកូនក្នុងអំឡុងរបបខ្មែរក្រហមនោះទេ។ យើងគ្មានថ្នាំពេទ្យទេ ហើយពេលនោះគឺលំបាកវេទនាខ្លាំងណាស់។*

ជាអកុសល ស្ត្រីជាច្រើនបានបាត់បង់ប្ដីរបស់ខ្លួនខណៈពេលដែលពួកគេមានផ្ទៃពោះ ឬទទួលដំណឹងថា ប្ដីរបស់ពួកគេស្លាប់បន្ទាប់ពីកូនកើតមក។ ប្ដីរបស់លោកស្រី សាវ៉ន [Savorn] ត្រូវគេសម្លាប់បាត់ទៅហើយពេលដែលកូនរបស់ខ្លួនកើត ប៉ុន្តែគាត់មិនបានដឹងទេ[១៤៦]។

*ការចងចាំដ៏ពិបាក និងឈឺចាប់បំផុតពីរបបខ្មែរក្រហមគឺ ប្ដីខ្ញុំមិនបាននៅជាមួយខ្ញុំទេនៅពេលខ្ញុំសម្រាលកូនស្រីរបស់ខ្ញុំ។ គាត់ត្រូវខ្មែរក្រហមសម្លាប់បាត់ទៅហើយនៅពេលកូនខ្ញុំកើត។ ដូច្នេះ នៅពេលខ្ញុំមានកូន មានតែម្ដាយខ្ញុំប៉ុណ្ណោះដែលនៅមើលថែខ្ញុំ។ ខ្ញុំតែងតែគិតថា បើសិនជាប្ដីខ្ញុំនៅរស់វិញ គាត់នឹងជួយខ្ញុំបានខ្លះ ហើយខ្ញុំអាចមានអាហារខ្លះហូបដែរ។ អ្នកសាកស្រមៃមើលថាតើមានអ្វីកើតឡើងចំពោះអ្នក បើសិនជាអ្នកសម្រាលកូនដោយគ្មានប្ដី ត្រូវធ្វើការធ្ងន់ៗដោយគ្មានអាហារ និងគ្មាននរណាម្នាក់ផ្ដល់អ្វីឱ្យយើងនោះ។*

លោកស្រី ស៊ូ ឱម [Su Om] ក៏បានរំលឹកផងដែរថា៖ *"នៅពេលកូនខ្ញុំកើត ប្ដីខ្ញុំអាចមកលេងយើងបានតែ ៣ ថ្ងៃប៉ុណ្ណោះ។ គាត់មកមែន ប៉ុន្តែដូចគាត់អត់មកអញ្ចឹងដែរ។ គាត់បានត្រឡប់ទៅវិញភ្លាមបន្ទាប់ពីជួបកូនគាត់ និងខ្ញុំរួច។ យើងគ្មានភ្លើងប្រើទេ។ យើងប្រើឫស្សីដើម្បីបំភ្លឺផ្ទះ។ យើងគ្មានចាន ឆ្នាំង ឬភួយខ្នើយអ្វីទាំងអស់។ យើងគ្មានអ្វីនោះទេ។ គេមិនឱ្យស្រោងលុំខ្ញុំទេ ប៉ុន្តែគេឱ្យម្រេច និងខ្ទឹមមកខ្ញុំ"*[១៤៧]។

សូម្បីតែនៅពេលប្ដីសុំខ្មែរក្រហមទៅមើលប្រពន្ធខ្លួន ក៏ភាគច្រើនខ្មែរក្រហមមិនយល់ព្រមដែរ។ លោកស្រី នង ឃុត [Norng Khut] អាយុ ៧០ ឆ្នាំ បានបាត់បង់កូនភ្លោះរបស់គាត់នៅពេលកើត។ គាត់និយាយថា៖ *"ប្ដីខ្ញុំមិនត្រូវបានអនុញ្ញាតឱ្យនៅជាមួយខ្ញុំឡើយក្នុងអំឡុងពេលសម្រាលកូនដ៏លំបាកនោះ។ ខ្មែរក្រហមនិយាយជាមួយយើងថា "តើឯងជាគ្រូពេទ្យឬ? ហេតុអ្វីបានជាចង់ទៅមើលប្រពន្ធឯង? យើងមានគ្រូពេទ្យ និងឆ្មបផ្ទាល់របស់យើងហើយ។ ឯងមិនចាំបាច់ទៅទីនោះជាមួយប្រពន្ធឯងទេ"*[១៤៨]។

### ការសម្រាលកូននៅក្រោលគោ

ក្នុងអំឡុងរបបខ្មែរក្រហម ប្រជាជន ជាពិសេសប្រជាជនថ្មី ជាញឹកញាប់ត្រូវគេផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត។ ពួកគេភាគច្រើនគ្មានកន្លែងស្ថិតស្ថេររស់នៅនោះទេ។ ហេតុនេះ កន្លែងសម្រាលកូនច្រើនផ្សេងៗគ្នាត្រូវគេរាយការណ៍នៅក្នុងបទសម្ភាសន៍។ លោកស្រី អ៊ីរ៉ា [Era] បានសម្រាលកូននៅក្នុងក្រោលគោ ព្រោះនោះគឺជាផ្ទះរបស់គាត់នៅពេលនោះ[១៤៩]។

*ខ្ញុំបានសម្រាលកូនប្រុសខ្ញុំនៅក្នុងក្រោលគោ។ នោះគឺជាផ្ទះរបស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍ថាសំណាងគ្រប់គ្រាន់ហើយ។ អ្នកខ្លះប្រើតែស្មៅយកមកធ្វើផ្ទះ។ នៅពេលនោះ យើងគិតមិនដល់ថា ខ្ញុំនឹងសម្រាលកូននៅក្នុងក្រោលគោទេ។ គ្រាន់តែមានជីវិតនៅរស់គឺគ្រប់គ្រាន់ហើយ។ យើងអត់*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

*ឃ្លានស្ទើរតែស្លាប់ទៅហើយ ដូច្នេះយើងមិនបានគិតពីគុណភាពផ្ទះរបស់យើងឡើយ។ ការគ្មានផ្ទះមិនសំខាន់ឡើយចំពោះយើង។*

*ខ្ញុំចាប់ផ្តើមឈឺចាប់ពោះសម្រាលនៅពេលព្រឹក ហើយកាន់តែឈឺខ្លាំងទៀតនៅរង្វង់ថ្ងៃត្រង់។ ខ្ញុំបានសុំច្បាប់ខ្មែរក្រហមសម្រាកពីការងារដោយសារតែឈឺពេក។ ម្តាយខ្ញុំតែងតែបន់ស្រន់ឱ្យខ្ញុំសម្រាលកូនបានជោគជ័យ ដោយសារតែនោះជាកូនដំបូងរបស់ខ្ញុំ។ ជើងខ្ញុំឡើងហើម ហើយមានគេប្រាប់គ្រូសារខ្ញុំឱ្យរកផ្កាឈូកបន់ស្រន់ឱ្យខ្ញុំ។ ខ្ញុំឈឺចាប់ខ្លាំងណាស់ដោយសារតែកូនខ្ញុំធ្ងោសខ្លាំងពេក។ កូនខ្ញុំកើតនៅម៉ោង ២:១៥ នាទីរសៀល។ ខ្ញុំឈឺចាប់ពេក ហើយខ្ញុំគ្មានកម្លាំងទេដោយសារតែខ្ញុំមិនបានហូបត្រីសាច់អ្វីឡើយ។*

*ភ្លាមៗបន្ទាប់ពីកូនខ្ញុំកើត គេដាក់កូនខ្ញុំលើខ្លួនរបស់ខ្ញុំដើម្បីឱ្យខ្ញុំឃើញមុខគាត់ ប៉ុន្តែខ្ញុំហត់ពេក។ ខ្ញុំគ្រាន់តែមើលមុខកូនប្រុសខ្ញុំ ហើយញញឹមប៉ុណ្ណោះ បន្ទាប់មក ប្តីខ្ញុំបានយកកូនខ្ញុំទៅងូតទឹក សម្អាតខ្លួន។ នៅថ្ងៃនោះ គាត់មិនបានទៅធ្វើការទេ។ គាត់បានសុំការអនុញ្ញាតនៅជាមួយខ្ញុំ។ ដូច្នេះ ប្តីខ្ញុំបានខ្ចីនាឡិកាដៃពីខ្មែរក្រហមដើម្បីមើលម៉ោងពេលកូនរបស់យើងកើតមក។ ថ្ងៃនោះគឺថ្ងៃ ច័ន្ទ។ បន្ទាប់មក ខ្ញុំត្រូវដេកអាំងភ្លើងលើគ្រែ។ ប្តីខ្ញុំមិនបានរើសអុសមកត្រូវ ធ្វើឱ្យមានផ្សែងខ្លាំងពេក និងបានប៉ះពាល់ដល់កូនរបស់ខ្ញុំ។*

ក៏មានស្ត្រីដែលសម្រាលកូននៅក្នុងព្រៃផងដែរ។ លោកស្រី ឆន ឆេន [Chn Chen] អាយុ ៦០ ឆ្នាំ បាននិយាយថា គាត់បានឃើញស្ត្រីម្នាក់ដែលបានសម្រាលកូននៅក្នុងព្រៃដោយគ្មាននីតិវិធី ត្រឹមត្រូវដែលចាំបាច់សម្រាប់ការសម្រាលកូនឡើយ[១៥០]។

**ការអនុវត្តតាមបែបប្រពៃណី**

បន្ទាប់ពីកូនកើតមក គ្មានការប្រារព្ធពិធីតាមបែបប្រពៃណីណាត្រូវបានអនុញ្ញាតដើម្បីប្រទានពរដល់ជីវិតថ្មីឡើយ។ លោកស្រី ប៊ុន ផល្លា [Bun Phalla] និយាយរួមនឹងការសោកស្តាយថា៖ *"ខ្ញុំមិនអាចរៀបចំពិធីប្រពៃណីឱ្យកូនស្រីខ្ញុំបានទេ ព្រោះខ្មែរក្រហមមិនអនុញ្ញាតឱ្យនរណាម្នាក់ធ្វើពិធីប្រពៃណីអ្វីទាំងអស់"*[១៥១]។ លោកស្រី ហ៊ុន សុន [Hun Son] មានកូនពីរនាក់ក្នុងរបបខ្មែរក្រហម ម្នាក់នៅឆ្នាំ ១៩៧៥ និងម្នាក់ទៀតនៅឆ្នាំ ១៩៧៨។ កូនដំបូងរបស់គាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហម[១៥២]។

*គ្មានការប្រារព្ធពិធីប្រពៃណីសម្រាប់កូនដែលទើបនឹងកើតត្រូវគេអនុញ្ញាតឡើយ នៅក្នុងរបបខ្មែរក្រហម ជាពិសេសបើធៀបទៅនឹងពេលមុនរបបខ្មែរក្រហម។ ខ្ញុំខ្លាចខ្មែរក្រហមណាស់ ព្រោះពួកគេបង្ខំប្រជាជនទាំងអស់មិនឱ្យជឿលើអបិយជំនឿណាមួយឡើយ។ យើងត្រូវគេបង្ខំឱ្យស្លៀកខ្មៅ និងកាត់សក់ឱ្យខ្លីផងដែរ។ បើយើងមិនព្រមធ្វើតាមការណែនាំរបស់គេទេ យើងនឹងត្រូវគេបញ្ជូនទៅជំរំកសាងមិនខាន។*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

ស្ត្រីទាំងអស់នៅក្នុងខេត្តបាត់ដំបងបានរាយការណ៍ថា ពួកគេបានផឹកស្រាសបន្ទាប់ពីសម្រាលកូនរួច។ ជាក់ស្តែងណាស់ នេះគឺជារឿងធម្មតាទៅហើយ ហើយស្ត្រីនិយាយអំពីរឿងនេះដោយបើកចំហ។ ស្ត្រីភាគច្រើន សើចទាំងអៀនខ្មាសនៅពេលនិយាយអំពីរឿងនេះ។ ភាគច្រើនប្រហែលជាគេមានអារម្មណ៍ថា ទង្វើនេះមិនមែនជាការអនុវត្តតាមបែបប្រពៃណី "ល្អ" ដើម្បីនិយាយដោយចំហជាមួយក្មេងជំនាន់ក្រោយឡើយ ប៉ុន្តែពួកគេបាននិយាយអំពីរឿងនោះ។ លោកស្រី ស៊ូ សាវ៉ន [Su Savorn] រស់នៅខេត្តបាត់ដំបងដូចគ្នា រំលឹកពីការសម្រាលកូនរបស់គាត់នៅផ្ទះ[១៥៣]។

*ខ្ញុំមិនបានទទួលថ្នាំអ្វីទាំងអស់ក្រោយពីសម្រាលកូនរួច។ ប៉ុន្តែខ្ញុំទទួលបានស្រាស ២ ដបពីប្រធានភូមិ។*

លោកស្រី សារ៉េត [Sareth] រស់នៅក្នុងខេត្តកំពង់ចាមនៅពេលគេផ្តល់ស្រាសឱ្យគាត់។ ដូច្នេះ ការអនុវត្តបែបប្រពៃណីដោយផឹកស្រាសនេះមិនត្រូវបានកម្រិតទេនៅក្នុងតំបន់ខេត្តបាត់ដំបង[១៥៤]។

*នៅពេលកូនខ្ញុំកើតមក ខ្ញុំបានឃើញមុខកូនរបស់ខ្ញុំ ហើយខ្ញុំរីករាយណាស់។ ខ្ញុំបានសម្រាលកូននៅផ្ទះ ហើយគ្រូពេទ្យម្នាក់មកពីឃុំបានមកជួយខ្ញុំ។ ទោះជាយ៉ាងណា គ្មានថ្នាំពេទ្យឡើយ។ នៅពេលខ្ញុំមានកូនទីមួយរបស់ខ្ញុំ ខ្មែរក្រហមបានឱ្យស្រាសមកខ្ញុំ ៣ លីត្រ ហើយខ្ញុំក៏បានប្រើថ្នាំបុរាណមួយចំនួនផងដែរ។*

ការអនុវត្តដូចគ្នាក៏ត្រូវបានរាយការណ៍ផងដែរនៅក្នុងខេត្តព្រៃវែង ហើយ លោកស្រី អេង [Eng] ក៏ត្រូវគេផ្តល់ស្រាសឱ្យផងដែរ។ *"នៅពេលកូនខ្ញុំកើតមក ខ្មែរក្រហមបានផ្តល់ស្រាសឱ្យខ្ញុំ ៣ លីត្រ ហើយខ្ញុំត្រូវបានអនុញ្ញាតឱ្យសម្រាករយៈពេល ៦០ ថ្ងៃ"*[១៥៥]។

ទំនៀមទម្លាប់ "ផឹកស្រា" នេះបានធ្វើឱ្យសិស្សស្រីៗរបស់ខ្ញុំភាគច្រើនរន្ធត់។ ជាក់ស្តែង ក្មេងជំនាន់ក្រោយមានការយល់ដឹងច្រើន ហើយពួកគេដឹងថា ស្រាអាចជះឥទ្ធិពលអវិជ្ជមានដល់សុខភាពរបស់ម្តាយ និងទារកទើបនឹងកើត។ ខ្ញុំក៏ត្រូវគេផ្តល់ស្រាបែបប្រពៃណីដូចនោះដែរ នៅពេលខ្ញុំមានផ្ទៃពោះនៅខែ វិច្ឆិកា ឆ្នាំ ២០១០ ហើយនៅពេលនោះ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ អ្នកមើលថែទាំខ្ញុំ លោកស្រី ប៉ាក់ មកពីខេត្តកំពង់ឆ្នាំង បានជួយកូនគាត់ឱ្យមានកូន ២០ នាក់រួចមកហើយនៅពេលនោះ (ក្រោយមក ចៅទី ២១ របស់គាត់ក៏បានកើតដែរក្នុងឆ្នាំ ២០១៣)។ ស្រាសនេះខ្លាំងណាស់ ហើយមានជាតិផ្លែឈើច្រើន ដើម្បី "ខាត់ស្បែកទារកឱ្យក្លាយជាស"។ គាត់បានធ្វើស្រាសជាង ២ លីត្រឱ្យខ្ញុំ ព្រោះនោះគឺជាបរិមាណដែលស្ត្រីម្នាក់អាចផឹកបាននៅពេលគាត់សម្រាលកូនរួច។ គាត់មានមោទនភាពណាស់ដែលកូនស្រីរបស់គាត់ទាំងអស់បានផឹកស្រាសនោះដែរ។ គាត់បានណែនាំខ្ញុំឱ្យផឹកស្រាសនោះភ្លាមបន្ទាប់ពីកូនខ្ញុំកើតមក ដើម្បីបន្ថយការឈឺចាប់។ ខណៈពេលដែលខ្ញុំមានផ្ទៃពោះ គេមិនឱ្យខ្ញុំផឹកច្រើនពេកទេ។

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

លោកស្រី ជូ ជួប [Chou Choub] បានសម្រាលកូននៅផ្ទះ និងបានធ្វើតាមបែបបទប្រពៃណីខ្លះៗ សម្រាប់ខ្លួនឯង ប៉ុន្តែមិនមែនសម្រាប់កូនរបស់គាត់ទេ ហើយគាត់នៅតែសោកស្តាយឥឡូវនេះ[១៥៦]។

*នៅពេលនោះ យើងជាធម្មតាមិនទៅមន្ទីរពេទ្យដើម្បីពិនិត្យសុខភាព ឬសម្រាលកូននោះទេ។ យើងប្រើតែវិធីសាស្ត្របុរាណប៉ុណ្ណោះ។ ខ្ញុំបានសម្រាលកូនដំបូងរបស់ខ្ញុំនៅមន្ទីរពេទ្យ ហើយខ្ញុំពិតជាមានអារម្មណ៍ថា មានផាសុខភាពជាងពេលទៅសម្រាលកូននៅមន្ទីរពេទ្យបែបនោះ។ ប៉ុន្តែខ្ញុំមិនបានជឿទុកចិត្តលើមន្ទីរពេទ្យខ្មែរក្រហមទេ។ នៅពេលខ្ញុំមានផ្ទៃពោះ ខ្មែរក្រហមមិនបានផ្តល់ថ្នាំអ្វីដល់ខ្ញុំនោះទេ។ ប៉ុន្តែ ក្រោយពេលសម្រាលកូនរួច ខ្ញុំត្រូវអាំងភ្លើងដែលនៅក្រោមគ្រែដើម្បីកម្តៅខ្លួនខ្ញុំជាមួយនឹងកូន រយៈពេល ៣ ថ្ងៃ។ អ្នកខ្លះប្រើភ្លើងអាំងខ្លួនឯងដោយលាយជាមួយទឹកអំបិលដើម្បីធ្វើឱ្យឈាមរត់ស្រួល និងបង្ការកុំឱ្យមានជាំមុខ។ ខ្ញុំក៏បានផឹកស្រាថ្នាំបុរាណដើម្បីកម្តៅខ្លួន និងឱ្យឈាមរត់ស្រួលផងដែរ។ ប្តីរបស់ខ្ញុំបានចេញទៅក្រៅរកថ្នាំឱ្យខ្ញុំ ប៉ុន្តែគាត់មិនបានឈប់សម្រាកនោះទេ។ ប្តីរបស់ខ្ញុំបានដើររកស្រាថ្នាំបុរាណនេះនៅក្នុងតំបន់មួយទៀតជាសម្ងាត់។ ជាអកុសល ខ្ញុំមិនអាចធ្វើពិធីប្រពៃណីសម្រាប់កូនខ្ញុំបានទេនៅក្នុងរបបខ្មែរក្រហម។*

បន្ថែមពីលើស្រាបុរាណ ការកម្តៅខ្លួនម្តាយ និងកូនដែលទើបនឹងកើត រួមជាមួយនឹងផ្សែងពីក្រោមគ្រែ ត្រូវគេរាយការណ៍ថាមានជាទូទៅនៅក្នុងតំបន់ភាគច្រើនទាំងអស់[១៥៧]។ លោកស្រី សារ៉ន [Saron] ក៏ធ្វើតាមបែបបទជាប្រពៃណីនេះផងដែរបន្ទាប់ពីសម្រាលកូនរួច[១៥៨]។

*ស្ថានភាពនៅក្នុងតំបន់ខ្ញុំយ៉ាប់ខ្លាំងណាស់ ដូច្នេះខ្ញុំនៅតែផ្ទះ និងមើលថែសុខភាពខ្ញុំប៉ុណ្ណោះ។ ខ្ញុំដេកនៅលើគ្រែដោយផ្សែងចេញពីភ្នក់ភ្លើងដែលនៅខាងក្រោមគ្រែ។ ពួកគេបានផ្តល់ស្រាបុរាណពីរដបដែលធ្វើពីអង្ករ ឬឫសឈើមកឱ្យខ្ញុំផឹកក្រោយពេលសម្រាលផងដែរ។ គេជឿថាស្រានោះនឹងជួយរំលាយឈាមក្នុងខ្លួនរបស់យើង។*

ស្ត្រីស្ទើរតែទាំងអស់ចាំបានថា ពួកគេបានឃើញមុខកូនរបស់ខ្លួនភ្លាមក្រោយពេលសម្រាលរួច[១៥៩]។ ជាក់ស្តែង ជារឿងធម្មតាទៅហើយដែលឆ្មបទាំងអស់ធ្វើដូចនេះ។ មានម្តាយតែម្នាក់គត់ គឺ លោកស្រី ស៊ូ ឱម [Su Om] ដែលបាននិយាយថា កូនប្រុសរបស់គាត់ ឈ្មោះ ឈុត ត្រូវឆ្មបយកទៅមួយស្របក់ បន្ទាប់ពីកើតមក ហើយក្រោយមកបានយកត្រឡប់មកវិញ។ ជាក់ស្តែងណាស់ដែលថា ស្ត្រីជាម្តាយភ័យខ្លាចថាមិនអាចឃើញមុខកូនរបស់ខ្លួនភ្លាមៗបន្ទាប់ពីកើតរួច ដូចដែលគាត់បានកត់សម្គាល់[១៦០]។

*ក្រោយពីឆ្មបយកកូនខ្ញុំត្រឡប់មកឱ្យខ្ញុំវិញ ខ្ញុំបានឃើញមុខកូនរបស់ខ្ញុំ ហើយខ្ញុំបានដាក់ខ្នើយឱ្យកូនខ្ញុំដេក។ កូនប្រុសខ្ញុំស្អាតខ្លាំងណាស់។ ខ្ញុំសប្បាយចិត្តពេលបានឃើញគាត់ តែនៅពេលនោះ ខ្ញុំគ្មានអ្វីទាំងអស់។ ខ្ញុំបានហូបតែបបរ។ ពេលនោះខ្ញុំលំបាកណាស់។ សំណាងល្អ យ៉ាងហោចណាស់ សុខភាពរបស់ខ្ញុំល្អ។*

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

Deleted: ខ្ញុំ

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

គាត់បានសម្រាលកូនក្នុងពេលតែមួយនឹងស្ត្រីជាច្រើនទៀតដែរ។ ហេតុនេះ ប្រហែលជា ឆ្មបបានធ្វើការព្យាបាលជាទម្លាប់ដូចៗគ្នាដែរនៅពេលសម្រាល។ ជាអកុសល គាត់មិនបានអនុវត្តតាមបែបប្រពៃណីទេ ដូចជា ការអាំងភ្លើង ការផឹកស្រា និងគ្មានម្រេចទេសម្រាប់ខ្ញុំ។ គាត់សឹងតែគ្មានពូកក្រាលដេកខ្លួនឯង និងកូនគាត់ផង។

មិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេដែលទារកជាច្រើននាក់មិនទាន់បានដាក់ឈ្មោះ ជាច្រើនសប្តាហ៍ ឬពេលខ្លះជាច្រើនខែ។ ទារកជាច្រើនបានស្លាប់មុនពេលគេដាក់ឈ្មោះឱ្យទៀត។ បើប្រៀបធៀបនឹងការអនុវត្តសព្វថ្ងៃដែលឪពុកម្តាយត្រៀមឈ្មោះទុកសម្រាប់កូន សឹងតែមុនពេលកូនកើតទៀតនោះ ការសម្រាលកូននៅក្នុងសម័យសង្គ្រាមគឺខុសគ្នាទាំងស្រុងតែម្តងទាក់ទងនឹងរឿងនេះ។

**បន្ទាប់ពីសម្រាលកូនរួច**

ភាគច្រើនស្ត្រីមិនត្រូវបានអនុញ្ញាតឱ្យសម្រាកច្រើនសប្តាហ៍ក្នុងពេលតែមួយនោះទេ ហើយការឈប់សម្រាកខ្លីបំផុតគឺមានរយៈពេលបីថ្ងៃ។ លោកស្រី ចាម សារួម [Cham Saroum] លោកស្រី ឡាន់ គីមហួន [Lann Kimhuan] និងលោកស្រី ញែក នេន [Nheak Nen] ត្រូវគេបញ្ជាឱ្យត្រឡប់ទៅធ្វើការវិញតែក្រោយពេល ៣ ថ្ងៃបន្ទាប់ពីសម្រាលរួចប៉ុណ្ណោះ។ លោកស្រី ញែក [Nheak] បាននិយាយថា៖ *"ខ្មែរក្រហមមិនខ្វល់ទេ ព្រោះវាមិនទាក់ទងអ្វីនឹងពួកគេឡើយ។ ខ្មែរក្រហមគ្រាន់តែបង្ខំយើងឱ្យធ្វើការឱ្យគេប៉ុណ្ណោះ។ ខ្ញុំត្រូវគេបង្ខំឱ្យត្រឡប់ទៅធ្វើការវិញតែក្នុងពេលបីថ្ងៃប៉ុណ្ណោះក្រោយពេលសម្រាលកូនរួច"*[១៦១]។ លោកស្រី មួន ជប់ [Moun Chob] អាយុ ៧១ ឆ្នាំ ត្រូវគេអនុញ្ញាតឱ្យនៅជាមួយកូនដែលទើបនឹងកើតរបស់គាត់បាន ៤ ថ្ងៃប៉ុណ្ណោះ ហើយក្រោយមកត្រូវគេបង្ខំឱ្យត្រឡប់ទៅធ្វើការវិញ។ លោកស្រី គង់ ស៊ីម [Kung Sim] អាយុ ៧៣ ឆ្នាំ ត្រូវគេបង្ខំឱ្យទៅធ្វើការវិញក្រោយ ៧ ថ្ងៃបន្ទាប់ពីសម្រាលកូនរួច។

លោកស្រី អ៊ីរ៉ា [Era] បាននិយាយថា ពេលសម្រាលកូន គាត់លំបាកខ្លាំងណាស់ ប៉ុន្តែកាន់តែលំបាកទៅទៀតក្រោយពេលកូនគាត់កើតមក ដោយសារគាត់ត្រូវគេបង្ខំឱ្យផ្លាស់ទីទៅកន្លែងថ្មី[១៦២]។

> *មួយសប្តាហ៍បន្ទាប់ពីសម្រាលកូនរួច ខ្ញុំត្រូវផ្លាស់ទី ហើយនៅពេលនោះហើយដែលខ្ញុំផ្តាច់ដោះកូនរបស់ខ្ញុំ។ ខ្ញុំបំបៅដោះកូនបានតែ ៦ ឬ ៧ ថ្ងៃប៉ុណ្ណោះបន្ទាប់ពីកូនប្រុសខ្ញុំកើតមក ព្រោះខ្ញុំមិនទាន់ធ្វើការងារអ្វីធ្ងន់។ ប៉ុន្តែ បានមួយសប្តាហ៍បន្ទាប់ពីកូនខ្ញុំកើត ខ្ញុំត្រូវផ្លាស់ទី ដោយថ្មើរជើងទៅទីនោះ។ ខ្ញុំគ្មានអ្វីជិះទេ។ ការហូរឈាមក្រោយសម្រាលកូនរបស់ខ្ញុំនៅតែបន្តរហូតពេលធ្វើដំណើរ។ យើងមិនបានខ្វល់ពីស្ថានភាពរបស់ម្តាយក្រោយពេលសម្រាលកូនរួចឡើយ។ អ្នកខ្លះបានស្លាប់ទាំងម្តាយទាំងកូនទៀតផង។ ករណីខ្លះទៀត ម្តាយស្លាប់ តែកូននៅរស់។ កូនខ្ញុំ និងខ្ញុំនៅរស់ដោយសារតែប្តីខ្ញុំគិតអំពីថ្នាំជាអាទិភាពចម្បងសម្រាប់ខ្ញុំ។*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

ជាទូទៅ ម្តាយត្រូវគេអនុញ្ញាតឲ្យសម្រាកពីមួយទៅពីរខែ។ លោកស្រី ស៊ូ សាវ៉ន [Su Savorn] បាននិយាយថា៖ *"បន្ទាប់ពីកូនខ្ញុំកើតមក ខ្ញុំបានសម្រាកនៅផ្ទះមួយខែ។ នេះជាច្បាប់របស់ខ្មែរក្រហម"*[១៦៣]។ គ្មាននរណាម្នាក់រំលឹកពីរបៀបដែលស្ត្រីត្រូវគេណែនាំអំពីការឈប់សម្រាកមាតុភាពឡើយ មានតែ លោកស្រី ស៊ូ សាវ៉ន [Su Savorn] ប៉ុណ្ណោះ ដូច្នេះ តាមមើលទៅ គ្មានច្បាប់ជាឯកសណ្ឋានអំពីការឈប់នេះទេ។ ជាទូទៅ ខ្មែរក្រហមត្រូវការកម្លាំងពលកម្មច្រើនតាមដែលអាចធ្វើទៅបានសម្រាប់បដិវត្តន៍ ដូច្នេះ អ្នកដែលអាចធ្វើការបាន គួរតែធ្វើការ។

ស្ត្រីជាច្រើនបាននិយាយថា ពួកគេមិនចាំបាច់រាយការណ៍អំពីការមានផ្ទៃពោះរបស់ខ្លួនទៅដល់ខ្មែរក្រហមឡើយ ព្រោះខ្មែរក្រហមមិនខ្វល់នោះទេ[១៦៤]។ ទោះជាយ៉ាងណា លោកស្រី ម៉ុយ រ៉ុម [Moy Rom] ស្ទើរតែត្រូវគេសម្លាប់ ព្រោះគាត់មិនបានរាយការណ៍ពីរឿងគាត់សម្រាលកូនដល់ខ្មែរក្រហម។ ការឈឺពោះសម្រាលកូនរបស់គាត់ ស្រាប់តែចាប់ផ្តើមភ្លាមៗ ហើយគាត់មិនបានរាយការណ៍ទៅខ្មែរក្រហមថាគាត់សម្រាលកូន។ ដូច្នេះ គាត់ស្ទើរតែត្រូវគេដាក់ទោសរួមជាមួយប្តីរបស់គាត់ទៅហើយឌី[១៦៥]។

> *ការមានផ្ទៃពោះរបស់ខ្ញុំគឺលំបាកខ្លាំងណាស់ ដោយសារខ្មែរក្រហមបង្ខំខ្ញុំឲ្យខំប្រឹងធ្វើការដូចនឹងស្ត្រីផ្សេងៗទៀតដែលគ្មានផ្ទៃពោះដែរ។ នៅពេលខ្ញុំមានផ្ទៃពោះជិត ៨ ខែទៅហើយ ខ្ញុំត្រូវគេបង្ខំឲ្យធ្វើការនៅភ្នំគូលែន។ ខ្មែរក្រហមមិនព្រមឲ្យខ្ញុំសម្រាកទេ។ ពួកគេបានហៅខ្ញុំថា "ប្រពន្ធទាហាន លន់ នល់"។ កូនខ្ញុំបានកើតមុនពេលកំណត់ ហើយយើងមិនបានរាយការណ៍ប្រាប់ខ្មែរក្រហមថា ខ្ញុំបានសម្រាលកូនស្ទើរតែមួយខែមុន។ បន្ទាប់ពីសម្រាលបានមួយខែ ប្តីខ្ញុំបានរាយការណ៍ទៅខ្មែរក្រហមថា ខ្ញុំមានកូនម្នាក់ហើយ។ ពេលនោះ ខ្មែរក្រហមបានស្តីបន្ទោសឲ្យ ខ្ញុំពីរឿងដែលខ្ញុំលាក់ការពិតដែលយើងមានកូនមួយនេះ។ ពួកគេចង់សម្លាប់យើងជាការដាក់ទណ្ឌកម្មពីបទលាក់រឿងសម្រាលកូនជាសម្ងាត់។*

ប្តីរបស់គាត់មុនរបបខ្មែរក្រហមគឺជាទាហាន លន់ នល់ និងបានស្លាប់មុនពេលខ្មែរក្រហមឡើងកាន់អំណាច។ គាត់ត្រូវគេបង្ខំឲ្យរៀបការនៅក្នុងរបបខ្មែរក្រហម ហើយរឿងខាងលើនេះគឺជារឿងដែលគាត់មានផ្ទៃពោះជាមួយប្តីទីពីរ។ ជាសំណាងល្អ ទាហានវៀតណាមបានចូលមករំដោះតំបន់របស់គាត់រីឯខ្មែរក្រហមបានរត់គេចខ្លួនបាត់។ នោះឯងជាហេតុផលដែលគាត់មិនត្រូវគេសម្លាប់ និងមានជីវិតរស់រានមកដល់សព្វថ្ងៃ។ គាត់បាននិយាយថា៖ *"ខ្ញុំមានសំណាងណាស់ដែលបាននៅរស់"*។

ទោះជាយ៉ាងណា អាចទៅរួចដែរសម្រាប់ស្ត្រីជាម្តាយមានប្តីជាទាហានខ្មែរក្រហមអាចរីករាយនឹងសិទ្ធិពិសេសមួយចំនួនក្រោយពេលសម្រាលកូនរួច។ លោកស្រី ឡាន់ គឹមហួន [Lann Kimhuan] អាយុ ៦៦ ឆ្នាំ បានរស់នៅក្នុងខេត្តបាត់ដំបងក្នុងរបបខ្មែរក្រហម។ គាត់បានសម្រាលកូននៅក្នុងរបបខ្មែរក្រហម និងអំឡុងពេលពរពោះ គាត់មិនដែលសប្បាយចិត្តទេ និងសឹងតែរំលូតកូនបាត់ទៅហើយបើគាត់ដឹងថាធ្វើ

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

យ៉ាងម៉េចនោះ។ ដោយសារតែគាត់ជាប្រជាជនមូលដ្ឋាន និងស្និទ្ធស្នាលនឹងអ្នកគ្រប់គ្រងរបស់ខ្មែរក្រហម (ទោះជាគាត់មិនបញ្ជាក់ខ្លួនឯងថាជាខ្មែរក្រហមក្តី) គាត់បានត្រូវគេអនុញ្ញាតឱ្យនៅជាមួយកូន និងថែទាំកូនដោយខ្លួនឯងផ្ទាល់។ ម្តាយរបស់គាត់ពេលខ្លះជួយគាត់មើលថែទាំកូនផងដែរ។ ទោះជាយ៉ាងណា ករណីបែបនោះកម្រមានណាស់ ព្រោះឪពុកម្តាយភាគច្រើនមិនអាចនៅជាមួយកូនរបស់ខ្លួនបានទេ។ សូម្បីតែម្តាយដែលបំបៅដោះកូនក៏ត្រូវគេដកចេញពីកូន និងបង្ខំឱ្យធ្វើការនៅស្រែដែរ។

**ប្តី និងការសម្រាលកូន**

ស្ត្រីភាគច្រើនមិនបាននៅជាមួយប្តីរបស់ខ្លួនឡើយនៅពេលកូនរបស់ពួកគេកើត។ ខ្មែរក្រហមមិនអនុញ្ញាតឱ្យពួកគេមកទេ ឬក្នុងករណីភាគច្រើន ប្តីគ្មានវិធីដឹងថាពេលណាប្រពន្ធរបស់ខ្លួនត្រូវសម្រាលកូនដែរ។

បើតាមការយល់ឃើញរបស់ប្តី ជីវិតរបស់ស្ត្រីជាម្តាយគឺលំបាកខ្លាំងណាស់។ លោក សូ មិត្ត [So Miith] អាយុ ៦៥ ឆ្នាំ បាននិយាយថា៖ *"ការមានកូនក្នុងរបបខ្មែរក្រហមគឺលំបាកខ្លាំងណាស់។ នៅពេលប្រពន្ធខ្ញុំមានផ្ទៃពោះ និងសម្រាលកូន ខ្ញុំស្រមៃថា ស្ត្រីដទៃទៀតក៏ឆ្លងកាត់បទពិសោធន៍ដូចគ្នានឹងប្រពន្ធខ្ញុំផងដែរ។ ក្រោយពេលកូនរបស់យើងកើត តែក្រោយពេល ១០ ទៅ ១៥ ថ្ងៃប៉ុណ្ណោះ ប្រពន្ធខ្ញុំត្រូវគេបង្ខំឱ្យធ្វើការវិញធម្មតា។ យើងគ្មានថ្នាំប្រើឡើយសូម្បីតែពេលកូនយើងឈឺក៏ដោយ។ គ្មានអាហារគ្រប់គ្រាន់សម្រាប់ម្តាយទេ។ នោះជាមូលហេតុដែលប្រពន្ធខ្ញុំមិនអាចបំបៅដោះកូនយើងបាន។ ទាំងប្រពន្ធ និងកូនខ្ញុំឃ្លានខ្លាំងណាស់ និងរងទុក្ខច្រើនទៀតផង"*[១៦៦]។

លោកស្រី ហួត យ៉ុន [Hout Yon] រំលឹកថា ប្តីរបស់គាត់បានមកជួបគាត់ និងកូននៅពេលកូនគាត់អាយុបានពីរខែកន្លះហើយ[១៦៧]។

> *ពីរខែកន្លះបន្ទាប់ពីកូនទីមួយរបស់ខ្ញុំកើតមក ប្តីរបស់ខ្ញុំទីបំផុតបានមកជួបពួកយើង។ នេះគឺដោយសារតែខ្មែរក្រហមកម្រនឹងអនុញ្ញាតឱ្យប្តីខ្ញុំត្រឡប់មកផ្ទះមើលខ្ញុំណាស់។ ពេលខ្ញុំឃើញមុខប្តីរបស់ខ្ញុំ ខ្ញុំមិនដឹងថាត្រូវប្រាប់អ្វីដល់គាត់ទេ។ ប៉ុន្តែគាត់ហាក់ដូចជាសប្បាយចិត្តខ្លាំងណាស់ដែលខ្ញុំបានសម្រាលកូនដោយជោគជ័យ។ ប៉ុន្តែ ខ្មែរក្រហមមិនអនុញ្ញាតឱ្យគាត់នៅជាមួយខ្ញុំបានយូរទេ។ យើងត្រូវគេបំបែកសឹងតែគ្រប់ពេលទៅហើយ តែយើងនៅតែមានកូន ... (សើច) ...។*

ចំពោះអ្នកដែលត្រូវធ្វើជាឪពុកគេភាគច្រើន ពួកគេលំបាកនឹងជួយប្រពន្ធគេបានណាស់ ព្រោះខ្មែរក្រហមដាក់កម្រិតឱ្យធ្វើដូច្នេះ។ ប្រការនេះបានដាក់សម្ពាធមិនឱ្យពួកគេបំពេញតួនាទីជាបុរសតាមប្រពៃណីរបស់ខ្លួន។ ពួកគេក៏រស់នៅទាំងអស់សង្ឃឹមផងដែរ។ ប្តីរបស់លោកស្រី សារ៉ន [Saron] បាននិយាយអំពីការសម្រាលកូន[១៦៨]។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*នៅពេលកូនខ្ញុំកើត ខ្ញុំមិនបានដឹងទេ ព្រោះខ្ញុំទៅធ្វើការនៅស្រែឆ្ងាយៗពីប្រពន្ធរបស់ខ្ញុំ។ សាច់ញាតិខ្ញុំបានមកប្រាប់ខ្ញុំអំពីការសម្រាលនោះ។ ខ្ញុំលឺថា គ្មានឆ្មបជួយប្រពន្ធខ្ញុំពេលសម្រាលកូននោះទេ ប៉ុន្តែមានស្ត្រីជាចាស់ទុំខ្លះបានមកផ្ទះខ្ញុំជួយប្រពន្ធខ្ញុំ។ ខ្ញុំមានអារម្មណ៍ធម្មតា ហាក់ដូចជាគ្មានអ្វីពិសេសកើតឡើងទេពេលខ្ញុំឃើញកូនរបស់ខ្ញុំ។ ខ្ញុំមិនអាចមានអារម្មណ៍អ្វីពិសេស ព្រោះយើងស្ទើរតែដាច់ពោះស្លាប់ហើយនៅពេលនោះ។ ដូច្នេះ ខ្ញុំដឹងថា កូនខ្ញុំនឹងពិបាករស់រានខ្លាំងណាស់។*

បទពិសោធន៍ទាំងនោះរបស់ប្តីដែលគេមិនអនុញ្ញាតឲ្យទៅមើលប្រពន្ធ ឬកូនរបស់ខ្លួន សុទ្ធតែជារឿងទូទៅទៅហើយនៅទូទាំងការស្រាវជ្រាវ។

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

[Chapter 8]

## ជំពូកទី ៨៖ ការរំលូតកូន

ការរំលូតកូនក្នុងរបបខ្មែរក្រហមគឺជាបញ្ហាគួរឲ្យតក់ស្លុតបំផុតមួយដែលខ្ញុំបានដឹង នៅពេលដែលខ្ញុំបានធ្វើការស្រាវជ្រាវលើអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម កាលពីឆ្នាំ ២០០៥។ ខ្ញុំបានជួបជាមួយឆ្មបម្នាក់នៅផ្ទះរបស់គាត់នៅក្រុងព្រះសីហនុ ហើយគាត់បានប្រាប់ខ្ញុំថា គាត់នៅតែសោកស្ដាយដែលគាត់បានសម្លាប់ក្មេងស្រីម្នាក់នៅក្នុងរបបខ្មែរក្រហម។ ក្មេងស្រីនោះមានផ្ទៃពោះ ប៉ុន្តែ មិនបានរៀបការ ហើយនៅក្នុងរបបខ្មែរក្រហម អ្នកណាដែលប្រព្រឹត្ត "ខុសសីលធម៌" ដូចជាការរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍ត្រូវគេផ្ដន្ទាទោស ភាគច្រើនប្រហែលជាដល់ស្លាប់។ ដូច្នេះ ស្ត្រីវ័យក្មេងម្នាក់នោះបានមកជួបឆ្មបដោយសម្ងាត់ដើម្បីសុំឲ្យគាត់រំលូតកូន។ អតីតឆ្មបម្នាក់នោះបានជួយគាត់ ប៉ុន្តែការរំលូតនោះមិនទទួល_បានជោគជ័យទេ ដូច្នេះការមានផ្ទៃពោះរបស់គាត់នៅតែបន្ត ហើយដោយហេតុនេះ គាត់ក៏ស្លាប់។ ស្ត្រីចំណាស់នោះនៅតែសោកស្ដាយដែលគាត់មិនអាចជួយក្មេងស្រីនោះបាន បើទោះជាវាមិនមែនជាកំហុសរបស់គាត់ក្ដី។

### បម្រាមនៅក្នុងសង្គមកម្ពុជា

នៅក្នុងប្រទេសកម្ពុជា ជាទូទៅ គេមិនចូលចិត្តនិយាយអំពីការរំលូតកូនទេ។ មានម្ដងនោះសិស្សស្រីរបស់ខ្ញុំ_ដែលមានផ្ទៃពោះដោយមិនចង់ និងចង់រំលូតកូន បានមករកខ្ញុំ។ គាត់បានទាក់ទងខ្ញុំដោយសួររកមន្ទីរពេទ្យណាដែលអាចជួយរំលូតកូនឲ្យគាត់ដោយសុវត្ថិភាព។ គាត់ចង់ធ្វើយ៉ាងណាឲ្យរឿងដែលគាត់រំលូតកូននឹងមិនមានគេដឹង។ ទោះជាការរំលូតកូនជារឿងស្របច្បាប់ក្រោមលក្ខខណ្ឌមួយចំនួន តាមជំនឿពុទ្ធសាសនា គេជឿជាទូទៅថា ការរំលូតកូនគឺជាអំពើសម្លាប់មនុស្ស។ ដូច្នេះ ស្ត្រីជាច្រើនស្ទាក់ស្ទើរនឹងនិយាយអំពីរឿងនេះ។

ប៉ុន្តែ ខ្ញុំប្រាកដណាស់ថា ស្ត្រីមួយចំនួនចង់រំលូតកូនមែននៅក្នុងអំឡុងរបបខ្មែរក្រហម ដោយសារតែស្ត្រីខ្លួនឯងរងទុកពីភាពស្រេកឃ្លាន និងភាពអត់ឃ្លានទៅហើយ ហើយពួកគេដឹងថា ខ្លួននឹងត្រូវលំបាកយ៉ាងណាដែលត្រូវបន្តមានផ្ទៃពោះតទៅទៀតនោះ។ ដូច្នេះ ខ្ញុំបានសួរពួកគេជាពិសេសថា៖ តើមានពេលណាមួយដែលពួកគេគិតដល់ការចង់រំលូតកូនឬទេ ហើយបើមាន តើពួកគេបាននិយាយជាមួយប្ដីរបស់គេអំពីគំនិតចង់រំលូតកូននេះ។

### ការប៉ុនប៉ងរំលូតកូន

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

មិនមែនស្ត្រីទាំងអស់សុទ្ធតែនិយាយអំពីការរំលូតកូនដោយបើកចំហនោះទេ ប៉ុន្តែស្ត្រីមួយចំនួនបាននិយាយច្បាស់ៗថា ពួកគេចង់រំលូតកូន។ លោកស្រី ញែក នេន [Nheak Nen] បាននិយាយថា៖ *"ខ្ញុំចង់រំលូតកូនបើខ្ញុំដឹងថាធ្វើយ៉ាងណាមែននោះ ព្រោះជីវិតខ្ញុំរងទុក្ខវេទនាណាស់ទៅហើយ ហើយខ្ញុំគ្មានអាហារហូបគ្រប់គ្រាន់នោះទេ"*[១៦៩]។លោកស្រី អួត ម៉េង [Out Meing] បានប្រាប់ប្តីរបស់គាត់ថា គាត់ចង់រំលូតកូន ប៉ុន្តែប្តីគាត់បានព្យាយាមនិយាយជាមួយគាត់ឲ្យផ្លាស់ប្តូរគំនិត។ គាត់បាននិយាយថា៖ *"ខ្ញុំវេទនាណាស់ពេលមានផ្ទៃពោះនោះ។ ពេលខ្ញុំចាញ់កូន ខ្មែរក្រហមបានធ្វើបាបខ្ញុំ និងបង្ខំខ្ញុំឲ្យធ្វើការទៀត"*[១៧០]។

លោកស្រី ស៊ិន សារ៉េត [Sin Sareth] បានពរពោះពីរដងក្នុងអំឡុងរបបខ្មែរក្រហម។ គាត់កើតមានអាការៈចាញ់កូនពេញមួយរយៈពេលដែលគាត់មានផ្ទៃពោះនោះ។ ប្តីគាត់ភាគច្រើននៅឆ្ងាយពីគាត់ ហើយគាត់បានរស់នៅជាមួយម្តាយក្មេក។ គាត់ពិតជាព្យាយាមបញ្ចប់គភ៌របស់គាត់ណាស់[១៧១]។

> *ខ្ញុំបានមានផ្ទៃពោះប្រហែលជា ៣ ខែក្រោយពេលរៀបការ។ ប្តីខ្ញុំសប្បាយចិត្តណាស់ដែលខ្ញុំមានផ្ទៃពោះ។ ប៉ុន្តែ ខ្ញុំឃ្លានខ្លាំងណាស់ ដូច្នេះ ពេលនោះខ្ញុំលំបាកខ្លាំងណាស់។ ប្តីខ្ញុំត្រូវគេបង្ខំឲ្យធ្វើការនៅកន្លែងឆ្ងាយពីខ្ញុំ។ គាត់មិនអាចមកជួបនិយាយជាមួយខ្ញុំ ពេលខ្ញុំកំពុងលំបាកបានទេ។ ពេលខ្លះ គេឲ្យខ្ញុំតែបបរ ៤ កូនវែក ២ ដងក្នុងមួយថ្ងៃប៉ុណ្ណោះ។ នោះជាពេលខ្ញុំមានផ្ទៃពោះលើកដំបូង ដូច្នេះ ខ្ញុំបានព្យាយាមសួរម្តាយខ្ញុំ និងចាស់ៗទាក់ទងនឹងរបៀបថែទាំសុខភាពរបស់ខ្ញុំ។ នៅពេលនោះ យើងហូបអាហាររួមគ្នា ហើយមានស្ត្រីមានផ្ទៃពោះជាច្រើននៅជុំវិញខ្លួនខ្ញុំ។ ពួកគេបានប្រាប់ខ្ញុំថាកុំឲ្យងូតទឹកនៅពេលយប់ ព្រោះកូនខ្ញុំអាចនឹងថ្លោស។ ពួកគេក៏បានណែនាំខ្ញុំឲ្យហូបអាហារប្រយ័ត្នប្រយែង ខ្ញុំមិនគួរអង្គុយនៅមាត់ទ្វារ ជាដើម។ នៅពេលខ្ញុំមានផ្ទៃពោះលើកដំបូង ខ្ញុំបានធ្វើតាមដំបូន្មានទាំងអស់នេះ។*
>
> *ប៉ុន្តែ តាមពិត ពេលខ្ញុំមានផ្ទៃពោះនោះ ខ្ញុំលំបាកខ្លាំងណាស់។ ខ្ញុំគ្មានអាហារហូបគ្រប់គ្រាន់។ គ្មានទឹកប្រើប្រាស់គ្រប់គ្រាន់ ដូច្នេះ ខ្ញុំត្រូវតែនៅស្ងាត់ស្ងៀម និងរក្សាការសម្ងាត់ពេលណាដែលខ្ញុំប្រើទឹក។ ខ្ញុំមានអាការៈចាញ់កូនគ្រប់ពេល។ ខ្ញុំចេញទឹកមាត់រហូត ដូច្នេះ នៅពេលយប់ខ្ញុំត្រូវបៀមផ្លែអំពិលរហូតដើម្បីកុំឲ្យចេញទឹកមាត់។ ក៏ដូចគ្នា ខ្ញុំត្រូវតែទុកក្រមាជូតទឹកមាត់។ ដូច្នេះ ខ្ញុំក៏បានគិតដល់ការរំលូតកូន។ ប្តីខ្ញុំ និងខ្ញុំអាចជួបគ្នាបានតែពេលខ្លះៗប៉ុណ្ណោះ ហើយយើងកម្រនឹងបាននិយាយគ្នាតែពីរនាក់ណាស់។ ប៉ុន្តែ ថ្ងៃមួយ ខ្ញុំបានសួរគាត់ថាតើគាត់គិតដូចម្តេចអំពីរឿងដែលខ្ញុំមានផ្ទៃពោះ និងរឿងដែលខ្ញុំគិតចង់រំលូតកូន។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំខ្លាចខ្លាំងណាស់ ហើយការមានកូននឹងលំបាកខ្លាំងណាស់ ព្រោះគ្មានថ្នាំសង្កូវអ្វីទាំងអស់។ គាត់បាននិយាយថា បើពួកយើងមានកូន យើងនឹងលំបាកខ្លាំងណាស់ ព្រោះយើងគ្មានអ្វីហូប ដូច្នេះគាត់បានយល់ព្រមឲ្យខ្ញុំសាកល្បងរំលូតកូន។ អូ ទេ ប្រហែលជាខ្ញុំមិនបានប្រាប់គាត់។ ប៉ុន្តែ ខ្ញុំគិតថា គាត់ដឹងពីអ្វីដែលខ្ញុំចង់ធ្វើ។*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

*ខ្ញុំភ្លេចថាតើខ្ញុំបាននិយាយរឿងនេះជាមួយគាត់ឬក៏អត់ទេ។ ទោះជាយ៉ាងណា ខ្ញុំបានព្យាយាមបញ្ចប់គភ៌របស់ខ្ញុំ ខ្ញុំដឹងថា មានស្ត្រីខ្លះដែលព្យាយាមរំលូតកូនដោយយកដុំថ្មមកវាយពោះខ្លួនឯង ឬផឹកស្រាឲ្យច្រើន។ ដូច្នេះ ខ្ញុំបានសាកល្បងផឹកស្រាដើម្បីបញ្ចប់គភ៌របស់ខ្ញុំ។ ខ្ញុំបានផឹកប្រហែលជា ២ កែវប៉ុណ្ណោះ ព្រោះខ្ញុំមិនចេះផឹកស្រាទេ និងគិតថា ប៉ុណ្ណឹងគ្រប់គ្រាន់ហើយ។ ជាអកុសល អ្វីដែលបានកើតឡើងនោះគឺ ខ្ញុំរាក ហើយខ្ញុំនៅតែបន្តមានផ្ទៃពោះដដែល។ នៅពេលនោះ យើងអាចលាក់ស្រាទុកបាន។ ខ្ញុំមិនបានប្រាប់ម្ដាយខ្ញុំនូវអ្វីដែលខ្ញុំព្យាយាមធ្វើនោះឡើយ។*

*ខ្ញុំបានមានផ្ទៃពោះម្ដងទៀតនៅក្នុងរបបខ្មែរក្រហម។ នៅពេលនោះ ខ្មែរក្រហមបានចាប់ផ្ដើមសម្លាប់មនុស្សយ៉ាងច្រើន។ ខ្ញុំគិតថា ខ្ញុំសំណាងណាស់ដែលអាចក្រោកឡើងនៅពេលព្រឹក ព្រោះនោះមានន័យថា ខ្ញុំមិនទាន់ត្រូវគេសម្លាប់ឡើយ។ ខ្ញុំអំពីរឿងរស់រានមានជីវិតគ្រប់ពេល។ ដោយមានកូនមួយនៅនឹងដៃ និងកូនមួយទៀតនៅក្នុងពោះខ្ញុំ ខ្ញុំមិនបានគិតដល់ការរំលូតកូនទេ។ ប៉ុន្តែ ខ្ញុំពិតជាពិបាកខ្លាំងណាស់។ ពេលនោះគឺនៅឆ្នាំ ១៩៧៨ ហើយលើកនោះគឺពិបាកជាងការមានផ្ទៃពោះកូនដំបូងរបស់ខ្ញុំទៀត។ ពេលនោះក៏ជាពេលដែលបងប្រុសរបស់ខ្ញុំត្រូវគេសម្លាប់ផងដែរ។*

នៅចុងបញ្ចប់នៃការសម្ភាសដ៏យូររហូតដល់ព្រលប់ ខ្ញុំបានសួរ លោកស្រី សារ៉េត [Sareth] ថាតើគាត់រំលឹកពីពេលលំបាកខ្លាំងដែលគាត់មានផ្ទៃពោះក្នុងរបបខ្មែរក្រហមយ៉ាងដូចម្ដេច។ គាត់បានឆ្លើយ ដោយសើចផងថា៖ *"ពេលខ្ញុំមានផ្ទៃពោះកូនទីពីររបស់ខ្ញុំ នៅពេលល្ងាចថ្មើរនេះចូលមកដល់ ខ្ញុំចាប់ផ្ដើមព្រួយបារម្ភ និងភ័យខ្លាចថា ខ្មែរក្រហមអាចនឹងមកសម្លាប់ខ្ញុំ។ ប៉ុន្តែពេលព្រឹកឡើង ខ្ញុំបានធូរចិត្តដែលខ្ញុំបានរស់ជីវិតមួយថ្ងៃទៀត"*។

ស្ត្រីស្ទើរតែគ្រប់ស្ត្រីបាននិយាយអំពីអំឡុងពេលមានផ្ទៃពោះរបស់ខ្លួនថាជាពេលវេទនាខ្លាំង ហើយថា ពួកគេមិនចង់មានផ្ទៃពោះទេ។ ភាគច្រើនប្រហែលជាស្ត្រីជាច្រើនចង់បញ្ចប់ការមានផ្ទៃពោះរបស់ខ្លួន ទោះជាគេមិនអាចទទួលបានព័ត៌មានត្រឹមត្រូវអំពីបញ្ហានេះ ដោយសារតែបម្រាមរបស់សង្គមមិនឲ្យនិយាយអំពីបញ្ហានេះក្ដី ជាពិសេសក្នុងចំណោមស្ត្រីចាស់ៗ។ មូលហេតុនៅពីក្រោយការសន្និដ្ឋាននេះគឺ ពួកគេគ្មានអាហារគ្រប់គ្រាន់ដើម្បីចិញ្ចឹមខ្លួនបាន ហើយពួកគេបារម្ភអំពីជីវិតកូនរបស់ខ្លួនក្រោយពេលកើតមក ជាពិសេសដោយឃើញក្មេងជាច្រើនស្លាប់នៅជុំវិញខ្លួនពួកគេ។ ជារឿងគួរឲ្យអស់សំណើចណាស់នៅពេលដែលខ្ញុំលឺ លោកស្រី ណេហៀត [Neheat] ដែលមានផ្ទៃពោះ ១២ ដងក្នុងជីវិតរបស់គាត់ និយាយថា៖ *"គ្មានស្ត្រីណាចាំបាច់រំលូតកូននោះទេ ព្រោះយើងត្រូវគេបង្ខំឲ្យធ្វើការងារធ្ងន់ណាស់ទៅហើយ រហូតដល់យើងរលូតកូនដោយឯកឯងតែម្ដង"*[១៧២] ។ ប្រការនេះគឺជាបទឧក្រិដ្ឋមួយទៀតប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រឆាំងនឹងស្ត្រីដែលត្រៀមខ្លួនជាម្ដាយដែលថា ស្ត្រីមិនអាចមានសេរីភាពក្នុងការជ្រើសរើសជម្រើសបន្តពូជបាន។ ស្ត្រីដែលត្រូវគេបង្ខំឲ្យគិតដល់ការរំលូតកូននៅពេលដែលពួកគេគួរតែសប្បាយចិត្តនឹង

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

ការស្វាគមន៍ជីវិតថ្មី។ ខ្មែរក្រហមមិនបានអនុញ្ញាតឱ្យស្ត្រីអនុវត្តសិទ្ធិនៃសុខភាពបន្តពូជរបស់ខ្លួន ហើយស្ត្រីជាធម្មតាមិនមានស្វ័យភាពលើរឿងផ្លូវភេទរបស់ខ្លួន។

**ការរំលូតកូន និងអាពាហ៍ពិពាហ៍ដោយបង្ខំ**

អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាកត្តាមួយទៀត ដែលជំរុញឱ្យស្ត្រីមួយចំនួនរំលូតកូន។ លោកស្រី ម៉ូ [Mo] អាយុ ៦៥ ឆ្នាំ បាននិយាយថា៖ *"ខ្ញុំដឹងថា ស្ត្រីមួយចំនួនបានព្យាយាមរំលូតកូនដោយសារពួកគេមិនស្រឡាញ់ប្តីរបស់ខ្លួន។ ពួកគេត្រូវពួកខ្មែរក្រហមបង្ខំឱ្យរៀបការ។ ខ្ញុំមានអារម្មណ៍អាណិតពួកគេណាស់ដែលត្រូវគេបង្ខំឱ្យរៀបការដូចនេះ"*[១៧៣] ។ ប៉ុន្តែ សំណាកគំរូនៅក្នុងការសិក្សានេះតូចពេកមិនអាច បង្កើតជាគំនិតទូទៅអំពីអារម្មណ៍របស់ស្ត្រីអំពី "ការមានផ្ទៃពោះដោយបង្ខំ" ជាលទ្ធផលនៃអាពាហ៍ពិពាហ៍ដោយបង្ខំនោះ។

លោកស្រី ផម អូន [Phom Oun] ក៏ដូចជាស្ត្រីជាច្រើនទៀតដែរ គិតអំពីការរំលូតកូនជាច្រើនដងខណៈដែលគាត់មានផ្ទៃពោះក្នុងរបបខ្មែរក្រហម។ គាត់ត្រូវគេបង្ខំឱ្យរៀបការជាមួយបុរសម្នាក់ដែលគាត់មិនដែលជួបពីមុន បន្ទាប់ពីក្តីស្រមៃចង់ក្លាយជាគ្រូពេទ្យរបស់គាត់ត្រូវបានបំផ្លាញដោយរបបខ្មែរក្រហម[១៧៤]។

**Formatted:** Condensed by 0.3 pt

> *នៅពេលខ្ញុំមានផ្ទៃពោះ ខ្ញុំបានគិតអំពីការរំលូតកូន។ ពិតជាលំបាកខ្លាំងណាស់សម្រាប់ខ្ញុំក្នុងការមានផ្ទៃពោះពេលនោះ។ សូម្បីតែក្រោយពេលកូនខ្ញុំកើតមកក្តី ជីវិតពួកគេជួបប្រទះនឹងសោកនាដកម្មយ៉ាងខ្លាំង។ ពួកគេអាចរស់នៅតែជាមួយជីដូនចាស់ៗដែលបញ្ចុកក្មេងដោយទំពារ ម្ហូបនិងបាយជាមួយគ្នា។ ខ្ញុំទ្រាំមើលរឿងនោះមិនបានទេ។ ក្មេងៗទាំងនោះឈឺច្រើនណាស់។ មើលទៅវេទនាណាស់ ហើយខ្ញុំមានអារម្មណ៍សោកស្តាយខ្លាំងណាស់ចំពោះអនាគតកូនរបស់ខ្ញុំ។ ខ្ញុំគិតថាបើកូនខ្ញុំមិនបាច់កើតមកល្អជាង។ បើខ្ញុំគ្មានកូនគឺកាន់តែប្រសើរ។ ទោះជាយ៉ាងណា ខ្ញុំមិនអាចធ្វើអ្វីបានដើម្បីបញ្ឈប់ការមានផ្ទៃពោះរបស់ខ្ញុំបានឡើយ។ យើងគ្មានមធ្យោបាយរំលូតកូនទេក្នុងអំឡុងពេលមានសង្គ្រាមនោះ។*

ខ្ញុំជឿថា ស្ត្រីជាច្រើនពិតជាបានគិតដល់ការរំលូតកូនមែន យ៉ាងហោចណាស់ម្តងក្នុងពេលមានផ្ទៃពោះ ឬពួកគេសង្ឃឹមថា គភ៌របស់ពួកគេនឹងបញ្ចប់ទៅតាមធម្មជាតិ។ រឿងរ៉ាវទាំងអស់នៃការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម ត្រូវបានបំពេញដោយភាពរងទុក្ខវេទនា និងការរងគ្រោះ ហើយក្នុងនាមខ្ញុំជាម្តាយខ្លួនឯងផ្ទាល់ ខ្ញុំស្ទើរតែមិនអាចស្រមៃថា ខ្ញុំនឹងចង់បានកូនយ៉ាងដូចម្តេចនៅពេលបែបនោះ។ ជីវិតរបស់ពួកគេក្រៀមក្រំណាស់ ពោរពេញទៅដោយការស្លាប់របស់សមាជិកគ្រួសារ និងរស់នៅដោយភាពភ័យខ្លាចថានឹងត្រូវគេសម្លាប់នៅពេលណាមួយ។

*[រូបភាព]*

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

លោកស្រី រ៉ុន [Ron] ខេត្តព្រៃវែង ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៥

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

[Chapter 12]
## ជំពូកទី ១២៖ ការរំដោះ

### ជីវិតបន្ទាប់ពីការរំដោះភ្លាម

ពេលទាហានខ្មែរក្រហមចាប់ផ្តើមចាកចេញពីតំបន់កាន់កាប់ ប្រជាជនមានការវង្វេងវង្វាន់ ហើយស្ត្រីជាច្រើនមិនដឹងថាត្រូវធ្វើអ្វីនោះទេ។ ពួកគេគ្រាន់តែធ្វើតាមបញ្ជារបស់នរណាក៏បាន ដូចដែលពួកគេបានធ្វើនៅក្នុងរបបខ្មែរក្រហម។

ស្ត្រីជាច្រើនបែកខ្ញែកពីប្តី ឪពុកម្តាយ ឬសមាជិកគ្រួសាររបស់ពួកគេ នៅពេលការរំដោះបានកើតឡើងនៅទីបំផុត។ ពួកគេត្រូវដើរត្រឡប់ទៅស្រុកកំណើតដើមរបស់ខ្លួនវិញដើម្បីស្វែងរកសមាជិកគ្រួសាររបស់ខ្លួនដែលបានបាត់ខ្លួន។ ជីដូនរបស់ អ៊ឹង លីហួរ [Ueng Lyhour] ម្តងនោះបានប្រាប់គាត់ថា៖ *"ខ្ញុំត្រូវដើរទៅភ្នំពេញពីខេត្តបាត់ដំបងជាមួយកូនស្រីរបស់ខ្ញុំ (ម្តាយរបស់ លីហួរ [Lyhour])។ យើងចំណាយពេលពីរខែដើម្បីត្រឡប់មកវិញ។ យើងគ្មានសូម្បីតែស្បែកជើងផងនៅពេលនោះ"*២១៧។

ស្ត្រីខ្លះបានសម្រាលកូនភ្លាមៗបន្ទាប់ពីការរំដោះរួច។ លោកស្រី ម៉ុន រ៉ាន [Mon Ran] ដែលបានសម្រាលកូនម្តងហើយក្នុងអំឡុងរបបខ្មែរក្រហម មានកូនមួយទៀតបន្ទាប់ពីទាហានវៀតណាមចូលមកកាន់កាប់តំបន់របស់គាត់[២១៨]។

*នៅពេលទាហានវៀតណាមចូលមករំដោះយើង ខ្ញុំបានមានផ្ទៃពោះម្តងទៀត។ ពួកគេចិត្តល្អដាក់យើងណាស់ ហើយខ្ញុំសប្បាយចិត្តដែលយើងឈប់ហូបអាហាររួមគ្នា។ ក្នុងតំបន់យើង យើងមានត្រីច្រើន ដូច្នេះ ប្តីខ្ញុំបានទៅនេសាទត្រីរាល់ថ្ងៃ។ យើងមានត្រីហូបខ្លួនឯងច្រើន។ ឥឡូវនេះយើងគ្មានត្រីច្រើនដូចនោះទេ ប៉ុន្តែនៅពេលនោះ យើងមានត្រីច្រើន។ ពេលនោះគឺខុសគ្នាខ្លាំងណាស់ពីការមានផ្ទៃពោះរបស់ខ្ញុំក្នុងអំឡុងរបបខ្មែរក្រហម។*

លោកស្រី ឡាន់ គឹមហួន [Lann Kimhuan] មានកូនប្រុសម្នាក់អាយុ ៨ ខែ នៅពេលទាហានវៀតណាមចូលមករំដោះតំបន់របស់គាត់នោះ។ គាត់ត្រូវរត់ជាមួយកូន និងម្តាយរបស់គាត់ រីឯប្តីគាត់នៅកន្លែងផ្សេងទៀត។ គាត់ត្រូវរត់គេចពីការប្រយុទ្ធគ្នានៅក្នុងព្រៃ ពីមួយថ្ងៃទៅមួយថ្ងៃ និងបានឃើញសាកសពជាច្រើននៅតាមផ្លូវ[២១៩]។

*មុនពេលកងទ័ពវៀតណាមចូលមកដល់តំបន់យើង ខ្ញុំកំពុងរស់នៅឯភ្នំដើងទិញ។ ជីវិតខ្ញុំនៅទីនោះលំបាកខ្លាំងណាស់ ព្រោះខ្ញុំគ្មានអាហារហូបគ្រប់គ្រាន់ និងគ្មានកន្លែងសមរម្យរស់នៅ។ លើសពីនេះទៀត ខ្ញុំត្រូវបីកូនប្រុសតូចអាយុ ៨ ខែរបស់ខ្ញុំតាមខ្លួនផង។ នៅពេលយោធាវៀតណាមចូលមកវាយខ្មែរក្រហមដើម្បីសង្គ្រោះយើង ខ្ញុំត្រូវបង្ខំចិត្តរត់តាមទិសដៅមួយ។ ពួកគេនិយាយ*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

ប្រាប់ពួកយើងថា យើងត្រូវទៅ "មុខ" ជាមួយនឹងអ្នកផ្សេងមួយចំនួនទៀត។ បើនរណាម្នាក់ក្នុងចំណោមយើងមិនធ្វើតាមការណែនាំនោះទេ ខ្មែរក្រហមនឹងសម្លាប់យើង។ ពេលខ្លះ ខ្ញុំត្រូវជិះរទេះគោឆ្លងកាត់វាលពិឃាដ។ ខ្ញុំបានឃើញសាកសពជាច្រើននៅតាមផ្លូវ។ ខ្ញុំបានបន្តរត់ពីកន្លែងមួយទៅកន្លែងមួយទៀត។ នៅពេលមេឃងងឹត យើងដេកនៅកន្លែងដែលយើងនៅនោះ មិនថាកន្លែងនោះជាព្រៃ ឬស្ថានភាពដីយ៉ាងណាក៏ដោយ។ ខណៈពេលដែលយើងកំពុងរត់គេចខ្លួន យើងបានឃើញឃ្លាំងស្រូវអង្ករ និងបានចូលយកអង្ករពីទីនោះ។ នៅពេលយើងបន្តរត់ទៀត យើងត្រូវយកអង្ករតាមខ្លួនរហូតដល់យើងទៅដល់ទីរួមខេត្តបាត់ដំបង។

ជាសំណាងល្អ កូនប្រុសខ្ញុំមិនបានឈឺថ្កាត់អ្វីទេអំឡុងពេលរត់គេចខ្លួននោះ ប៉ុន្តែខ្ញុំបានឈឺ។ ខ្ញុំបានសម្រាលកូនរបស់ខ្ញុំក្នុងអំឡុងរបបខ្មែរក្រហម។ ខ្ញុំនៅតែត្រូវធ្វើការធ្ងន់ដោយគ្មានអាហារ_រូបត្ថម្ភត្រឹមត្រូវ។ ខ្ញុំនឿយហត់ខ្លាំងមែនទែនគ្រប់ពេល។ ខ្ញុំបានចុះខ្សោយ និងឈឺ។ នោះក៏ដោយសារតែខ្ញុំត្រូវគេបង្ខំឱ្យធ្វើការដូចអ្នកផ្សេងទៀតដែរបន្ទាប់ពីសម្រាលកូនបានតែ ៣ ថ្ងៃប៉ុណ្ណោះ។ ខ្មែរក្រហមមិនបានឱ្យថ្នាំអ្វីដល់យើងឡើយ។ ឪពុកខ្ញុំដឹងបច្ចេកទេសខ្លះៗអំពីរបៀបធ្វើថ្នាំបុរាណ។ ហេតុនេះ គាត់បានលាយរុក្ខជាតិធម្មជាតិមួយចំនួន ជាមួយឫសឈើផ្សេងៗឱ្យខ្ញុំ។

ពេលខ្ញុំត្រឡប់ទៅផ្ទះខ្ញុំវិញជាលើកដំបូង ផ្ទះដែលយើងកំពុងរស់នៅនេះ ខ្ញុំគ្មានអ្វីហូបទេក្រៅពីរុក្ខជាតិក្នុងព្រៃ។ ប្ដីខ្ញុំមិននៅទីនោះជាមួយខ្ញុំទេ។ ពេលដែលខ្ញុំចូលទៅនៅក្នុងផ្ទះខ្ញុំវិញ ទាហានវៀតណាមមួយក្រុមបានមកដល់ផ្ទះខ្ញុំ ហើយបានសុំយើងដេកនៅក្នុងផ្ទះខ្ញុំជាច្រើនថ្ងៃ។ លើកដំបូងដែលខ្ញុំឃើញពួកគេស្លៀកពាក់ឯកសណ្ឋានកងទ័ពចូលមកជិតផ្ទះខ្ញុំ ខ្ញុំខ្លាចខ្លាំងណាស់។ មេក្រុមម្នាក់ចេះនិយាយភាសាខ្មែរយ៉ាងស្ទាត់។ គាត់បានសុំស្នាក់នៅផ្ទះខ្ញុំយ៉ាងគួរសម។ ពួកគេបានសន្យាថានឹងមិនធ្វើអ្វីយើងទេ ហើយប្រាប់យើងថា ពួកគេនឹងដេកនៅក្នុងផ្ទះដោយមិនរំខានយើងឡើយ។ ពួកគេចិត្តល្អដាក់ខ្ញុំណាស់។ ពួកគេបានជួយធ្វើការងារផ្ទះ លេងជាមួយកូនខ្ញុំ និងការពារគ្រួសាររបស់ខ្ញុំ។ ទាហានទាំងនោះក្មេងៗទេ អាយុប្រហែលជាជិត ២០ ឆ្នាំ។ មេក្រុមនោះអាយុប្រហែល ៣០ ឆ្នាំ។ ក្រោយពីបីថ្ងៃ ពួកគេបានប្រាប់ខ្ញុំថា ដល់ពេលដែលពួកគេត្រូវទៅជួយសង្គ្រោះប្រជាជនខ្មែរផ្សេងទៀតពីរបបខ្មែរក្រហមហើយ។ ក្រោយមក ខ្ញុំមិនដែលបានជួបពួកគេ ឬយោធាណាផ្សេងទៀតនៅក្នុងតំបន់នេះឡើយ។

ខណៈពេលដែលស្ត្រីមួយចំនួនចាំបានយ៉ាងច្បាស់ថាបានជួបនឹងទាហានវៀតណាម អ្នកផ្សេងទៀតចាំបានថាបានឃើញសាកសព និងក្មេងដែលត្រូវគេបោះបង់ចោល។ លោកស្រី វ៉ាន់ កេន [Van Ken] បានវិលត្រឡប់ពីខេត្តតាកែវទៅខេត្តកំពតវិញតាមរថយន្ត។ ពួកទាហានវៀតណាមបានរៀបចំរថយន្តនេះឱ្យប្រជាជនខ្មែរប្រើ។ គាត់បាននិយាយថា៖ *"នៅតាមផ្លូវទៅកំពត យើងឃើញក្មេងតូចៗជាច្រើនស្រែកយំ ឬ*

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

*គ្រាន់តែអង្គុយជាមួយសាកសពដែលនៅក្បែរខ្លួនគេនោះ។ ខ្ញុំគិតថា ម្ដាយពួកគេបានស្លាប់តាមផ្លូវ ហើយកូននៅរស់។ ខ្ញុំចាំបានថា មានក្មេងស្រីគួរឱ្យស្រឡាញ់ម្នាក់ដែលកំពុងយំ ដោយមានសាកសពម្ដាយរបស់ខ្លួននៅក្បែរនោះផង។ មីងខ្ញុំមានអារម្មណ៍សោកស្ដាយ និងអាណិតក្មេងនោះណាស់ និងសុំឱ្យយើងយកគេទៅជាមួយយើងទៅកំពត។ ប៉ុន្តែ ជីដូនរបស់ខ្ញុំបដិសេធ ហើយនិយាយថា យើងគ្មានកន្លែងទំនេរ និងគ្មានសមត្ថភាពចិញ្ចឹមក្មេងម្នាក់ទៀតទេ'*[២២០]។ បើតាមគាត់ប្រាប់ ក៏មានមនុស្សរើសក្មេងអាណាថាទាំងនោះទៅចិញ្ចឹមដែរ។

ក្រោយថ្ងៃរំដោះ មនុស្សជាច្រើនព្យាយាមស្វែងរកសមាជិកគ្រួសាររបស់ខ្លួន ហើយអ្នកខ្លះបានជោគជ័យ។ លោកស្រី គឹម សែន [Kim Sen] អាយុ ៧0 ឆ្នាំ បានបែកពីប្ដី និងកូនស្រីរបស់ខ្លួន ប៉ុន្តែជាសំណាងល្អ គាត់បានរកឃើញពួកគេទាំងពីរវិញ[២២១]។

> *នៅក្រោយរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំបានជួបជុំគ្នាវិញ។ ប្ដីខ្ញុំបានរកខ្ញុំឃើញនៅឆ្នាំ ១៩៧៩ នៅក្បាលពួរ នៅពេលទាហានវៀតណាមចូលមក។ ខ្ញុំបានរស់នៅជាមួយប្ដីខ្ញុំរហូតដល់សព្វថ្ងៃ។ នៅពេលពួកទាហានវៀតណាមបានចូលមក កូនប្រុសរបស់ខ្ញុំបានអាយុមួយឆ្នាំ។ ទាហានខ្មែរក្រហមបានប្រាប់ឱ្យខ្ញុំរត់ ប៉ុន្តែទាហានចិត្តល្អមួយចំនួនបានប្រាប់ខ្ញុំឱ្យនៅ ព្រោះបើខ្ញុំរត់ ខ្ញុំនឹងគ្មានអាហារ និងទឹកគ្រប់គ្រាន់ទេព្រោះវានៅក្នុងព្រៃ។ ទាហានវៀតណាមមិនបានធ្វើអ្វីអាក្រក់ដាក់ពួកយើងទេ។ ពួកគេប្រាប់យើងឱ្យត្រឡប់ទៅកន្លែងដែលយើងធ្លាប់រស់នៅវិញ។ ដូច្នេះ ខ្ញុំបានសម្រេចចិត្តត្រឡប់ទៅស្រុកកំណើតរបស់យើងវិញដោយសុវត្ថិភាព។ នៅពេលនោះ ខ្ញុំបានជួបជុំជាមួយកូនស្រីច្បងរបស់ខ្ញុំវិញ។ កូនខ្ញុំត្រូវអ្នកដែលបានមើលថែគាត់បញ្ជូនមកផ្ទះវិញ។*

ពិតជាមានការភាន់ច្រឡំធំមែននៅពេលនោះជុំវិញការរំដោះ។ ភាគច្រើន ខ្មែរក្រហមមិនបានជូនដំណឹងដល់ប្រជាជនថា ពួកគេកំពុងរត់គេចខ្លួនទេ ឬប្រជាជនគ្រាន់តែឃើញទាហានវៀតណាមចូលមកក្នុងភូមិប៉ុណ្ណោះ។ ស្ត្រីមួយចំនួនក៏ត្រូវបានចាប់ខ្លួននៅពេលកំពុងប្រយុទ្ធគ្នានោះផងដែរ រីឯខ្លះទៀតត្រូវបង្ខំចិត្តរត់គេចខ្លួនខណៈពេលដែលពួកគេមានផ្ទៃពោះ។ រយៈពេលដ៏ខ្លីនេះមានភាពស្មុគស្មាញខ្លាំងណាស់ និងប្លែកៗទៀតផង ដូច្នេះស្ត្រីម្នាក់ៗមានបទពិសោធន៍ផ្ទាល់ខ្លួនខុសៗគ្នាតាមនោះដែរ។

**ចំណងអាពាហ៍ពិពាហ៍ក្រោយការរំដោះ**

ស្ត្រីជាច្រើននៅតែបន្តចំណងអាពាហ៍ពិពាហ៍របស់ពួកគេទៀត ទោះជាពួកគេត្រូវគេ “បង្ខំ” ឱ្យរៀបការនៅក្នុងរបបខ្មែរក្រហមក្ដី។ ប៉ុន្តែស្ត្រីជាច្រើនក៏ជ្រើសរើសចាកចេញពីប្ដីរបស់ខ្លួន ហើយប្ដីភាគច្រើនមិនត្រឡប់មកវិញទេ។ មានផ្លូវជាច្រើនដែលស្ត្រីដើរដើម្បីបន្តជីវិតរស់នៅជាមួយប្ដី កុមារ ឪពុកម្ដាយ និងសាច់ញាតិរបស់ខ្លួនទៀត។

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

លោកស្រី ប៊ុន ផល្លា [Bun Phalla] ត្រូវគេបង្ខំឱ្យរៀបការ ជាលទ្ធផលសម្រាលបានកូនស្រីម្នាក់ពីអាពាហ៍ពិពាហ៍ដោយបង្ខំនោះ ហើយគាត់បានបន្តនៅជាមួយប្តីរបស់គាត់ទៀតបន្ទាប់ពីរបបខ្មែរក្រហមចប់[២២២]។ ចំពោះអាពាហ៍ពិពាហ៍នេះ លោកស្រី ប៊ុន [Bun] បាននិយាយថា៖ *"ប្តីខ្ញុំស្រឡាញ់ខ្ញុំ និងបានមើលថែទាំកូនយើងបានយ៉ាងល្អ។ នោះហើយជាមូលហេតុដែលខ្ញុំនៅជាមួយគាត់រហូតមក"*។ ស្ត្រីជាច្រើនបានបង្ហាញទស្សនៈដូចគ្នានឹងគាត់ដែរ នៅពេលសួរថា ហេតុអ្វីបានជាពួកគេនៅតែនៅជាមួយបុរសដែលពួកគេត្រូវបានបង្ខំឱ្យរៀបការជាមួយទៀតនោះ[២២៣]។ គាត់មិនដែលស្រឡាញ់ប្តីដែលគេបង្ខំឱ្យគាត់រៀបការជាមួយនោះទេ ប៉ុន្តែរហូតមកដល់ពេលគាត់ស្លាប់ពីរបីឆ្នាំមុននេះ ពួកគេបាននៅជាមួយគ្នាជាប្តីប្រពន្ធ។ ស្ត្រីមួយចំនួនក៏បាននិយាយដែរថា ពួកគេពេញចិត្តនឹងរក្សាស្ថិរភាពនេះនៅក្នុងជីវិតពួកគេដដែល ជាពិសេសនៅពេលពួកគេមានកូនមួយរួចទៅហើយនោះ។

ស្រដៀងទៅនឹងលោកស្រី ប៊ុន [Bun] ខាងលើដែរ លោកស្រី រ៉ុន [Ron] ក៏បានបន្តរួមរស់ជាមួយប្តីដែលខ្មែរក្រហមបង្ខំគាត់ឱ្យរៀបការជាមួយនោះផងដែរ[២២៤]។

> *ខ្ញុំមិនដែលចង់ឃើញកន្លែងដែលខ្ញុំត្រូវគេបង្ខំឱ្យរៀបការនោះទេ។ នៅពេលខ្ញុំនឹកដល់រឿងរៀបការនោះ ខ្ញុំខឹងខ្លាំងណាស់។ ជាសំណាងល្អ ប្តីរបស់ខ្ញុំពិតជាមនុស្សល្អមែន។ គាត់ចិត្តល្អនឹងខ្ញុំណាស់។ គាត់មិនដែលធ្វើអ្វីអាក្រក់ឱ្យខ្ញុំឈឺចាប់ទេនៅមួយជីវិតអាពាហ៍ពិពាហ៍របស់យើងនេះ។*

លោកស្រី រ៉ុន [Ron] បានបន្តរួមរស់ជាមួយប្តីគាត់ទៀតនៅក្រោយរបបខ្មែរក្រហម ហើយពួកគេពិតជាគិតចង់រៀបចំពិធីមង្គលការម្តងទៀតដើម្បីអបអរដល់អាពាហ៍ពិពាហ៍របស់ពួកគេមែន។ ជាអកុសលរឿងនោះមិនអាចទៅរួចទេ ដោយសារតែប្តីរបស់គាត់បានលាចាកលោកពីរឆ្នាំមកហើយ។ ស្ត្រីជាច្រើនបានបាត់បង់ប្តីរបស់ខ្លួនក្នុងរបបខ្មែរក្រហម។ ប្តីរបស់លោកស្រី នូ ខន [Nu Khorn] ត្រូវគេសម្លាប់នៅពេលកូនទីពីររបស់ពួកគេទើបតែបានអាយុ ១ ខែ។ គាត់បានបន្តមើលថែកូនរបស់គាត់ និងកូនប្រុសរបស់ប្តីគាត់ពីអាពាហ៍ពិពាហ៍មុនផងដែរ។ គាត់បានសម្រេចចិត្តមិនរៀបការម្តងទៀតទេ *"ព្រោះខ្ញុំខ្លាចថា អនាគតប្តីខ្ញុំអាចនឹងធ្វើបាបកូនប្តីមុនរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំបាននៅតែម្នាក់ឯងក្រោយពេលសង្គ្រាមចប់'*[២២៥]។

ផ្ទុយទៅវិញ មានស្ត្រីមួយចំនួនដែលបានលែងលះប្តីរបស់ពួកគេ។ លោកស្រី ព្រុយ រ័ត្ន [Prui Rat] ដែលបានរៀបការក្នុងរបបខ្មែរក្រហម បានលែងលះប្តីរបស់គាត់ នៅពេលគាត់មានផ្ទៃពោះកូនទី ៤ បាន ៣ ខែ។ គាត់បាននិយាយថា៖ *"ប្តីខ្ញុំជាមនុស្សធ្វើបាបប្រពន្ធកូនណាស់។ ខ្ញុំមិនអាចនៅជាមួយគាត់បានទៀតទេ។ នៅពេលខ្ញុំសម្រេចចិត្តធ្វើដូចនេះ ខ្ញុំមានដីខ្លះដែលប្រធានភូមិចែកឱ្យគ្រួសារនីមួយៗ ដូច្នេះ ខ្ញុំអាចផ្គត់ផ្គង់ដល់កូនខ្ញុំ ទោះជាគ្មានគាត់ក៏ដោយ*[២២៦] ។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

ដូចគ្នានេះផងដែរ ការបាត់ខ្លួនរបស់ប្តីក្រោយការរំដោះ ក៏ត្រូវគេរាយការណ៍ផងដែរ។ លោកស្រី នន់ នួន [Non Nuon] អាយុ ៦៨ ឆ្នាំ ត្រូវគេបង្ខំឱ្យរៀបការនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែបន្ទាប់ពីការរំដោះ ប្តីគាត់បានបាត់ខ្លួន នៅពេលកូនដំបូងរបស់គាត់បានអាយុ ១២ ខែ និងកូនទីពីរបានអាយុ ២ ខែប៉ុណ្ណោះ[២២៧]។

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

[Chapter 13]

## ជំពូកទី ១៣: សេចក្តីសន្និដ្ឋាន

### កេរដំណែលនៃអាពាហ៍ពិពាហ៍ដោយបង្ខំ

ការស្រាវជ្រាវនេះបានជួបជាមួយស្ត្រីចំនួន ៣១ នាក់ដែលបានរៀបការក្នុងរបបខ្មែរក្រហម។ អាពាហ៍ពិពាហ៍មួយចំនួនបានបញ្ចប់ដោយសារការស្លាប់ ឬការបាត់ខ្លួនរបស់ប្តី និងខ្លះទៀតដោយការលែងលះគ្នា រីឯងស្ត្រីមួយចំនួនសម្រេចចិត្តបន្តចំណងអាពាហ៍ពិពាហ៍របស់ពួកគេទៀត។ អាពាហ៍ពិពាហ៍ដោយបង្ខំគឺបញ្ហាស្មុគស្មាញមួយ។ ស្ត្រីជាច្រើននៅតែរួមរស់ជាមួយបុរសដែលខ្លួនត្រូវបានបង្ខំឱ្យរៀបការជាមួយ ដោយឪពុកម្តាយមិនមែនជាអ្នករៀបចំអាពាហ៍ពិពាហ៍នោះតាមប្រពៃណីឡើយ ប៉ុន្តែ ឪពុកម្តាយខ្លះសប្បាយចិត្តដែលឃើញកូនស្រីរបស់ខ្លួនរៀបការកាលពីនៅរបបខ្មែរក្រហមនោះ។

មានហេតុផលជាច្រើនផ្សេងៗគ្នាដែលស្ត្រីសម្រេចចិត្តបន្តចំណងអាពាហ៍ពិពាហ៍ ដែលរៀបចំដោយខ្មែរក្រហមនេះទៀត។ គេពិបាកនឹងយល់ពីការសម្រេចចិត្តរបស់ពួកគេនេះណាស់ជាទូទៅ។ មូលហេតុច្រំដែលបំផុតនោះគឺ ប្តីរបស់ពួកគេបានយកម្ហូបអាហារឱ្យពួកគេ និងកូន ហើយពួកគេប្រែជាគិតថា ប្តីរបស់ខ្លួនជាបុរសល្អដែលអាចនៅជាមួយបាន។

លើសពីនេះទៀត ស្ត្រីជាច្រើនទទួលស្គាល់ថា ពួកគេបានរៀបការរួចហើយ បើទោះជាអ្នកណាជាអ្នកសម្រេចចិត្តឱ្យពួកគេក្តី។ លោកស្រី ហៀម សារឿន [Heam Sa Roeun] អាយុ ៦២ ឆ្នាំ ក៏ត្រូវគេបង្ខំឱ្យរៀបការ និងមានកូនមួយនៅក្នុងរបបខ្មែរក្រហមផងដែរ។ គាត់បាននិយាយថា៖ *"ដោយសារពួកគេបានរៀបការក្លាយជាប្តីប្រពន្ធរួចហើយ ពួកគេគួរតែបន្តចំណងអាពាហ៍ពិពាហ៍នេះ និងរួមរស់ជាមួយគ្នារហូតទៅ"*[២៣៧]។ ស្ត្រី និងបុរសជាច្រើនបានចែករំលែកទស្សនៈរបស់ខ្លួន។ ដោយសារទំនៀមទម្លាប់ខ្មែរដែលកូនស្រីគ្មានអំណាចធ្វើការសម្រេចចិត្តអ្វីបានទាំងអស់ទាក់ទងនឹងការរៀបចំជីវិតគូ ពួកគេបានទទួលយកផ្នត់គំនិតដែលថា នរណាម្នាក់នឹង "នាំយក" ព្រះអង្គម្ចាស់របស់ខ្លួនមកឱ្យរៀបការជាមួយមិនខាន។ ទាក់ទងនឹងបញ្ហានេះ ជារឿងកាន់តែមានន័យទៀតក្នុងការវិភាគ "អាពាហ៍ពិពាហ៍ដោយបង្ខំ" នេះចេញពីទស្សនៈរបស់បុរស ព្រោះពួកគេត្រូវបានដកហូតតួនាទីជាប្រពៃណីរបស់ខ្លួនក្នុងការផ្តួចផ្តើមដំណើរការអាពាហ៍ពិពាហ៍។ កង្វះដំណើរការផ្តួចផ្តើមនេះអាចប៉ះពាល់ដល់ទស្សនៈអំពីភាពជាបុរសរបស់ខ្លួន។

ស្ត្រីភាគច្រើនដែលត្រូវខ្មែរក្រហមបង្ខំឱ្យរៀបការ មិនដែលខ្វល់ពីស្ថានភាពគ្រួសាររបស់ពួកគេឡើយនៅពេលរបបខ្មែរក្រហមបញ្ចប់។ អាទិភាពរបស់ពួកគេគឺការរស់រានមានជីវិត។ ពួកគេភាគច្រើន ត្រូវការប្តីជាចាំបាច់ដើម្បីស្វែងរកអាហារ និងទីជម្រកមានសុវត្ថិភាព។ ស្ត្រីរំពឹងថា ប្តីរបស់ខ្លួននឹងបំពេញតួនាទីរបស់បុរសតាមប្រពៃណីនៅក្នុងគ្រួសារ ជាអ្នកការពារ និងទំនុកបម្រុង។ ស្ត្រីគ្រាន់តែទទួលស្គាល់ថា ខ្លួនបានរៀបការរួចហើយ និងបន្តរស់នៅជាមួយប្តីរបស់ខ្លួនតទៅទៀត។ ទោះជាយ៉ាងណា ស្ត្រីខ្លះបានសម្រេច

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

ចិត្តបញ្ចប់អាពាហ៍ពិពាហ៍របស់ពួកគេ ដោយសារប្ដីរបស់ពួកគេធ្វើបាបពួកគេ ដូច្នេះ ពួកគេមិនអាចនៅជាមួយគ្នាបានទៀតទេ។ មានបទពិសោធន៍ច្រើនប្រភេទចម្រុះគ្នាអំពីអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ប៉ុន្តែស្ត្រីភាគច្រើនដែលយល់ព្រមផ្ដល់បទសម្ភាសន៍បាននិយាយថា ពួកគេប្រែជាសង្កេតឃើញប្ដីរបស់ខ្លួនចិត្តល្អ និងជាមនុស្សល្អ ហើយនោះគឺជាមូលហេតុដែលពួកគេសម្រេចចិត្តរួមរស់ជាមួយគ្នាបន្តទៀត។ ក្នុងករណីណាក៏ដោយ ស្ត្រីស្ទើរតែគ្មានជម្រើសចំពោះរឿងអាពាហ៍ពិពាហ៍របស់ខ្លួន សូម្បីតែមុនពេលមានសង្គ្រាមក្តី ដូច្នេះ ដរាបណាប្ដីរបស់គាត់មិនប្រើហិង្សាខ្លាំងពេក ពួកគេពេញចិត្តនឹងរួមរស់ជាមួយគាត់ហើយ។ ក្នុងករណីជាច្រើន ឪពុកម្ដាយរបស់ពួកគេបានស្លាប់បាត់ហើយនៅពេលចប់សង្គ្រាម ដូច្នេះ ពួកគេជាធម្មតាមិនចាំបាច់ព្រួយបារម្ភអំពីទំនាក់ទំនងជាមួយឪពុកម្ដាយក្មេកទៀតទេ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បាន និងកំពុងកាត់ទោសមេដឹកនាំកំពូលៗនៃរបបខ្មែរក្រហមក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ។ ដូច្នេះ គេមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានរៀបចំឡើងដោយខ្មែរក្រហម ហើយសិទ្ធិមនុស្សជាមូលដ្ឋានត្រូវបានរំលោភដោយមេដឹកនាំខ្មែរក្រហម។ បញ្ហានេះបានទាក់ទាញចំណាប់អារម្មណ៍ពីសំណាក់ប្រជាជន ជាពិសេសក្នុងចំណោមយុវជន។ សិស្សវ័យក្មេងនៅក្នុងថ្នាក់របស់ខ្ញុំនៅក្នុងឆ្នាំ ២០០៥ នៅពេលខ្ញុំធ្វើការស្រាវជ្រាវដំបូងលើបញ្ហានេះ ភាគច្រើនមិនបានដឹងអ្វីទាំងអស់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំនេះទេ ព្រោះគ្មាននរណាម្នាក់និយាយអំពីរឿងនេះឡើយ។ នៅរង្វង់ឆ្នាំ ២០១០ សិស្សបានចាប់ផ្ដើមនិយាយប្រាប់ខ្ញុំថា ពួកគេទើបនឹងបានដឹងថា សាច់ញាតិ ឬឪពុកម្ដាយរបស់ពួកគេត្រូវគេបង្ខំឱ្យរៀបការក្នុងអំឡុងរបបខ្មែរក្រហម។ ឥឡូវនេះ នៅក្នុងឆ្នាំ ២០១៥ សិស្សភាគច្រើននៅក្នុងថ្នាក់របស់ខ្ញុំបានដឹងថា មានអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបខ្មែរក្រហម ប្រហែលជាដោយសារការងាររបស់ អ.វ.ត.ក ដែលបានដោះស្រាយការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរនេះ។

ទោះជាយ៉ាងណា មានគំនិតចម្រុះគ្នាអំពីការលោតត្រដាងអាពាហ៍ពិពាហ៍ដោយបង្ខំនេះដល់កុមារដែលកើតចេញពីអាពាហ៍ពិពាហ៍បែបនេះ។ លោកស្រី ប៊ុន ផល្លា [Bun Phalla] មកពីខេត្តរតនគីរី ត្រូវបានគេបង្ខំឱ្យរៀបការ ហើយជាលទ្ធផលបានកូនស្រីម្នាក់ពីចំណងដោយបង្ខំនេះ។ គាត់បានបន្តរស់នៅជាមួយប្ដីរបស់គាត់ទៀតនៅក្រោយរបបខ្មែរក្រហម។ គាត់បាននិយាយថា៖ "ខ្ញុំមិនដែលចង់ទៅឃើញភូមិចាស់របស់ខ្ញុំ និងកន្លែងដែលខ្ញុំត្រូវគេបង្ខំឱ្យរៀបការនោះទេ។ អតីតកាលបានធ្វើឱ្យខ្ញុំនឹកឃើញដល់រឿងរ៉ាវឈឺចាប់ជាច្រើន ហើយខ្ញុំមិនចង់រំលឹករឿងអ្វីពីពេលនោះឡើងវិញឡើយ"[២៣៨]។ លោកស្រី រ៉ុន [Ron] ក៏បានបន្តរស់នៅជាមួយប្ដីដែលខ្មែរក្រហមបង្ខំគាត់ឱ្យរៀបការជាមួយនោះដដែល។ គាត់និយាយថា *"ខ្ញុំនិយាយអំពីអតីតកាលរបស់ខ្ញុំប្រាប់អ្នក។ ប៉ុន្តែតាមពិត ខ្ញុំមិនចង់និយាយអំពីរឿងនោះទេ។ ខ្ញុំមិនចង់រំលឹកបទពិសោធន៍ដ៏អាក្រក់របស់ខ្ញុំឡើងវិញឡើយ។ គ្រាន់តែរំលឹកឡើងវិញក៏ធ្វើឱ្យខ្ញុំឈឺចាប់ខ្លាំងណាស់ដែរ"*[២៣៩]។ ការនិយាយ

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

អំពីអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាបញ្ហារសើបមួយ ដោយសារស្ត្រីភាគច្រើននៅតែរក្សាចំណង អាពាហ៍ពិពាហ៍នោះទៀត ហើយពួកគេប្រហែលជាមិនចង់បង្ហើបរឿងអតីតកាលដល់កូនចៅរបស់ពួកគេទេ។

Formatted: Condensed by 0.3 pt

នៅក្នុងអំឡុងពេលនៃការស្រាវជ្រាវរបស់យើង យើងបានជួបជាមួយស្ត្រីជាច្រើនដែលបាននិយាយថា គូស្វាមីភរិយាដែលត្រូវគេបង្ខំឱ្យរៀបការមិនគួរប្រាប់កូនរបស់ខ្លួនអំពីរឿងនោះទេ។ លោកអ៊ាន វ៉ែន [Ean Ven] អាយុ ៧០ ឆ្នាំ បាននិយាយថា៖ *"ឪពុកម្ដាយមិនគួរនិយាយអំពីអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ ព្រោះកូនៗអាចនឹងគិតថា ពួកគេកើតមកដោយសារតែអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកខ្មែរក្រហមប៉ុណ្ណោះ ហើយពួកគេអាចនឹងមានការខកចិត្ត"*[២៤០]។យើងត្រូវការពិភាក្សាគ្នាច្រើនទៀតអំពីបញ្ហានេះដើម្បីដោះស្រាយនឹងការប៉ះទង្គិចផ្លូវចិត្តអន្តរជំនាន់ និងដើម្បីផ្ដល់អំណាចដល់ទាំងឪពុកម្ដាយ និងកូន។

**អាថ៌កំបាំងនៃគោលនយោបាយលើចំនួនប្រជាជនរបស់ខ្មែរក្រហម**

ជាការលំបាកយល់ណាស់ថាហេតុអ្វីបានជាខ្មែរក្រហម មិនយកចិត្តទុកដាក់លើសុខភាពរបស់ស្ត្រីត្រៀមសម្រាល និងមិនបានផ្ដល់ការថែទាំដល់ទារកដែលទើបនឹងកើតឱ្យបានគ្រប់គ្រាន់។ ទារកជាច្រើនបានស្លាប់ ដោយសារតែការថែទាំជាមូលដ្ឋានមិនត្រូវបានផ្ដល់ឱ្យតែប៉ុណ្ណោះ។ ចំណាប់អារម្មណ៍របស់ខ្ញុំ តាមរយៈបទសម្ភាសន៍ជាមួយនឹងស្ត្រីទាំងអស់ គឺថា ខ្មែរក្រហមមិនចង់ឱ្យទារកណាម្នាក់កើតមកទេ។ គ្មានភស្តុតាងជាឯកសារណាគាំទ្រដល់ចំណុចនេះទេ ប៉ុន្តែរឿងរ៉ាវទាំងអស់ដែលបានមកពីស្ត្រី ចង្អុលបង្ហាញពីការសន្និដ្ឋានដូចគ្នានេះផងដែរ ពោលគឺ ខ្មែរក្រហមមិនចង់ឱ្យមានទារកកើតមកទេ។ ស្ត្រីទាំងអស់ដែលយល់ព្រមផ្ដល់បទសម្ភាសន៍ បានទទួលរងគ្រោះយ៉ាងខ្លាំងដោយសារតែការមានផ្ទៃពោះ។ ពួកគេបានរលូតកូន និងបាត់បង់កូនដែលនៅក្មេងខ្ចីរបស់ខ្លួន។ គ្មានសញ្ញាណាដែលថា ខ្មែរក្រហមយកចិត្តទុកដាក់ចំពោះសុខភាព ឬសុខុមាលភាពរបស់ស្ត្រីដែលត្រៀមធ្វើជាម្ដាយ ឬកូនរបស់ពួកគេទេ។ អៀង ធីរិទ្ធិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៅក្នុងរបបខ្មែរក្រហម ដែលបានលាចាកលោកទៅនៅខែ សីហា ឆ្នាំ ២០១៥ ធ្លាប់ត្រូវគេរាយការណ៍ថា រូបគាត់បាននិយាយថា ខ្មែរក្រហមចង់ឱ្យមានកំណើនចំនួនប្រជាជន ប៉ុន្តែខ្ញុំមិនបានរកឃើញភស្តុតាងណាដែលគាំទ្រដល់សេចក្ដីថ្លែងការណ៍របស់គាត់នោះទេ។ ជារឿងអកុសលណាស់ដែលតួអង្គ សំខាន់ៗជាប្រវត្តិសាស្ត្របានស្លាប់អស់។

ដូច្នេះ រឿងនេះនៅតែជាអាថ៌កំបាំងថាតើហេតុអ្វីបានជាខ្មែរក្រហមមិនយកចិត្តទុកដាក់ចំពោះស្ត្រីមានផ្ទៃពោះ ក៏ដូចជាទារកដែលទើបនឹងកើត បើពួកគេពិតជាចង់បង្កើតមនុស្សជំនាន់ថ្មីដែលអាចរួមចំណែកយ៉ាងពេញលេញដល់បដិវត្តន៍មែននោះ។ ក្ដីសង្ឃឹមតែមួយគត់នោះគឺថា អ.វ.ត.ក អាចរកឃើញព័ត៌មានមួយចំនួនអំពីគោលនយោបាយនៃប្រព័ន្ធអភិបាលកិច្ចរបស់ខ្មែរក្រហម។ លោកស្រី ជូ ជួប [Chou Choub] បាននិយាយថា៖

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];

*បើសិនខ្ញុំនិយាយថា៖ "តើខ្ញុំខឹងនឹងរឿងអ្វី" ខ្ញុំខឹងនឹងមេដឹកនាំកំពូលៗដែលបានបញ្ជាឱ្យពួកយើងធ្វើអ្វីគ្រប់យ៉ាងទោះជាយើងមិនចង់ក្តី។ ខ្ញុំខឹងខ្លាំងណាស់ ប៉ុន្តែមិនអាចធ្វើអ្វីបានឡើយ។ ជារឿងធម្មតាទៅហើយសម្រាប់មនុស្សគ្រប់គ្នាដែលពួកគេមិនអាចធ្វើអ្វីបាននោះ។*

ជាការទទួលខុសត្រូវរួមដើម្បីយល់បានថា ហេតុអ្វីខ្មែរក្រហមឡើងកាន់អំណាច ហេតុអ្វីបានជាពួកគេសម្លាប់ប្រជាជនខ្លួនឯង ហើយហេតុអ្វីបានជាស្ត្រីត្រូវទទួលរងគ្រោះ។ គេចាំបាច់ត្រូវការការស្រាវជ្រាវជាច្រើនទៀតដើម្បីផ្តល់នូវរូបភាពកាន់តែច្បាស់មួយនូវអ្វីដែលបានកើតឡើង ជាពិសេសចេញពីទស្សនវិស័យនៃការផ្តល់អំណាចដល់ស្ត្រី។ ស្ត្រីទាំងអស់ដែលនៅរស់រានមានជីវិត សុទ្ធតែជាស្ត្រីដែលមានអនុភាព ហើយពួកគេសក្តិសមនឹងទទួលបានការកោតសរសើរ។ ជាការសំខាន់ណាស់ដែលរឿងរ៉ាវរបស់ពួកគេត្រូវគេផ្សព្វផ្សាយសឱ្យបានដឹងដល់ក្មេងជំនាន់ក្រោយ ដែលមិនដែលបានដោះស្រាយនឹងការលំបាកបែបនោះ។

[រូបភាព]

លោកស្រី ឈុន ឡៃ Chhun Ley ខេត្តសៀមរាប ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

Original EN: 01322840-01322893
Translated: [Chapter 1]; [Chapter 3]; [Chapter 5]; [Chapter 6]; [Chapter 7]; [Chapter 8]; [Chapter 12]; [Chapter 13];